## មាតិការឿង

១.ព្រះមហាក្សត្រនរោត្តម........................០៤
២.គុកទួលស្លែងនឹងក្លាយជាសារមន្ទីរ............០៥
៣.ថ្ងៃបុណ្យនៃពួកប្រេត.,កូនខ្មែររៀនសូកប៉ាន់...០៧
៤.អ្នកស្រុកនាំគ្នាស្រែកយំ........................ ០៩
៥.សោភ័ណ្ឌភាព និងសុខភាព...................... ១២
៧.នាទីប្រវត្តិសាស្ត្រ និងនាទីព្រះពុទ្ធសាសនា... ១៣
៦.សួនកំណាព្យ..........................................១៦
៧.ជីវិតរបស់ភរិយាអធិរាជសំម្លែងមាស.......... ២១


# ខ្មែរប៉ុស្តិ៍
# The Khmer Post


ទូរស័ព្ទពាណិជ្ជកម្មខ្មែរប៉ុស្តិ៍ ហ្វីឡាដែលហ្វីយ៉ា
* សុបិន : (២៦៧) ២៥៣-៣៩៤៧
* ទូរស័ព្ទ នៅរ៉ូដអាយឡិន
* សេរី : (៤០១) ៩១៩-៩៩៥៤

ទូរស័ព្ទវិទ្យុសម្លេងខ្មែរអាមេរិកាំង
* ស៊ីដន : (២១៥) ២៨៤-១៣៤៣

Email : khmerpostec@gmail.com

KHMER BILINGUAL BIWEEKLY NEWSPAPER

VOLUME 02 ISSUE September 23th-October 09th 2008 ADVERTISING (267) 253-3947 WWW.THEKHMERPOST.COM


## តុលាការសហព័ន្ធច្រានចោលបណ្តឹងរឿងទំនាស់វត្ត IRAP

ឡុងប៊ិច : មាជ សុណ្ណារ៉ា


ផិត្យ ស៊ីផាន់ (រូបថត ឯល ម៉ាន់ថា)

●●● តុលាការសហព័ន្ធបានច្រានចោលបណ្តឹងរឿងជម្លោះវត្ត IRAP ដែលគណៈកម្មការវត្តចាស់ (តនៅទំព័រទី១៨)

## រៀបចំចូលភ្ជុំបិណ្ឌនៅហ្វីឡាដែលហ្វៀ



ដោយ : ពិន សំខុន

●●● បុណ្យភ្ជុំបិណ្ឌនឹងបានរំកិលមកជិតដល់ហើយ គេនឹងនាំគ្នាប្រារព្ធពិធីនេះ (តនៅទំព័រទី០៨)

## គណបក្សប្រឆាំងពីរពិតជាធ្វើពហិការ ?

ភ្នំពេញ,ខ្មែរប៉ុស្តិ៍ : ចាន់ កុសល


គណបក្សប្រឆាំងកំពុងធ្វើសន្និសីទកាសែត មិនទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត

●●● គណបក្សហ្វ៊ុនសិនប៉ិច និងគណបក្សនរោត្តម រណឫទ្ធិ ដែលបានទទួលលាភសក្ការៈពីគណបក្សប្រជាជនកម្ពុជាបានច្រានចោលសម្ព័ន្ធមិត្តរបស់ខ្លួន និងទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតជាតិ កាលពីថ្ងៃទី២៧ខែកក្កដា កន្លងមកនេះ ។

ចំណែកឯគណបក្សសិទ្ធិមនុស្ស និងគណបក្ស សម រង្ស៊ី ដែលមានគោលការណ៍ច្បាស់លាស់ក្នុង (តនៅទំព័រទី០៦)

## ដឹកដៃខ្មែរ នៅហ្វីឡាដែលហ្វៀ ទៅបោះឆ្នោត



នាង ស៊ន នាយិកាប្រតិបត្តិសមាគមខ្មែរ



អ្នកឯកទេសពន្យល់ពីរបៀបបោះឆ្នោត

## ទិវាដ៏សំខាន់សំរាប់ប្អូរជីវភាពពលរដ្ឋខ្មែរ_អាមេរិកាំង

ដោយ : អ៊ុម លឿង

●●● នៅសល់តែជាងពីរខែទៀតប៉ុណ្ណោះ ការបោះឆ្នោតជ្រើសរើសបេក្ខភាពប្រធានាធិបតីថ្មី របស់សហរដ្ឋអាមេរិក នឹងត្រូវរៀបចំធ្វើឡើងទូទាំងសហរដ្ឋអាមេរិកទាំងមូល ។ លោក បារ៉ាក់ អូបាម៉ា ជាបេក្ខជនប្រធានាធិបតី មកពីគណបក្សប្រជាធិបតេយ្យ និង ចន ម៉ាកេន មកពីគណបក្សសាធារណរដ្ឋ គឺជាផ្ទាំងស៊ុបសម្រាប់ប្រជាពលរដ្ឋអាមេរិកាំងទាំងអស់ ដែលមានសិទ្ធិបោះឆ្នោត និងជាអនាគតនាវាដ៏ប្រណិតក្នុងការដឹកនាំសហរដ្ឋអាមេរិកទាំងមូល ឆ្ពោះទៅកាន់ត្រើយនៃភាពចម្រើនលូតលាស់របស់ប្រទេសជាតិ ។

សហគមន៍ខ្មែរប្រចាំរដ្ឋផែនស៊ីវេនញៀ នៃទីក្រុងហ្វីឡាដែលហ្វៀ បានដុតដៃដុតជើងយ៉ាងសកម្មក្នុងការរៀបចំធ្វើកិច្ចប្រជុំមួយរបស់សហគមន៍ខ្មែរ ក្រោមប្រធានបទ " កិច្ចប្រជុំអ្នកបោះឆ្នោតខ្មែរ-អាមេរិកាំង " ដើម្បីជួយសម្រួលដល់បងប្អូនខ្មែរ-អាមេរិកាំង ឱ្យមានការងាយស្រួលយល់ក្នុងការបោះឆ្នោតជាសកលដែលនឹងប្រព្រឹត្តធ្វើឡើងនៅថ្ងៃទី០៤ ខែវិច្ឆិកា ខាងមុខនេះ ។

លោក សម សិរិទ្ធ ប្រធានសហគមន៍ខ្មែរ ប្រចាំក្រុងហ្វីឡាដែល-ហ្វៀ មានប្រសាសន៍ថា : "នៅជាពេលមួយដ៏ល្អបំផុត ដែលមានបងប្អូនខ្មែរយើងមកចូលរួមប្រជុំ ដើម្បីស្វែងយល់ក្នុងការបោះឆ្នោត ព្រោះនេះ ជាភារកិច្ចរបស់យើងគ្រប់គ្នាក្នុងនាមជាខ្មែរអាមេរិកាំង"។

អ្នកស្រី ស៊ុយ ស៊ុនឌី នាយិកាប្រតិបត្តិរបស់សហគមន៍ខ្មែរ ក៏បានថ្លែងក្នុងឱកាសនោះថា "ពេលនេះសហគមន៍ខ្មែរ ពុំមែនជាអ្នកឃោសនាសម្រាប់គណបក្សនយោបាយណាមួយឡើយ, ឈរនៅលើផ្លូវកណ្តាលទេ តែគ្រាន់ជាដំណឹងសម្រាប់ឱ្យបងប្អូនបានយល់ដឹងផ្នែកបោះឆ្នោតតែប៉ុណ្ណោះ" ។

លោក ត្រៃ ហ៊ួល ជាពលរដ្ឋខ្មែរ-អាមេរិកាំង នៅហ្វីឡាខាងត្បូង ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះ បានប្រាប់ខ្មែរប៉ុស្តិ៍ថា "ក្នុងនាមលោកជាខ្មែរ-អាមេរិកាំង ចាំបាច់លោកត្រូវតែបំពេញនូវតួនាទីរបស់ខ្លួន" ដោយការចុះឈ្មោះបោះឆ្នោត ហើយការដែលលោកមានវត្តមាននៅទីនេះ គឺអាស្រ័យដោយការជូនដំណឹងពីសហ-គមន៍ខ្មែរ ។ ចំពោះសំនួរដែលសួរថា តើលោកបោះឆ្នោតឱ្យគណបក្សណាមួយនោះ លោកពុំអាចជម្រាបបានឡើយ ព្រោះនោះជារឿងសម្ងាត់ ។

ចំណែកឯលោក ប៊ុន ស៊ុន អាយុ៧៨ឆ្នាំ មានទីលំនៅតំបន់ហ្វីឡាដែលហ្វីហ្វៀខាងជើង បានសំដែងនូវទស្សនៈផ្ទាល់ខ្លួនថា : "នេះជាកម្មវិធីដ៏ល្អមួយសម្រាប់ជាផលប្រយោជន៍ដល់បងប្អូនខ្មែរ ព្រោះសព្វថ្ងៃយើងមករស់នៅក្នុងសហរដ្ឋអាមេរិក ដូច្នេះយើងជាកូន ជាចៅ គួរតែបំពេញនូវតួនាទីរបស់ខ្លួនកុំបីខាន " ។

(តនៅទំព័រទី០៣)





Fast & Friendly Service

USA
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO

Cambodia: Victory Travel
No. 96 Eo Street. 148, Phsar Kandal
Phnom Penh, Cambodia
Tel: 011-892329
Manager SIN PO
CHENDA: 023-221069


## ដៃពីរទ្រទ្រង់ជីវិតសារព័ត៌មានមួយ

ដោយ : ពិន សំខុន



●●● កាសែត " ខ្មែរប៉ុស្តិ៍ " ដែលដៃពីរកំពុងកាន់អានេះ កើតឡើងដូចគ្នារវាង " **ដៃម្ខាង**" អ្នកកសាង និង "**ដៃម្ខាងទៀត**" អ្នកគាំទ្រ ។ យើងមានវាសនាជាដៃម្ខាងក្នុងនាមជាអ្នកផលិតកំពុងបំរើលោកអ្នកអានដែលកើនចំនួនរៀងរាល់ថ្ងៃយ៉ាងគួរឱ្យចាប់អារម្មណ៍ធ្វើឱ្យ " **ជីវិតមួយ** " និងសារ-ព័ត៌មានខ្មែរអាចផ្សាយបានយ៉ាងមានសេចក្តីសង្ឃឹម និងយ៉ាងកក់ក្តៅនៅក្រៅប្រទេសកម្ពុជា ។ " ខ្មែរប៉ុស្តិ៍ " ជា (តនៅទំព័រទី១៩)

សូមអញ្ជើញស្តាប់វិទ្យុសម្លេងខ្មែរអាមេរិកាំង នៅ ហ្វីឡាដែលហ្វីយ៉ា AM1540 នៅរៀងរាល់ថ្ងៃសៅរ៍ ពីម៉ោង ៣ ដល់ ៤ រសៀល

# សន្សំសំចៃនារដូវរងារខាងមុខ

ខ្យល់ត្រជាក់ចាប់ផ្តើមធ្លាក់មកដល់ហើយ រដូវស្លឹកឈើជ្រុសក៏មកដល់ហើយដែរ លោក-អ្នកនៅមានពេលខ្លះដែរទឹងជួសជុលផ្ទះសម្បែង ដែលរៀងរាល់ឆ្នាំ តែងតែទទួលការទ្រុឌទ្រោមដោយប្រការណាមួយ ។ អង្គការ " យូណេទិចវេយ " បានផ្សព្វផ្សាយនៅគំនូរស្រួលបល់ជូនម្ចាស់គេហដ្ឋាន សំរាប់ប្រឈមមុខខ្មែរធ្លាក់ទឹកក ដែលនឹងមកដល់នៅពេលឆាប់ៗ នេះ ។



# ការពិតនៃការទទួលទានបារី



- ✓ បារីមានជាតិនីកូទីន (Nicotine)។ ជាតិនីកូទីនគឺជាគ្រឿងញៀន។
- ✓ ផ្សែងបារីមានជាតិគីមីចំនួនច្រើនជាង ៤,០០០ យ៉ាងទៅទៀត។ ក្នុងចំណោមនោះ មានជាតិគីមីជាច្រើនដែលមានជាតិពុល ហើយភាគច្រើនអាចបណ្តាលឲ្យកើតជម្ងឺមហារីកផង។
- ✓ ការទទួលទានបារីអាចបង្កើននូវការកើតជម្ងឺមហារីកសួត និងជម្ងឺមហារីកដទៃផ្សេងទៀត។
- ✓ ការទទួលទានបារីជាមូលហេតុដ៏ចម្បងមួយដែលបណ្តាលឲ្យកើតជម្ងឺបេះដូង។
- ✓ ជាមធ្យម អ្នកទទួលទានបារីចំណាយប្រាក់ប្រហែលជា ១,០០០ ដុល្លា ក្នុងមួយឆ្នាំៗទៅលើបារី។
- ✓ ការទទួលទានបារីក្នុងកំឡុងពេលមានផ្ទៃពោះអាចបំផ្លាញការលូតលាស់របស់ទារកនៅក្នុងផ្ទៃ។
- ✓ អ្នកមិនទទួលទានបារីដែលរស់នៅនិងធ្វើការនៅកន្លែងដែលមានអ្នកទទួលទានបារីអាចមានសុខភាពពុំល្អ។ ជាពិសេស ចំពោះកូនក្មេងវាអាចមានគ្រោះថ្នាក់យ៉ាងខ្លាំង។
- ✓ ជារៀងរាល់ឆ្នាំ ការទទួលទានបារីបណ្តាលឲ្យមានមនុស្សស្លាប់ច្រើនជាងបញ្ហាសុរា, គ្រោះថ្នាក់ចរយន្ត, ជម្ងឺអេដស៍, អត្តឃាតកម្ម, ឃាតកម្ម, អគ្គីភ័យ, គ្រឿងញៀនកូកាអ៊ីន និងគ្រឿងញៀនហេរ៉ូអ៊ីន រួមគ្នា ទៅទៀត។


## AMERICAN LEGION POST 153 PRESENTS



សូមអញ្ជើញមកពីសាយ ពិសារគ្រឿងភេសជ្ជៈ ពីកំសាន្តនៅ "ហ្វ្រង់ទិក"

**FRANTIC**

DJ FRIDAY AND SATURDAY
FROM 9 P.M. – 3 A.M.
MEMBERS ONLY
SMOKING PERMITTED

2514 S. 24TH ST.
PHILA., PA 19145
215-551-1950

### មន្ទីរបរិយាកាសយ៉ាងត្រជាក់ចិត្ត បន្ទាប់ពីធ្វើការងារហត់នឿយ !

កន្លែងកំសាន្តធំទូលាយ-ស្តាប់ភ្លេងយ៉ាងពិរោះអស្ចារ្យ ឬក៏បុកប៊ីយ៉ា ក៏មានជូនកំសាន្តដែរ ។
យើងខ្ញុំរីករាយណាស់នឹងឃើញលោក-អ្នកអញ្ជើញមក !
ថ្ងៃសុក្រ-សៅរ៍ ពីម៉ោង ៩ ដល់ម៉ោង ៣ ព្រឹក
**DJ** នឹងបំពេញអារម្មណ៍លោក-អ្នកតាមតន្ត្រីសំរាំងថ្មីៗ



ចង់ជួលសាល ឬចង់បានម្ហូបជប់លៀង យើងធ្វើជូនបាន !
HALL RENTAL & CATERING AVALIABLE
REASONABLE PRICE



## Nationwide

Insurance & Financial Service

សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ

We offer Cheap Price for Every Client

យើងធ្វើជូនគ្រប់ភ្ញៀវដោយតម្លៃទាប

| | |
|---|---|
| Business Liability Insurance | ធានារ៉ាប់រងជំនួញឃោរកម្មករ |
| Home Insurance | ធានារ៉ាប់រងផ្ទះសម្បែង |
| Health Insurance | ធានារ៉ាប់រង សុខភាព |
| Auto Insurance | ធានារ៉ាប់រងរថយន្ត |
| Life Insurance | ធានារ៉ាប់រងជីវិត |

Discount 30% when you purchase
Home & Auto Insurance

ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ
ធានារ៉ាប់រង ផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

North Philadelphia office:
6603 Bustleton Ave.
Philadelphia, Pa 19149
Tel: (215) 335-2140
Fax: (215) 335-2147

## (តមកពីទំព័រទី០១) ទិវាដ៏សំខាន់សំរាប់ប្តូរជីវភាពពលរដ្ឋខ្មែរ...

លោក ប៊ុន ស៊ុន បានបន្តដោយឥតលាក់លៀមថា លោកជាអ្នកគាំទ្រ " គណបក្សសាធារណរដ្ឋ" ដោយថែមទាំងបង្ហាញនូវប័ណ្ណ (Card) មួយចំនួនផងដែរ ។

រីឯលោក មាស សារ៉ុន វ័យ៦៤ឆ្នាំ មានទីលំនៅក្នុងតំបន់ហ្វីឡាដែលហ្វីហ្សៀខាងជើង ក៏មានស្សនៈប្រហាក់ប្រហែលវាគ្មិនខាងលើដែរ ។ លោកមានប្រសាសន៍ថា: " ក្នុងនាមជាខ្មែរសញ្ជាតិអាមេរិកាំង លោកត្រូវតែបំពេញនូវតួនាទីរបស់ខ្លួនជាចាំបាច់ ។ ចំណែកគណបក្សដែលលោកមានគំរោងនឹងបោះឆ្នោតជូនលោកមិនត្រូវបានឱ្យ "ខ្មែរប៉ុស្តិ៍" ដឹងឡើយ " ។ ហើយចំពោះដំណឹងនៃការជួបប្រជុំនេះ លោកដឹងតាមរយៈកាសែត " ខ្មែរប៉ុស្តិ៍ " ។

សូមជម្រាបថា: " កិច្ចប្រជុំអ្នកបោះឆ្នោតខ្មែរ-អាមេរិកាំងនេះ បានប្រារព្ធធ្វើឡើងនៅឯអាគារ BCTGM Local 6 5416 Rising Sun AV Phila PA 19120 កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៨ កន្លងមកនេះ ដោយមានភ្ញៀវជាតិ និងអន្តរជាតិ ប្រមាណជាង២៥០នាក់ ព្រមទាំងមានការនិមន្តចូលរួមដោយព្រះសង្ឃគង់នៅវត្តសុរិយារង្សីផងដែរ ។


១. ត្រែ ហ៊ុល ≈ ពុំអាចជំរាបបានទេ


២. ប៊ុន ស៊ុន ≈ លោកជាអ្នកគាំទ្រគណបក្សសាធារណរដ្ឋ


៣.មាស សារ៉ុន ≈ ពុំទាន់និយាយ


៤.ផន ស្រីស្រស់ ≈ ខ្ញុំបោះឱ្យ អូបាម៉ា


៥.ផង់ សារ៉ម ≈ ( បោះឱ្យអ្នកឈ្នះ )


៦. ពុទ្ធារី ឡុង ≈ ខ្ញុំជាអ្នកឯករាជ្យ


៧.ញ៉ឹម ចំរើន ≈ ខ្ញុំចង់បោះឆ្នោតឱ្យអូបាម៉ា


៨.ភឿង ឡុង ≈ ខ្ញុំបោះឆ្នោតឱ្យ ម៉ាកេន


៩. គុជ ធីម ≈ ខ្ញុំបោះឱ្យអ្នកចាញ់


១០. ហាក់ ផន ≈ ខ្ញុំចូលចិត្ត ម៉ាកេន


១១ នឿន អ៊ុច ≈ ខ្ញុំស្រឡាញ់ ម៉ាកេន


១២. ម៉ម យិន ≈ ខ្ញុំបោះឆ្នោតឱ្យ ម៉ាកេន


១៣. រួន ប្រុញ ≈ ខ្ញុំនឹងបោះឆ្នោតឱ្យ ម៉ាកេន


១៤. ជិន ចន្ថា ≈ ខ្ញុំមិនទាន់ដឹងនៅឡើយទេ


១៥. សា អ៊ឹម ≈ ឱ្យជនភាគតិច


១៦. អេមី ផាត ≈ បោះឆ្នោតឱ្យអូបាម៉ា ដោយសារខ្មៅ


១៧. ឈុនគីម សឿន ≈ បោះឱ្យអ្នកអាយុចាស់


១៨. អ៊ូកៅ ≈ តាំងតែពីណាពីណីមកខ្ញុំបោះឱ្យសាធារណរដ្ឋ


១៩.អ៊ូ គីមហួត ≈ ជាធំលាប់ឱ្យបោះឱ្យសាធារណរដ្ឋ


២០. ជេសិន គុជ ≈ បោះឱ្យ ប្រាមា អូបាម៉ា

(តទៅទំព័រទី០៤)

# ព្រះមហាក្សត្រនរោត្តម សីហនុ ធ្វើបណ្តាំមរតក

*ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : ស៊ឹម សុភាឫទ្ធិ*

•••ខណៈពេលដែលអ្នកសារព័ត៌មានបានសរសេរពីទ្រព្យសម្បត្តិដ៏មហាសាលរបស់ព្រះមហាក្សត្រនៅបណ្តាប្រទេសលើពិភពលោក



ព្រះមហាក្សត្រ សីហមុនី



សម្តេចម៉ែ មុនីនាថ សីហនុ

នោះ ។ អតីតព្រះមហាក្សត្រ នរោត្តម សីហនុ បានចុះផ្សាយពីទ្រព្យសម្បត្តិផ្ទាល់របស់ព្រះអង្គ និងអ្នកដែលត្រូវទទួលមរតកថែមទៀតផង ។

កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៨ ពីក្រុងប៉េកាំង ប្រទេសចិន ព្រះមហាក្សត្រនរោត្តម សីហនុ បានចុះផ្សាយលើគេហទំព័រជាភាសាបារាំង ដែលបានប្រកាសពីទ្រព្យសម្បត្តិរបស់ទ្រង់មានចំនួន ៤៤.៨៧១ដុល្លារ ក្នុងធនាគារ Banque Palatine ប្រទេសបារាំង ។

នៅប្រទេសកម្ពុជា ព្រះអង្គមានព្រះរាជដំណាក់ពីរ គឺមួយស្ថិតនៅទីក្រុងភ្នំពេញ និងមួយទៀតនៅខេត្តសៀមរាប ហើយព្រះរាជដំណាក់នេះនឹងក្លាយជាកម្មសិទ្ធិរបស់ព្រះរាជអគ្គមហេសី និងព្រះរាជវាំងក្រុងភ្នំពេញ ជាកម្មសិទ្ធិរបស់បុត្រានរោត្តម សីហមុនី មហាក្សត្របច្ចុប្បន្ន។ ក្រោយពីសម្តេចអគ្គមហេសី នរោត្តម មុនីនាថសីហនុ ចូលទីវង្គតទៅ ព្រះរាជដំណាក់នេះនឹងក្លាយជាកម្មសិទ្ធិរបស់ព្រះមហាក្សត្រនរោត្តម សីហមុនី ។

ព្រះមហាក្សត្រដែលចូលនិវត្តន៍អង្គនេះ បានមានព្រះបន្ទូលថា ព្រះរាជដំណាក់កំណើតរបស់ខ្ញុំស្ថិតនៅក្បែរព្រះបរមរាជវាំង ដែលខ្ញុំបានឱ្យទៅសាធារណរដ្ឋកូរ៉េប្រើប្រាស់កន្លងមកនោះ នឹងក្លាយជាទ្រព្យសម្បត្តិរបស់ព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ២០១៤ ។ ចាប់ពីឆ្នាំ២០១៤ ព្រះរាជដំណាក់នោះនឹងត្រូវបញ្ចូលជាសារមន្ទីរជាតិសំរាប់កូនចៅទាំងអស់គ្នាចូលទៅទស្សនា ។

អតីតព្រះមហាក្សត្រដែលមានព្រះជន្ម៨៥ វស្សាអង្គនេះត្រូវបានប្រជាពលរដ្ឋខ្មែរគោរពស្រឡាញ់ និងមានព្រះកិត្តិនាមល្បីល្បាញ ក្នុងបុព្វហេតុរំដោះប្រទេសជាតិឱ្យរួចពីបរទេសឈ្លានពាន ។ ព្រះកិត្តិនាមរបស់ព្រះអង្គក៏បានល្បីសុសសាយលើឆាកអន្តរជាតិទៀតផង គឺព្រះអង្គធ្វើបូជនីយកិច្ចទាមទារឯករាជ្យពីបារាំង ប្តឹងប្តល់ឈ្នះសៀមរឿងប្រាសាទព្រះវិហារឆ្នាំ ១៩៦២ ។ ទ្រព្យសម្បត្តិរបស់ព្រះអង្គបើប្រៀបធៀបជាមួយនឹងព្រះមហាក្សត្រនៅលើពិភពលោក គឺតិចជាងគេឆ្ងាយណាស់ ។

ការប្រកាសទ្រព្យសម្បត្តិរបស់អតីតព្រះមហាក្សត្រនេះ ទំនងព្រះអង្គចង់ដាស់តឿនដល់អ្នកដឹកនាំទាំងអស់ឱ្យហ៊ានបង្ហាញពីទ្រព្យសម្បត្តិរបស់ខ្លួន មុនពេលចូលកាន់ដំណែង និងក្រោយពេលចាកចេញពីការងារចៀសវាងការទិទៀនពីមហាជន ។

ទាក់ទិននៅនឹងច្បាប់ប្រកាសទ្រព្យសម្បត្តិនេះ អង្គការសង្គមស៊ីវិល និងក្រុមគណបក្សប្រឆាំងបានបញ្ជូនច្បាប់ទៅរដ្ឋសភាឱ្យអនុម័តជាយូរមកហើយ ប៉ុន្តែរហូតមកដល់ពេលនេះ មិនទាន់ចេញជាផ្លែផ្កានោះទេ ។

លោក យឹម សុវណ្ណ តំណាងរាស្ត្រគណបក្សសម រង្ស៊ី បានមានប្រសាសន៍ជាសារធារណៈថា គណបក្សលោកក៏ដូចជាខ្លួនលោកផ្ទាល់ ចង់ឱ្យមានច្បាប់នេះ ចៀសវាងកុំឱ្យមានការចោទប្រកាន់ពីមហាជន ។ ទង្វើរបស់អតីតព្រះមហាក្សត្រនេះល្អណាស់ គួរតែអ្នករាជការយើងរៀនសូត្រតាម ។

ចំណែកអ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាភាគច្រើនលើសលប់សុទ្ធតែមានទ្រព្យសម្បត្តិស្តុកស្តម្ភ លុយចាយវាយមិនអស់ ផ្ញើនៅធានាគារក្នុង និងក្រៅប្រទេស ។ អ្នកខ្លះ ទៀតលុយច្រើនពេកទៅទិញដីលាងលុយកខ្វក់បិទបាំងអំពើពុករលួយបានចំណេញពីដីមួយជាន់ទៀត ។

ជាឧទាហរណ៍ ទណ្ឌិត ហេង ពៅ អតីតស្នងការប៉ូលិសក្រុងភ្នំពេញ កូតាគណបក្សប្រជាជនកម្ពុជា ដែលប្រើអំពើឃោរឃៅ ចាប់ជំរិតអ្នកស្រុកយកលុយ មានផ្ទះវីឡា៣-៤កន្លែង និងលុយផ្ញើនៅធានាគារប្រមាណជិត១លានដុល្លារ ។

នេះគ្រាន់តែឋានៈត្រឹមស្នងការប៉ូលិសក្រុងភ្នំពេញ ចុះបើចៅហ្វាយក្រុង រដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី នាយករដ្ឋមន្ត្រីវិញ មានទ្រព្យសម្បត្តិច្រើនហូរហៀរយ៉ាងណាទៅ ?

តាមធម្មតាអ្នករាជការ មុនពេលចូលបំរើការងាររដ្ឋ មានរាងកាយស្គមស្គាំង ជិះម៉ូតូកញ្ចាស់ រស់នៅជាមួយបងប្អូន មានជីវភាព ខ្វះមុខ ខ្វះក្រោយ ។ ប៉ុន្តែបន្ទាប់ពីបំរើការងារ មានតួនាទីគ្រប់គ្រងស្ថាប័ន ក្រសួងមន្ទីរតែ ៤-៥ឆ្នាំ ស្រាប់តែមានផ្ទះធំទ្រនំខ្ពស់ ឡានថ្មីផ្លាស់ប្តូរជាញឹកញាប់ ហើយពួកគេតែងគេចវេះមិនចង់ប្រកាសពីទ្រព្យសម្បត្តិផ្ទាល់ខ្លួនជាសាធារណៈទេ ដោយសំអាងថា ខ្លាចបញ្ហាសន្តិសុខ ។

ជាញឹកញាប់មន្ត្រីរាជការ ក៏ដូចជាមន្ត្រីគណបក្សប្រជាជនកម្ពុជា ដែលមានឋានៈតួនាទីធំៗ សុទ្ធតែមានទ្រព្យសម្បត្តិហូរហៀរ ចាយវាយលែងអស់ ហើយពួកគេលែងចង់ឮ និងលែងចង់ឃើញច្បាប់ប្រឆាំងអំពើពុករលួយ ឬក៏ការប្រកាសទ្រព្យសម្បត្តិស្អីទេ គឺចង់តែធ្វើទីប្រឹក្សានាយករដ្ឋន្ត្រី ប្រធានរដ្ឋសភា និងព្រឹទ្ធសភា ធ្វើជាខ្នងបង្អែករកស៊ីប៉ុណ្ណោះ ៕

## (តមកពីទំព័រទី០៣) គុកទួលស្លែងនឹងក្លាយជាសារមន្ទីរចងចាំ...



២១. ស៊ីម៉ន ចាប ~ ខ្ញុំប្រហែលជាបោះឱ្យ Obama អូបាម៉ា



២៣. ម៉ូរី គុជ ~ ខ្ញុំចូលចិត្ត អូបាម៉ា



២២. សិរិទ្ធិ សម ~ ដល់ថ្ងៃបោះឆ្នោតបានខ្ញុំសំរេចចិត្ត

### ការបរិច្ឆេទនៃការបោះឆ្នោត

**ពិន សំខុន**

* ថ្ងៃបោះឆ្នោតជ្រើសរើសប្រធានាធិបតីនៃសហរដ្ឋអាមេរិក ៤ វិច្ឆិកា ២០០៨

. ថ្ងៃឈប់ទទួលចុះឈ្មោះ ៦ តុលា ២០០៨

. ថ្ងៃឈប់ទទួលចុះឈ្មោះ ឆ្នោតអវត្តមាន ២៨ តុលា ២០០៨

. ថ្ងៃឈប់ឱ្យបោះឆ្នោតមានជម្រើស ៤ វិច្ឆិកា ២០០៨

នាថ្ងៃបោះឆ្នោតប្រធានាធិបតីនោះ ក៏មានការបោះឆ្នោត ក៏មានការបោះឆ្នោតឯទៀតៗដែរ ។

- អគ្គមេធាវី រដ្ឋផែនស៊ុវេនា
- អគ្គត្រួតពិនិត្យសម្បត្តិរដ្ឋ ផែនស៊ុវេនា
- អគ្គហិរញ្ញិក រដ្ឋផែនស៊ុវេនា
- តំណាង រដ្ឋផែនស៊ុវេនា និងព្រឹទ្ធសភា រដ្ឋផែនស៊ុវេនា ចំនួនពាក់កណ្តាល ។

នៅលើម៉ាស៊ីន ដែលពលរដ្ឋត្រូវបោះឆ្នោត ឱ្យបេក្ខជនប្រធានាធិបតីណាមួយនោះ អ្នកបោះឆ្នោតនឹងបានឃើញ បេក្ខជនក្នុងតួនាទីផ្សេងៗ ទៀត ដាក់នៅក្នុងបញ្ជីបន្តបន្ទាប់គ្នា ដែលអ្នកចូលបោះឆ្នោត ត្រូវជ្រើសរើសក្នុងពេលជាមួយគ្នា ៕



# គុកទួលស្លែងនឹងក្លាយជាសារមន្ទីរចងចាំរបស់ពិភពលោក

***ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : គឹម សារឿន***

●●●អគារសាលារៀនដ៏ខ្ពស់ចំនួន៤ខ្នង មានលួសបន្លាហ៊ុមព័ទ្ធពីខាងក្រៅ ដែលនៅខាងក្នុងមានចោះទម្លុះជាបន្ទប់សំរាប់ឃុំឃាំង ច្រវ៉ាក់ខ្នោះឃ្នាងឧបករណ៍ធ្វើទារុណកម្មរូបថតជនរងគ្រោះ និងឆ្អឹងលលាដ៏ក្បាលខ្មោចយ៉ាងច្រើនត្រូវបានគេធ្វើទារុណកម្មរួចទើបយកទៅសំលាប់ចោល ។


កាំ ហ្គេចអ៊ាវ ហៅ ឌុច មេគុក ទួលស្លែងឡើងសវនាការ








មន្ទីរឃុំឃាំងទូលស្លែងនេះ ត្រូវពួក ប៉ុល ពត យកមនុស្សម្នាពីគ្រប់មជ្ឈដ្ឋានមកធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ ហើយទើបវាសំលាប់ចោលក្នុងឆ្នាំ១៩៧៥-១៩៧៩ ។ បន្ទាប់ពីថ្ងៃរំដោះ៧មករាឆ្នាំ១៩៧៩ ទីនេះត្រូវបានអាជ្ញាធរខ្មែររៀបចំជាសារមន្ទីរប្រល័យពូជសាសន៍ទូលស្លែង ដើម្បីឱ្យភ្ញៀវទេសចរចំរុះជាតិសាសន៍បានទស្សនា និង ស្វែងយល់ពីអំពើឃោរឃៅរបស់ពួក ប៉ុល ពត កាន់អំណាច ។

សារមន្ទីរប្រល័យពូជសាសន៍ទូលស្លែង ដែលជាកន្លែងធ្វើទារុណកម្មជនរងគ្រោះរបស់ពួកខ្មែរក្រហមនៅទីក្រុងភ្នំពេញ ត្រូវបានមន្ត្រីជំនាញរៀបចំសំនុំឯកសារទៅអង្គការយូណេស្កូដាក់បញ្ចូលជាសារមន្ទីរចងចាំរបស់សាកលលោកនៅទីក្រុងប៉ារីសប្រទេសបារាំង ។

ការដែលកម្ពុជាស្នើសុំឱ្យដាក់បញ្ចូលអតីតគុកទូលស្លែងជាសារមន្ទីរចងចាំរបស់ពិភពលោកពីព្រោះជនរងគ្រោះក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ស្លាប់អយុត្តិធម៌ខ្លាំងណាស់ ហើយរឿងនេះ វាគួរតែឱ្យមនុស្សជាតិទូទាំងពិភពលោកបានដឹងពីការឈឺចាប់របស់ពលរដ្ឋខ្មែរនៅសម័យនោះ ។

ក្នុងបន្ទប់នៃអគារទាំង៤ គេសង្កេតឃើញមានសេសសល់ភស្តុតាងមួយចំនួនដូចជា ដង្កាប ធុងអាគុយសំរាប់ធ្វើទារុណកម្មដោយចរន្តអគ្គិសនី បន្ទប់តូចៗសំរាប់សួរចំលើយមានដែកគាស់មួយប្រឡាក់ដោយឈាមនៅខាងចុងចប ប៉ែល ខ្នោះដៃ ខ្នោះជើង ច្រវ៉ាក់ សំរាប់រឹតដៃជើងអ្នកទោសសួរចំលើយ ។

ក្រៅពីនោះ មានរូបថតអ្នកទោសគ្រប់វ័យដែលមានសរសេរឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងមូលហេតុនៃការចាប់ខ្លួន ហើយមានការចុះបញ្ជីឈ្មោះដែលប្រព្រឹត្តទៅហ្មត់ចត់ណាស់ ។ នៅក្នុងបន្ទប់គេឃើញអ្នកទោសខ្លះត្រូវពួកវាវះពោះកាត់ក្បាល ខ្លះចងជើងឡើងលើទំលាក់ក្នុងពាងលាមក និងអ្នកទោសខ្លះទៀតត្រូវបានពួកវាធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ ។

អ្នកស្លាប់នៅក្នុងគុកទូលស្លែងពិតជាទទួលរងនូវទារុណកម្មធ្ងន់ធ្ងរណាស់ គេក៏បានយកលលាដ៏ក្បាល ឆ្អឹងមកតម្រៀបគ្នាធ្វើជាផែនទីប្រទេសកម្ពុជា ដែលមើលទៅគួរឱ្យញាក់សាច់ខ្លាំងណាស់ ។

មន្ទីរឃុំឃាំងទូលស្លែង ឬមន្ទីរស.២១នេះ ពួកខ្មែរក្រហមបានប្រើប្រាស់យុទ្ធសាស្ត្រផ្សេងៗហៅនិស្សិត បញ្ញាវន្តទាំងក្នុង និងក្រៅប្រទេសយកមកធ្វើទារុណកម្ម និងសំលាប់ចោលយ៉ាង

(តទៅទំព័រទី១១)

ខ្មែរប៉ុស្តិ៍មានសេចក្តីរីករាយ នឹងណែនាំដល់សហគមន៍ខ្មែរ




ឱសថស្ថានយើងនឹងជួយលោកអ្នកអំពីតម្លៃថ្នាំ ជាពិសេសដល់គ្រួសារដែលមានប្រាក់ចំណូលតិច

ឱសថស្ថានយើងខ្ញុំនឹងទូរស័ព្ទ ហើយធ្វើការជាមួយវេជ្ជបណ្ឌិត នឹងក្រុមហ៊ុនធានារ៉ាប់រងសុខភាព លោកអ្នកនឹងទទួលបានថ្នាំរបស់លោកអ្នកជាប្រាកដ

ឱសថស្ថាន Washington បានជួយអ្នកជំងឺរាប់ពាន់នាក់ នៅក្នុងសហគមន៍ ស្រាយបញ្ហាស្មុគស្មាញ ដើម្បីឱ្យបានឱសថដែលអ្នកទាំងនោះត្រូវការ ។

និយាយនិងពន្យល់អំពីថ្នាំ ជាភាសាខ្មែរ

លឿនរហ័ស :
ចាំ ១០ នាទី ឬយកទៅឱ្យដល់ផ្ទះ

600 Washington ave, Unit 18E Phila, PA - phone: 215-755-5100

## (តមកពីទំព័រទី០៥) គុកទួលស្លែងនឹងក្លាយជាសារមន្ទីរចងចាំ...

ការដឹកនាំជាតិមាតុភូមិ និងបានធ្វើការស្រាវជ្រាវឃើញភាពមិនប្រក្រតីយ៉ាងច្រើនបន្ទាប់ពីបោះឆ្នោតរួច ។

គណបក្សប្រឆាំងទាំងពីរនេះ បានដាក់ពាក្យបណ្តឹងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងក្រុមប្រឹក្សាធម្មនុញ្ញ ទាំងគ្មានសង្ឃឹម ហើយត្រូវបានស្ថាប័នទាំងនេះច្រាន



ឯកសារក្លែងក្លាយ ដែលមេឃុំ-មេឃុំ ចេញឱ្យអ្នកស្រុកប្រើនៅថ្ងៃបោះឆ្នោត

ចោល និងបិទផ្លូវតវ៉ារាល់ករណីបណ្តឹង ។ ទីបំផុតគណបក្សទាំងពីរក៏បានធ្វើសន្និសីទកាសែតរួមគ្នាប្រកាសមិនចូលរួមប្រជុំរដ្ឋសភាលើកដំបូង ហើយបញ្ជូនភស្តុតាងទាំងនេះឱ្យសហគមន៍អន្តរជាតិជួយរកយុត្តិធម៌ចំពោះប្រជាពលរដ្ឋខ្មែរដែលមិនបានបោះឆ្នោត ។

ក្នុងសន្និសីទរួមគ្នាកាលពីថ្ងៃទី២៥ ខែសីហាកន្លងមក នៅឯទីស្នាក់ការគណបក្ស សម រង្ស៊ី នោះ លោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស បានឱ្យដឹងថា គណបក្សសិទ្ធិមនុស្សមានផែនការចូលរួមធ្វើពហិការមិនចូលរួមសម័យប្រជុំសភាលើកទី១ ថ្ងៃទី២៤ ខែកញ្ញាខាងមុខ ប្រសិនបើភាពមិនប្រក្រតីទាំងឡាយរបស់គណបក្សប្រឆាំងមិនត្រូវបានដោះស្រាយតាមច្បាប់នោះ ។

លោក កឹម សុខា បានបន្តថា ភាពមិនប្រក្រតីនៃការបោះឆ្នោតមានទំហំធំខ្លាំងណាស់ គឺប្រជាពលរដ្ឋភាគច្រើនត្រូវបានគេលប់ឈ្មោះមិនបានបោះឆ្នោត ហើយលោករកបានភស្តុតាងច្រើនណាស់សំរាប់បញ្ជាក់ពីភាពមិនប្រក្រតីនេះ ។

ជាឧទាហរណ៍នៅខេត្តកំពង់ចាម គណបក្សសិទ្ធិមនុស្សខ្វះតែ៧៥០សំឡេងត្រូវបាន១អាសនៈទៀត ពេលនេះមានសកម្មជនរបស់លោកជាង ២០០០នាក់ បានដាក់ពាក្យថា មិនបានបោះឆ្នោត ។

ប្រធានគណបក្សសិទ្ធិមនុស្សបានបញ្ជាក់ថា អាសនៈចំនួន៩០ ដែលគណបក្សប្រជាជនកម្ពុជាទទួលបាន គួរតែបានទៅគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សមួយចំនួន ពីព្រោះអាសនៈរបស់គណបក្សប្រជាជនកម្ពុជាវាមិនពិតប្រាកដទេ គឺកើតចេញពីការក្លែងបន្លំ ។ ដូច្នេះគណបក្សលោកក៏ដូចជាគណបក្ស សម រង្ស៊ី មិនអាចចូលរួមប្រជុំជាមួយក្រុមតំណាងរាស្ត្រក្លែងក្លាយបានទេ ហើយគណបក្សយើងទាំងពីរនឹងរួមគ្នាធ្វើការទាមទារឱ្យខានតែបាន ។

លោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី បានមានប្រសាសន៍ថា ភាពមិនប្រក្រតីជាច្រើនដែលគណបក្សរកឃើញនៅក្រោយពេលបោះឆ្នោតដូចជា លប់ឈ្មោះប្រជាពលរដ្ឋចេញពីបញ្ជីអ្នកបោះឆ្នោត មិនមានភាពត្រឹមត្រូវ អ្នកខ្លះមានឈ្មោះបោះឆ្នោតត្រូវគេលួចបោះជំនួស អ្នកខ្លះទៀតមានលិខិតស្នាម តែគេមិនអនុញ្ញាតឱ្យបោះឆ្នោត និងការចេញទំរង់១០១៨ ខុសច្បាប់ឱ្យជនបរទេស អ្នកខ្លះមិនគ្រប់អាយុ និងឈ្មោះខ្មោចឱ្យបោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា ។

លោកប្រធានគណបក្ស សម រង្ស៊ី បានបន្តថា ភាពមិនប្រក្រតីបានកើតមានពាសពេញផ្ទៃប្រទេស ហើយយើងបានប្តឹងទៅ គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញឱ្យដោះស្រាយ ប៉ុន្តែត្រូវបានស្ថាប័នទាំងពីរច្រានចោល បិទផ្លូវតវ៉ាកាលពីថ្ងៃទី២៥ ខែសីហា ។ ទង្វើរបស់ស្ថាប័នទាំងពីរនេះយើងគ្មានជំនឿទេ ប៉ុន្តែយើងចង់ឱ្យមហាជនសហគមន៍ជាតិ-អន្តរជាតិដឹងថា ស្ថាប័នទាំងនេះស្ថិតនៅក្រោមគំនាបរបស់គណបក្សប្រជាជនកម្ពុជា ។

លោកប្រធាន សម រង្ស៊ី បានបន្តទៀតថា ពេលនេះយើងគ្រាន់តែតវ៉ាឱ្យមានការបោះឆ្នោតនៅខេត្ត-ក្រុងចំនួន៣ ដែលមានភាពមិនប្រក្រតីខ្លាំង គឺខេត្តស្វាយរៀង, កំពត, និងខេត្តពោធិ៍សាត់ ក្នុងខេត្តនីមួយៗ គឺខ្វះតែប៉ុន្មានរយសំឡេងប៉ុណ្ណោះ ។ អ្នកដែលមិនបានបោះឆ្នោតទាំងនោះបានធ្វើការតវ៉ាសុំសិទ្ធិបោះឆ្នោត ដែលភាគច្រើនជាអ្នកគាំទ្រគណបក្សប្រឆាំង ។

លោក សម រង្ស៊ី បានបញ្ជាក់ថា គណបក្សប្រជាជនកម្ពុជា បានប្រើប្រាស់វិធីក្នុងការលួចប្លន់សន្លឹកឆ្នោត ប្លន់សិទ្ធិសេរីភាពប្រជាពលរដ្ឋមិនឱ្យបោះឆ្នោត មិនអស់ចិត្តគេចង់បន្លំកៅអីរបស់គណបក្សយើងទៀត នេះជារឿងអយុត្តិធម៌ខ្លាំងណាស់សំរាប់ប្រជាពលរដ្ឋខ្មែរបច្ចុប្បន្ន ។

មេដឹកនាំនៃគណបក្សទាំងពីរបានបញ្ជាក់ថា ពេលនេះយើងមានភស្តុតាង ស្នាមមេដៃ និងពាក្យបណ្តឹងទាក់ទងទៅនឹងភាពមិនប្រក្រតីនេះរាប់ម៉ឺន ហើយយើងបានសរសេរលិខិតទៅកាន់ប្រធានាធិបតីបារាំង និងប្រធានាធិបតីឥណ្ឌូណេស៊ី សហប្រធានសន្និសីទទីក្រុងប៉ារីស ។ បន្ទាប់មកទៀត យើងនឹងធ្វើដំណើរទៅកាន់ទីក្រុងញូវយ៉ក ដើម្បីប្តឹងអង្គការសហប្រជាជាតិសហគមន៍អន្តរជាតិឱ្យជួយរកយុត្តិធម៌ជូនប្រជាពលរដ្ឋខ្មែរ ដែលត្រូវគេឆក់ប្លន់សិទ្ធិសេរីភាព ។

ក្នុងបណ្តឹងរបស់គណបក្សទាំងពីរបានចោទប្រកាន់គណបក្សប្រជាជនកម្ពុជា និង គ.ជ.ប ដែលគ្រប់គ្រងដោយ CPP ពីបទលប់ឈ្មោះអ្នកបោះឆ្នោតរាប់រយពាន់នាក់ ដែលគាំទ្រគណបក្សប្រឆាំងចេញពីបញ្ជី រក្សាឈ្មោះខ្មោចរាប់ពាន់នាក់ដើម្បីបង្កើនសន្លឹកឆ្នោតក្លែងក្លាយ ។

ការបោះឆ្នោតក្លែងក្លាយបែបនេះរំលោភលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលបានអំពាវនាវឱ្យប្រទេសកម្ពុជាបោះឆ្នោតតាមពេលវេលាមិនក្លែងក្លាយ គោរពសិទ្ធិមនុស្ស ។ ប្រទេសហត្ថលេខីទាំងនេះមាន ប្រទេសសហគមន៍អាស៊ាន, ចិន, ជប៉ុន, អង់គ្លេស, អូស្ត្រាលី, អាមេរិក ផងដែរ ។

នាយករដ្ឋមន្ត្រីខ្មែរស្របច្បាប់ ហ៊ុន សែន អាណត្តិទី៣នៅឯព្រលានយន្តហោះអន្តរជាតិភ្នំពេញ ក្នុង ឱកាសជូនដំណើរសម្តេចឪសម្តេច ម៉ែ និងព្រះ មហាក្សត្រ នរោត្តម សីហនុ កាលពីដើមខែ សីហា កន្លងមកនេះ បានព្រមានលោក សម រង្ស៊ី ថា បើគណបក្សប្រឆាំងមិនចូលរួមប្រជុំ សភាលើកទី១ទេ អាសនៈនេះនឹងយកទៅបែងចែកឱ្យគណបក្សដទៃទាំងអស់ ។

ហ៊ុន សែន បានបញ្ជាក់ទាំងកំហឹងថា អ្នកឯងកុំយកមាត្រាទី៧៦ នៃរដ្ឋធម្មនុញ្ញមករារាំងសភាឱ្យសោះ ត្រង់អ្នកឯងទទួលស្គាល់លទ្ធផលបោះឆ្នោត ឬអត់នោះ យើងមិនដឹងទេ គឺនៅថ្ងៃទី២៤ ខែកញ្ញា ត្រូវតែចូលរួមប្រជុំ ខ្ញុំនិយាយហើយនិយាយទៀត អ្នកឯងចាំតែមើលចុះ ។

បើតាមរដ្ឋធម្មនុញ្ញត្រង់មាត្រាទី៧៦ បានចែងថា រដ្ឋសភាដែលប្រជុំលើកដំបូងត្រូវមានសមាជិកយ៉ាងតិច១២០រូប ក្នុងចំណោមសមាជិកទាំង១២៣រូប ទើបអាចប្រកាសពីសុពលភាព

(តទៅទំព័រទី១០)


# ចង់ចេញពីភាពទ្រុឌទ្រោម? RELIV អាចប្តូររូបរាងកាយឱ្យមាំទាំបាន



Dr. Earleen Ong, Fellow of Geriatric Medicine, Certified Family Physician

Dr. John Harold Ong, Orthomolecular Medicine, Associate of Geriatric Medicine

"Nutrition has its role in medicine. There should never be a competition between supplementation and medication," says Dr. John Harold Ong. "Today's patients appreciate the idea that they have a big part in helping themselves. Reliv offers a holistic approach that is appealing and effective."

The Ongs knew from their own results with migraines and fatigue, and their daughter's results with developmental delays, that Reliv had a place in their practice. "Once we started recommending Reliv to our patients, we were amazed with the number of people who started calling us to refer their friends and relatives," Dr. Ong says.

"If nutrition is just given its rightful place in the mindset of most doctors, many patients will benefit without the fear of side-effects and adverse reactions now commonly experienced by so many."

**Reliv: Nutrition for the 21st Century**

Today's modern processing techniques rob essential nutrients from much of our food. Reliv restores the balance by delivering a unique blend of the vitamins, antioxidants, minerals, proteins, amino acids and phytonutrients the body needs to restore energy, fight off infections and feel great — every day.




The Reliv scientists formulate the most recent nutrition research into products that scientifically advance, nutritionally complete, and is proven to restore the boby functions.

- ពិសារ Reliv រាល់ថ្ងៃ គឺនាំឱ្យមានកម្លាំងកាយ រូបរាងមាំមួន សម្ផស្សស្រស់បស់ឡើងបាន
- Reliv អាចទប់ស្កាត់នូវជំងឺមួយចំនួនធំ ដែលកើតមកពីការពិសារចំណីអាហារខ្វះជីវជាតិ ធ្វើឱ្យសរីរាង្គគាំងដំណើរ
- ពិសារ Reliv លោក-អ្នកនឹងដឹងពីប្រសិទ្ធភាព ចាប់តាំងពីថ្ងៃដំបូង ដែលលោក-អ្នកប្រើ Reliv នេះភ្លាម ។

សូមទូរស័ព្ទជាវនៅលេខ : (636) 537 9715

. ដោយផ្តល់លេខសំគាល់ : RNC .7070 438001

បញ្ជាទិញ 1. RELIV CLAASIC មួយកំប៉ុង

2. Reliv INNERGINE មួយកំប៉ុង ដែលជាចំណីជីវជាតិ

លាយ RELIV 1 និង RELIV 2 ម្នាងមួយស្លាបព្រាក្នុងទឹកផ្លែឈើហើយពិសារម្តង ឬពីរដងក្នុងមួយថ្ងៃ ទៅតាមភាពទ្រុឌទ្រោមនៃរូបរាងកាយ

" ភាពរឹងមាំកើតឡើងស្ទើរជឿមិនបាន "

មួយវិញទៀត : នៅពេលឃើញប្រសិទ្ធភាពនៃ Reliv លោកអ្នកនឹងមានជំនឿថា អាចចែកចាយឱ្យមនុស្សច្រើនទៀតបាន សូមទាក់ទងមកយើងខ្ញុំ ដើម្បីចុះឈ្មោះជា RELIV DISTRIBUTOR បន្តទៅទៀត លោកអ្នកអាចនឹងចំណេញប្រាក់ច្រើន ដោយសារតែបានជួយអ្នកដទៃឱ្យមានសុខភាពល្អដូចលោកអ្នកបាន

ទូរស័ព្ទនៅ Philadelphia :(267) 254 8758 នៅ VIRGINIA 703 415-6257

WWW.RELIV.COM

# កម្មវិធី " ពីក " PEAK នៅតំបន់ហ្វីឡាដែលហ្វៀខាងជើង

**ខ្មែរប៉ុស្តិ៍**



សិក្សាអំពី "គ្រឿងញៀន និងសុរា " របស់កម្មសិក្សាការី ជាអ្នកថែទាំកុមារ នាថ្ងៃព្រហស្បតិ៍ ទី១៧ កញ្ញា នេះ គឺជាកម្មវិធីបង្កើនថាមពលដល់មាតាបិតាខ្មែរ ក្នុងការអប់រំកូនចៅ នៅបរិវេណសាលា E3 Center របស់សមាគមព្យាបាលជម្ងឺសសៃប្រសាទ MHASP នៅហ្វីឡាដែលហ្វីយ៉ាខាងជើង ។

កម្មសិក្សាការី ២៣នាក់ នៅតំបន់ឡូហ្គិនអលនី បានទទួលការពន្យល់ និងឆ្លើយសំនួរជាច្រើនពីនាយប៉ូលិសក្រុង ស្តីពីឥទ្ធិពលញូនៃគ្រឿងញៀន នៃសុរា មានជាអាទិ ការចាក់ខ្សែភាពយន្តបង្ហាញពីឃាតករដែលសាហាវជាងគេ គឺបារីបន្ទាប់មកសុរា ជាឃាតករទីពីរ ហើយបន្តមកទៀត រូបភាពនៃអាភៀនគ្រប់ធុន គ្រប់រូបភាពរាប់ទាំងថ្នាំទាំងឡាយ ដែលទទួលបានដោយស្របច្បាប់ តែអ្នកប្រើបែរជារំលោភវា ដោយប្រើលើសកម្លាំង បានក្លាយជាគ្រឿងញៀនដ៏សាហាវទៅវិញ ។ រូបភាពនៃយុវជនក្មេងៗដែលបាននជ្រើសរើស មាគ៌ាដ៏អាក្រក់សំរាប់ជីវិតរបស់ពួកគេ បានត្រូវបង្ហាញរូបរាងទ្រុឌទ្រោមក្នុងរយៈពេលដ៏ខ្លី ខ្លះក៏បានត្រូវបញ្ចប់ជីវិតយ៉ាងទាន់ហន់ ហើយខ្លះទៀតក៏ត្រូវបណ្តាញតុលាការដាក់គុករហូតដល់អស់ជីវិត ។

នេះជាកម្មវិធីថ្ងៃទី៣ ក្នុងចំណោមកម្មវិធី ៨ថ្ងៃ ដែលមានជាបន្តបន្ទាប់ ដូចជាជួបគ្នាជាមួយនឹងអ្នកឯកទេសខាងជម្ងឺផ្លូវចិត្ត ដែលសម្បូរកើតនៅក្នុងសហគមន៍ ដែលទើបមករស់នៅលើដែនដីថ្មី បញ្ហាកម្មវិធីអប់រំពិសេសចំពោះកុមារ ឬយុវជន ដែលពិបាកនឹងទទួលចំណេះការជួមជាមួយអង្គការធនធានមនុស្ស ដែលសហគមន៍ខ្មែរ ស្គាល់ថា " DHS " ឌី អេច អេស ឬអង្គការដែលដកកូនចៅចេញ ពីការគ្រប់គ្រងរបស់ម្តាយឪពុក ដែលគ្មានសមត្ថភាព... ។ល ។ យោងតាមសេចក្តីត្រូវការរបស់សហគមន៍ខ្មែរ ដែលចេះតែខ្សត់ខ្សោយ គ្មានពន្លឺនៃអនាគតនោះ កម្មសិក្សាការី បានសំដែងការទទួលយកកម្មវិធីនេះ ថាមានសារៈសំខាន់ណាស់ គួរតែសមាគមន៍ខ្មែររៀបចំពួកដៃគ្នា ការពារកូនចៅឱ្យបានខ្លាំងក្លាឡើង វាគ្មិនម្នាក់ទៀត បានបោកបង្ហាញកញ្ចក់ប្រាក់ដែលចែកជូនសំរាប់ជួលឱ្យគេមើលកូនឱ្យ ហើយឧទ្ទានថា " មើលនែ៎សមាគមនេះ ចាយប្រាក់ច្រើនណាស់ ដើម្បីចង់យើងបានចេះការពារកូនចៅ យើងគួរនាំគ្នាចូលរួមឱ្យបានច្រើន ហើយពួតដៃគ្នាកែរសង្គមយើងឡើងវិញ ! " ៕

# (តមកទំព័រទី០១) រៀបចំចូលភ្ជុំបិណ្ឌនៅហ្វីឡាដែលហ្វៀ...

នៅថ្ងៃអាទិត្យ ទី២៨ ថ្ងៃច័ន្ទ ទី២៩ និងថ្ងៃអង្គារ ទី៣០ ក្នុងរូបភាពជា បុណ្យធំប្រចាំឆ្នាំ ។

នៅថ្ងៃកាន់បិណ្ឌទី៣ សមាគមខ្មែរ បានចាប់កុសលជាមួយសមាជិកសមាជិការបស់ខ្លួន យកវត្តព្រះពុទ្ធរង្សី ជាទីប្រារព្ធពិធី នាល្ងាចថ្ងៃពុធ ទី១៧ កន្លងទៅនេះ ។



លោក សរិត សំ ប្រធានសមាគមខ្មែរ ថ្លែង អំណរគុណចំពោះភ្ញៀវ នៅចំពោះព្រះតំរុយព្រះ សង្ឃវត្តព្រះពុទ្ធរង្សី

នៅថ្ងៃជាមួយគ្នានោះដែរ នៅវត្តសុរិយារង្សី ឬវត្តខាងជើងវិញ សមាគមសំខាន់មួយទៀត នៅហ្វីឡាដែលហ្វៀ នេះ ក៏រៀបចំកាន់បិណ្ឌដូចគ្នាដែរ គឺសមាគមវិបស្សនា នៅហ្វីឡាដែលហ្វីហ្វៀ



ក្រុមវិបស្សនា ស្តាប់ព្រះសង្ឃទេសនា នាឱកាស កាន់បិណ្ឌទី៣ នៅវត្តសុរិយារង្សី

បុណ្យភ្ជុំបិណ្ឌនេះ ជាបុណ្យប្រពៃណី ដែលគេជឿថា ព្រលឹងអ្នកមានគុណខ្លះ បានប្រព្រឹត្តអំពើបាប ត្រូវចុះនរកនៅពេលស្លាប់ទៅ ។ នាឱកាសបុណ្យភ្ជុំបិណ្ឌនេះ ក្រុមយោមបាល បានដោះលែងឱ្យប្រេតឋាន-នរកមកទទួលចំណីអាហារ ដែលកូនចៅធ្វើបុណ្យដាក់ទៀនបញ្ជូនកុសលទៅឱ្យពួកប្រេតទាំងនោះ ។ ហេតុដូច្នេះ បានជាកូនចៅ ឬក្រុមគ្រួសារមានភារកិច្ចត្រូវទៅវត្តប្រគេនចង្ហាន់ដាក់ទាន ដើម្បីឧទ្ទិសកុសលទាំងនោះ អាចបញ្ជូន ទៅដល់ពួកប្រេត ដែលជាសាច់ញាតិ និងជាអ្នក មានគុណរបស់ពួកគេ ៕


## Washington Wellness Care មន្ទីរថែរក្សាខ្លួនប្រាណ "វ៉ាស៊ីនតុន"

Medical & Rehab.

ដោយវិជ្ជាពេទ្យ និងការបង្ហាត់រាងកាយឱ្យដើរឡើងវិញ

Medical & Rehab.
500 Washington Ave., 1st Fl.
Philadelphia, Pa 19147
Phone: 215.551.6838. Fax: 215.551.6718

**Dr. Scott C. Tran, D.C. Dr. Michael Barno, D.C. Dr. Zohar Stark, M.D.**

***We are specialized in treating:***

- Auto Accident Injuries - Work Related Injuries - Slip & Fall Injuries

**យើងមានជំនាញក្នុងការព្យាបាល :**

☞ របួសដោយគ្រោះថ្នាក់រថយន្ត ☞ របួសដោយទាក់ទងនឹងកន្លែងធ្វើការ ☞ របួសដោយរអិល ឬដួល

We have staffs who speaks Vietnamese, Chinese, and Cambodian
For Cambodian and Vietnamese Speaking Staff, please call Ricky Son at 215.380.1350
For English Speaking Staff, please call 215.551.6838

**យើងមានបុគ្គលិកដែលនិយាយភាសា វៀតណាម, ភាសាចិន , នឹងភាសាខ្មែរ**

ទាក់ទងជាមួយបុគ្គលិកខ្មែរ និងវៀតណាម សូមទូរស័ព្ទទៅ រីគី សុន **(215) 380-1350**

ទាក់ទងទៅបុគ្គលិកនិយាយភាសាអង់គ្លេស សូមទូរស័ព្ទទៅ **(215) 551-6838**

# អ្នកស្រុកនាំគ្នាស្រែកយំទាមទារយកដី

*ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : ចាន់ កុសល*

●●●ក្រោមរូបភាពតំបន់អភិវឌ្ឍន៍ការផ្ដល់ដីសម្បទានរដ្ឋឱ្យទៅក្រុមហ៊ុនមិនបានពិនិត្យឱ្យបានល្អិតល្អន់ និងទទួលបានលាភសក្ការៈផងនោះ ប្រជាពលរដ្ឋទាំងនៅទីក្រុង និងជនបទដាច់ស្រយាលមួយចំនួន ត្រូវបានគេបណ្ដេញចេញពីលំនៅឋាន និងដកហូតយកដីស្រែចំការរបស់ខ្លួន

តុលាការ

និងអ្នកខ្លះទៀតបានលើកគ្នាទៅដល់ផ្ទះនាយករដ្ឋមន្ត្រី ហ៊ុន សែន ឱ្យជួយអន្តរាគមន៍ ។ ប៉ុន្តែលទ្ធផលដែលពួកគាត់ទទួលនោះ គឺទឹកភ្នែកសំរែកនៃការឈឺចាប់លាន់ឮស្ទើរគ្រប់វិនាទី ហើយក្នុងចំណោមពួកគាត់ដែលធ្វើការតស៊ូស្រួចស្រាល់ ត្រូវពួកឈ្មួញឃុបឃិតជាមួយ

ជាផ្លូវការផង

សង្គ្រាមដីធ្លីបានផ្ទុះឡើងស្ទើរ គ្រប់កន្លែងដែលមានទ្រង់ទ្រាយកាន់តែធំ ធ្វើឱ្យកសិករត្រូវបាត់បង់លំនៅឋាន ដីស្រែចំការយ៉ាងអយុត្តិធម៌ ។ ទង្វើដ៏សាហាវគ្មានច្បាប់ទំលាប់នេះ វាផ្ដើមចេញពីអ្នកមានលុយ មានអំណាចឃុបឃិតជាមួយអាជ្ញាធរមូលដ្ឋាន ក្រោម

ឱ្យផ្អិបសំណុំរឿងនោះ

។ ម្យ៉ាងទៀត ដោយសារតែអំណាចទឹកប្រាក់ជាញឹកញាប់ តុលាការបានកាត់ឱ្យអ្នកស្រុកចាញ់ និងគំរាមចាប់អ្នកណាដែលចេញមុខប្រឆាំងដាក់គុក ឬដុតផ្ទះសំបែងចោលទៀតផង ។

ពួកឈ្មួញមានលុយបានឃុតឃិតគ្នារត់ការ



ប្រជាពលរដ្ឋរស់នៅតំបន់ដីក្រហម នាំគ្នាមកតវ៉ានៅមុខរដ្ឋសភា



ប្រជាពលរស់នៅតំបន់បឹងកក់ នាំគ្នាមកតវ៉ានៅមុខសាលាក្រុង

ដែលធ្លាប់កាន់កាប់ជាច្រើនឆ្នាំយ៉ាងអយុត្តិធម៌ ។

ពលរដ្ឋខ្មែរដែលត្រូវគេឆក់ប្លន់យកដីធ្លីរបស់ខ្លួនទាំងនោះ បានស្ទុះស្ទាទៅប្ដឹងអាជ្ញាធរមន្ត្រី

តុលាការចាប់ដាក់គុកបំបាក់ស្មារតីមិនឱ្យអ្នកផ្សេងបន្តការទាមទារ ។

ក្រោយពីបោះឆ្នោតមិនទាន់ប្រកាសលទ្ធផល


# ភោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)

## Nam Vang Restaurant

571 Unit # 1 Adams Avenue. Philadelphia, Pa 19120

(inside Hong Kong Market)

**(215) 742-9488**

Open 7 days a week from 9 a.m. – 9 p.m.

**បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច**



**១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជា:**

- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្ទាំង ឆាសាច់គោ
- មីកន្ទាំងឆាគ្រឿងសមុទ្រ
- បាយឆាគ្រប់មុខ
- សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង

**២_មុខជំនាញម្ហូបវៀតណាមឈ្ងុយឆ្ងាញ់ ដូចជា:**

- នំបញ្ចុកទឹកត្រីពិសេស
- នំប៉័ងបាតេ ឬសាច់គោអាំង
- ខគោ នំប៉័ង ឬមី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង

រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់រស់ជាតិផ្លែឈើ ដូចជា : ទុរេន ឬ អាវូកាដូ ហើយជាពិសេស មានទឹកអំពៅកិនស្រស់ៗ


រូបភាពតំបន់អភិវឌ្ឍន៍ និងយកដីសម្បទានឱ្យក្រុមហ៊ុនបរទេសជាថ្នូរនឹងលាភសក្ការៈសំរាប់បក្ខពួកក្រុមគ្រួសាររបស់ខ្លួន ។

ជនរងគ្រោះនៅតំបន់ខ្លះដែលត្រូវពួកក្រុមហ៊ុន និងអាជ្ញាធរឃុបឃិតគ្នាឆក់ប្លន់យកដីពួកគាត់នោះ គេឱ្យសំណងផ្លូវចិត្តបន្តិចបន្តួច គឺពី២០០០ទៅ៣០០០ដុល្លារប៉ុណ្ណោះ ដែលដីរបស់ពួកគាត់ធ្លាប់រស់នៅជាង២០ឆ្នាំ និងមានតំលៃរាប់សែនដុល្លារឯណោះ ។

មិនថាតែអ្នកទីក្រុងភ្នំពេញទេ ដែលរងគ្រោះក្នុងអំពើឆក់ប្លន់ដីធ្លីនោះ សូម្បីតែពួកព្នងរស់នៅតាមព្រៃភ្នំក្រំថ្ម ក៏ត្រូវអ្នកមានអំណាចរំលោភបំពានយកដីធ្លីរបស់ពួកគាត់ដែរ ។ ជនរងគ្រោះទាំងនេះបានប្រឹងប្រែងអសលទ្ធភាព តាមរយៈក្បួនបាតុកម្មតវ៉ាប្ដឹងទៅអាជ្ញាធរតុលាការ តវ៉ានៅមុខរដ្ឋសភា និងផ្ទះ ហ៊ុន សែន ។ ទីបំផុតពួកគាត់ក៏រត់ឱ្យខាងអង្គការសិទ្ធិមនុស្ស និងអ្នកសារព័តិមានជួយ ប៉ុន្តែអ្វីដែលពួកគាត់ខំសង្ឃឹមទុកនោះក៏នៅតែមិនដូចបំណងទៀត គឺមានតែស្រែកយំដើម្បីឱ្យធូរស្បើយក្នុងអារម្មណ៍តែប៉ុណ្ណោះ ។

ការអភិវឌ្ឍក្រោមសំរែកទួញយំសោកសៅ និងការជេរដាក់បណ្ដាសារបស់ប្រជាពលរដ្ឋ គ្រប់ទិសទីនោះ គេសង្កេតឃើញអាជ្ញាធរនៅតាមមូលដ្ឋានបណ្ដេញអ្នកស្រុកចេញពីលំនៅឋាន និងដកហូតយកដីកម្មសិទ្ធិរបស់ពួកគាត់ទៅឱ្យក្រុមហ៊ុនសង់ផ្ទះល្វែងលក់ ឬឱ្យក្រុមហ៊ុនធ្វើរបងហ៊ុំព័ទ្ធត្រៀមបង្កើតរោងចក្រចែកផលប្រយោជន៍គ្នា ។

ទំនាស់ដ៏ស្រួចស្រាវរវាងប្រជាពលរដ្ឋ និងអាជ្ញាធរ ក្រុមហ៊ុននេះ នៅតំបន់ខ្លះកើតមានរយៈពេល១០ឆ្នាំ និងខ្លះទៀតរហូតដល់១៥ឆ្នាំ គឺនៅតែគ្មានដំណោះស្រាយ ដោយសារខាងក្រុមហ៊ុនគេមានលុយសូកប៉ាន់មន្ត្រីតុលាការ ឬអាជ្ញាធរ

ទៅទីស្ដីការគណៈរដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រី ដើម្បីយក ស.ជ.ណ ឬសុំចំណារយល់ព្រមរំលោភយកដីរបស់អ្នកស្រុកដោយស្របច្បាប់ ក៏ដូចជាការគំរាមបំបាក់ស្មារតីអ្នកស្រុកផងដែរ ។

នេះជាឧទាហរណ៍ទំនាស់ដីធ្លីក្រោយបោះឆ្នោតថ្ងៃទី២៧ ខែកក្កដា រវាងប្រជាពលរដ្ឋ និងក្រុមអ្នកមានលុយ មានអំណាចដែលធ្វើឱ្យអ្នកក្រីក្រធ្វើការប្ដឹងប្ដល់ស្រែកទាមទារឱ្យសមត្ថកិច្ចដោះស្រាយ ប៉ុន្តែការទាមទាររបស់អ្នកក្រហាក់ដូចជាគ្មានប្រសិទ្ធភាពសោះ ។

**-ខេត្តកំពង់ចាម :** ប្រជាពលរដ្ឋប្រមាណជាង៧០០គ្រួសារ នៅឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ដែលកាន់កាប់ដីទំហំជាង១៤០០ហិកតាតាំងពីសម័យសង្គមរាស្ត្រនិយម បាននាំគ្នាតវ៉ា៣លើក ហើយទៅឱ្យ ហ៊ុន សែន ជួយដោះស្រាយ ប៉ុន្តែគ្មានបានលទ្ធផលអ្វីទេ ។

លោក ស៊ា ទ្រចេង តំណាងប្រជាពលរដ្ឋរងគ្រោះបានឱ្យដឹងថា ដីដាំកៅស៊ូរបស់គាត់ត្រូវប៉ូលិសចំការកៅស៊ូបឹងកេតឈ្មោះ សុខ ប៊ុន្នី ដឹកនាំកំលាំងទៅដកដើមកៅស៊ូរបស់គាត់ទាំង២លើកអស់ជាង៨០០ដើម ។

លោកបានបញ្ជាក់ថា សមត្ថកិច្ចអត់បានការពារអ្នកស្រុកទេ គឺការពារតែពួកឈ្មួញ ហើយរិះរកល្បិចធ្វើបាបប្រជាពលរដ្ឋថែមទៀត ។ នៅថ្ងៃទី២០ ខែសីហា ដោយអស់ជំរើស ក៏ទៅប្ដឹងអង្គការសិទ្ធិមនុស្ស ឱ្យជួយរកយុត្តិធម៌វិញ ។

លោក សាន រី តំណាងឱ្យប្រជាពលរដ្ឋ៦គ្រួសារ ដែលមានដីទំហំ៧ហិកតា បានបាត់បង់ដីធ្លីនៅភូមិជាំម្លូ ឃុំរការពប្រាំ ស្រុកត្បូងឃ្មុំ ត្រូវប៉ូលិសឈ្មោះ ហ៊ាង ហ៊ត ចាប់ខ្លួនបញ្ជូនទៅស្នងការប៉ូលិសខេត្ត ហើយផ្ទះរបស់គាត់ក៏ត្រូវគេដុតបំផ្លាញចោលអស់ដែរ ។

( តនៅទំព័រទី១៤ )

# (តមកពីទំព័រទី០៥) គុកទួលស្លែងនឹងក្លាយជាសារមន្ទីរចងចាំ...

ឃោរឃៅអស់១២០០០នាក់ ហើយអ្នកទោសដែលមានសំណាងអាចរស់បាន គឺមានចំនួនតិចតួចបំផុត ។

ជនអភ័ព្វដែលរងគ្រោះនៅទីនេះ ក្នុងមួយថ្ងៃត្រូវវាយសួរចម្លើយ៣ដង ពីម៉ោង៦:០០ដល់ម៉ោង១១:០០ព្រឹក រួចពីម៉ោង១:០០ដល់ ម៉ោង៥ល្ងាច និងពីម៉ោង៨:០០ដល់ម៉ោង១១យប់ ។ ក្នុងពេលសួរចម្លើយម្តងៗអ្នកទោសណា ក៏ត្រូវពួកវាវាយធ្វើទារុណកម្មរហូតដល់សន្លប់ ។

បន្ទាប់ពីពួក ប៉ុល ពត ដួលរលំទៅ មន្ទីរឃុំឃាំងទួលស្លែងដែលជាកន្លែងធ្វើទារុណកម្ម និងសំលាប់ធំនៅទីក្រុងភ្នំពេញ ក្រោមការគ្រប់គ្រងរបស់កាំងហ្គេចអ៊ាវ ហៅ ឌុច បានក្លាយជាសារមន្ទីរទេសចរណ៍ប្រវត្តិសាស្ត្រសំរាប់ភ្ញៀវចំរុះជាតិសាសន៍ ។

កញ្ញា ឃុន មារឌី អាយុ១៨ឆ្នាំ ជានិស្សិតរៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលមកទស្សនាសារមន្ទីរទួលស្លែង ក្នុងទិកមុខស្រពោបស្រពោនបានឱ្យដឹងថា ខ្ញុំកាលនៅពីតូចឪពុកម្តាយតែងតំណាលរឿងពីសម័យ ប៉ុល ពត ឱ្យស្តាប់ដែរ ប៉ុន្តែខ្ញុំមិនជឿទេ សូម្បីតែលោកគ្រូបង្រៀននៅក្នុងថ្នាក់ ខ្ញុំគិតថាវាជារឿងនិទានប៉ុណ្ណោះ គឺគ្មានខ្មែរណាសំលាប់មនុស្សដូចសត្វធាតុអ៊ីចឹងនោះទេ ។

កញ្ញា ឃុន មារឌី បន្តថា ខ្ញុំមានអារម្មណ៍ឈឺចាប់ និងខ្មោចផ្សាយ៉ាងខ្លាំងនៅពេលឃើញអំពើឃោរឃៅបែបនេះ ហើយខ្ញុំមិនចង់ឃើញរបបនេះទៀតទេ ។ ជាមួយគ្នានេះដែរ នាងក៏សំណូមពរឱ្យសាលាក្តីខ្មែរក្រហមកាត់ក្តីមេដឹកនាំខ្មែរក្រហមឱ្យបានឆាប់ ដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះ ។

ចំណែកលោក ឡេង សុខេន អាយុ៥១ឆ្នាំ មានស្រុកកំណើតនៅខេត្តតាកែវ បានឱ្យដឹងថា ក្នុងរបបអាវខ្មៅនេះ រូបគាត់មិនខុសប្លែកពីពលរដ្ឋខ្មែរទូទៅទេ គឺរងទុក្ខវេទនាគ្រប់បែបយ៉ាង ហើយលោកក៏មានបងជីដូនមួយម្នាក់ត្រូវពួក ប៉ុល ពត ចាប់យកមកសំលាប់នៅទីនេះដែរ ។ លោក ឡេង សុខេន បញ្ជាក់ថា ទោះបីពេលវេលាបានកន្លងទៅជិត៣០ឆ្នាំហើយក្តី ប៉ុន្តែនៅពេលឃើញភស្តុតាងនៅគុកទួលស្លែងនេះ រឿងរ៉ាវនៃការឈឺចាប់ទាំងប៉ុន្មានហាក់ដូចនៅថ្មីៗ ។

បុរសរូបនោះក៏បានបញ្ជាក់ដែរថា ក្នុងនាមគាត់ជាពលរដ្ឋខ្មែរម្នាក់រស់នៅក្រោមការគ្រប់គ្រងរបស់ពួកខ្មែរក្រហម ដែលទទួលរងនូវការឈឺចាប់ ព្រាត់ប្រាស់ក្រុមគ្រួសារ គឺចង់ឃើញសាលាក្តីខ្មែរក្រហមរកយុត្តិធម៌ឱ្យបានឆាប់កាត់ទោសមេដឹកនាំទាំងនោះឱ្យ បាននិងចង់ដឹងថា "អ្នកណានៅក្រោយខ្នងនៃការកាប់សំលាប់នេះ" ។

កាលពីព្រឹកថ្ងៃទី២៩ ខែសីហា លោក ជុំ ម៉ី អាយុ៧៨ឆ្នាំ អតីតអ្នកទោសនៅទួលស្លែងម្នាក់ក្នុងចំណោម១៧នាក់ ដែលបានរួចផុតពីសេចក្តីស្លាប់បានធ្វើការអំពាវនាវដល់ជនរងគ្រោះក្នុងរបបវាលពិឃាតទាំងអស់ឱ្យដាក់ពាក្យបណ្តឹងប្រឆាំងនឹងមេដឹកនាំខ្មែរក្រហមទាំងនោះ ក្នុងឱកាសសិក្ខាសាលាមួយដែលរៀបចំដោយសមាគមសិទ្ធិមនុស្សអាដហុក ។

មន្ត្រីសំរបសំរួលរបស់សមាគមសិទ្ធិមនុស្សអាដហុកក៏បានឱ្យដឹងថា រហូតមកដល់ពេលនេះមានប្រជាពលរដ្ឋរាប់សិបនាក់ បានដាក់ពាក្យបណ្តឹងប្រឆាំងមេដឹកនាំខ្មែរក្រហម ជាពិសេសចំពោះមេគុកទួលស្លែង កាំង ហ្គេចអ៊ាវ ហៅ ឌុច មានចំនួនច្រើនជាងគេ ។

ទាក់ទងទៅនឹងភ្ញៀវទេសចរដែលទៅទស្សនាអតីតគុកទួលស្លែងនេះ លោក ប៊ុន កង ប្រធានរដ្ឋបាលនៃសារមន្ទីរទួលស្លែងបានឱ្យដឹងថា ភ្ញៀវទេសចរចំរុះជាតិសាសន៍ដែលមកទស្សនាគឺតាមរដូវកាល បើរដូវវិស្សមកាលមានភ្ញៀវបរទេសមកច្រើន ប៉ុន្តែសព្វថ្ងៃនេះ ចំនួនភ្ញៀវថយចុះ ។ បើតាមទូរលេខក្នុងខែ សីហា កន្លងមកនេះ មានភ្ញៀវចំនួន៣២៩៣នាក់ ហើយដែលកន្លងមកភ្ញៀវមកទស្សនាលើសខ្ទង់ម្ភៃបន្តិចបន្តួចតែប៉ុណ្ណោះ ។ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងនេះ ត្រូវបានលោកស្រី Isabel Qowxavez មន្ត្រីអង្គការយូណេស្កូប្រចាំប្រទេសកម្ពុជារៀបចំបញ្ជូនសំនុំឯកសារទៅកាន់ការិយាល័យយូណេស្កូ ទីក្រុងប៉ារីស ប្រទេសបារាំង ដើម្បីឱ្យក្លាយជាសារមន្ទីរចងចាំរបស់សកលលោក ។

លោក ជ័យ សុភារ៉ា អនុប្រធាននាយកដ្ឋានសារមន្ទីរទួលបន្ទុកគុកទួលស្លែងបានឱ្យដឹងថា ការប្រល័យពូជសាសន៍មួយដែលកើតនៅចន្លោះឆ្នាំ១៩៧៥-១៩៧៨ គឺប្រជាជនយើងស្លាប់ទៅអយុត្តិធម៌ខ្លាំងណាស់ ហើយការឈឺចាប់នេះបានកើតមានចំពោះប្រជាជនទូទាំងពិភពលោកដែរ ពីព្រោះជាឧក្រិដ្ឋកម្មមួយប្រឆាំងនឹងមនុស្សជាតិថែមទៀតផង ។

លោក ជ័យ សុភារ៉ា បន្តថា ភស្តុតាងទាំងនេះមានសារសំខាន់ខ្លាំងណាស់សំរាប់អ្នកសិក្សាស្រាវជ្រាវ និងសាលាក្តីខ្មែរក្រហមក្នុងការជំនុំជំរះក្តីមេដឹកនាំខ្មែរក្រហម ជាពិសេស កាំង ហ្គេចអ៊ាវ ហៅ ឌុច ជាអតីតប្រធានគុកទួលស្លែង ។

ក្រៅពីសារមន្ទីរទួលស្លែង គឺមានវាលពិឃាតបឹងជើងឯកខាងត្បូងរាជធានីភ្នំពេញ ក៏មានសំលាប់មនុស្សយ៉ាងរង្គាលមិនចាញ់គុកទួលស្លែងដែរ ហើយភស្តុតាងជាច្រើនត្រូវបានគេដាក់ឱ្យភ្ញៀវទៅទស្សនា ។ បើតាមឯកសារនៅស្រុកខ្មែរមានគុកធ្វើទារុណកម្មអ្នកទោសនៅសម័យខ្មែរក្រហមចំនួន១៨០ ប៉ុន្តែគុកទាំងនោះ គេមិនទាន់កំណត់មុខសញ្ញាបាននៅឡើយទេ ។

គួរបញ្ជាក់ថា កេរដំណែលរបស់បុព្វបុរសខ្មែរមួយចំនួនត្រូវបានគេចាត់បញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោក ក្នុងនោះរួមមានរបាំអប្សរា ល្ខោនស្បែក ប្រាសាទអង្គរវត្ត និងប្រាសាទព្រះវិហារ ។ ចំណែកឯមន្ទីរស.២១ នឹងក្លាយជាសារមន្ទីរចងចាំរបស់ពិភពលោកទាំងមូល ពីព្រោះនេះជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយពិភពលោកនឹងបានស្វែងយល់ពីកម្ពុជាកាន់តែច្រើនថែមទៀត ៕





មន្ទីរឃុំឃាំងនៅគុកទួលស្លែង



ឧបករណ៍ធ្វើទារុណកម្មនៅគុកទួលស្លែង



លលាដ៍ក្បាលជនរងគ្រោះ នៅគុករបបខ្មែរក្រហម



ភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សនាគុកទួលស្លែង



នាទី ប្រវត្តិសាស្ត្រ

## ទំព័រហ្វីឡាដែលហ្វីយ៉ា

# ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

**ដោយ : ពិនសំខុន** ***តពីលេខមុន***

**២២ មេសា** សមាជសង្គមគាំទ្រដល់នយោបាយអព្យាក្រិតរបស់នរោត្តម សីហនុ គណបក្សប្រជាជន សុំចូលជាសមាជិក តែត្រូវសង្គមច្រានចោល ។

**១៥ មិថុនា** បង្កើតសហការណ៍ដើម្បីទប់ស្កាត់ដល់អ្នកជំនាញចិន ដែលរកស៊ីយកការប្រាក់ថ្លៃហួសហេតុ ។

**ថ្ងៃ ១៥ កញ្ញា** សម្ដេចសីហនុ រំលំរដ្ឋាភិបាល ហើយឡើងកាន់តំណែងជានាយករដ្ឋមន្ត្រី បង្កើតក្រសួងបោសសម្អាតទូទៅ ហើយប្រគល់ភារៈកិច្ចនេះ ថ្វាយសម្ដេច ស៊ីសុវត្ថិ មុនីរ៉េត ជាឪពុកមានៅក្រសួងនេះ ទ្រង់មុនីរ៉េត បានគម្រោងបង្កើតអង្គភាពពិសេស ហើយឯករាជ្យ ដើម្បីជំរះបញ្ជីពុករលួយរបស់មន្ត្រីរាជការធំៗ សម្ដេច សីហនុ មិនព្រមទាមទារ សម្ដេចមុនីរ៉េត លាចេញពីដំណែង តែទ្រង់ពុំធ្វើតាមទេ ។

**៥.រដ្ឋាភិបាល នរោត្តម (១៥.៩.១៩៥៦-២៥.១០.១៩៥៦)**

.នាយរដ្ឋមន្ត្រី-មន្ត្រីមហាផ្ទៃ និងការបរទេស : នរោត្តម សីហនុ

.ទេសរដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ និងបោសសម្អាតទូទៅ : ស៊ីសុវត្ថិ មុនីរ៉េត

.រដ្ឋមន្ត្រីសន្តិសុខជាតិ និងធម្មការ : ឈួន ម៉ុលពេជ្រ

.រដ្ឋមន្ត្រីយុត្តិធម៌ : កុស ឈឿន

.រដ្ឋមន្ត្រីហិរញ្ញវត្ថុ-ផែនការ និងឧស្សាហូបនីយកម្ម : ហួត សំអាត

.រដ្ឋមន្ត្រីសាធារណការ-កសិកម្ម និងទូរគមនាគមន៍ : ផ្លែក ភីន

.រដ្ឋលេខាធិការសាធារណសិក្សាអប់រំមូលដ្ឋាន និងវិចិត្រសិល្បៈ : ហួត សម្បត្តិ

.រដ្ឋលេខាធិការពាណិជ្ជកម្ម និងឧស្សាហកម្ម : កុច សាន

.រដ្ឋលេខាធិការព័ត៌មាន-កីឡានិងយុវជន : ឃីម ឌិត

.រដ្ឋលេខាធិការសាធារណសុខាភិបាល : ញ៉ៀម សុផល

.រដ្ឋលេខាធិការការងារសង្គមកិច្ច-ការសិក្សា និងការកែទម្រង់ : ទូច គីម

.រដ្ឋលេខាធិការអមទីស្ដីការគណរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធម៌ និងសារព័ត៌មាន : សឹង ភឿកថ

.រដ្ឋលេខាធិការកសិកម្មទទួលបន្ទុករាជមន្ទីរសហករណ៍ : ឡៅ ប៊ុនប៉ា

.អនុរដ្ឋលេខាធិការ និងសង្គមកិច្ចទទួលបន្ទុកតាំងទីលំនៅ និងកិច្ចការកសិករ : រឿម សុផល

.អនុរដ្ឋលេខាធិការមហាផ្ទៃ : អ៊ុក ឈុំ

.អនុរដ្ឋលេខាធិការសាធារណសិក្សាធិកា : ធុយ ប៊ុនសូ

**ខែ តុលា សៀមដាក់ទ័ពនៅលើព្រះវិហារ**

**២៥ តុលា** ប្ដូររដ្ឋាភិបាលថ្មីម្ដងនេះ នាយករដ្ឋមន្ត្រីបានទៅលោក សាន យុន ពេលនោះទ្រង់មុនីរ៉េត លែងនៅក្នុងគណរដ្ឋមន្ត្រីទៀតហើយ ។

**៦-រដ្ឋាភិបាល សាន យុន (២៥.១០.១៩៥៦-៣.១.១៩៥៧)**

.នាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីមហាផ្ទៃ-រដ្ឋមន្ត្រីការបរទេស ការពារជាតិ និងបោសសម្អាត : សាន យុន

.រដ្ឋមន្ត្រីសន្តិសុខជាតិ និងធម្មការ : ឈួន ម៉ុលពេជ្រ

.រដ្ឋមន្ត្រីយុត្តិធម៌ : សៅ អួន

.រដ្ឋមន្ត្រីហិរញ្ញវត្ថុ ផែនការ និងឧស្សាហូបនីយកម្ម : ហួត សំអាត

.រដ្ឋមន្ត្រីសាធារណការ កសិកកម្ម និងទូរគមនាគមន៍ : ផ្លែក ភ្លីន

.រដ្ឋលេខាធិការការងារ និងព័ត៌មាន : ហួត សម្បត្តិ

.រដ្ឋលេខាធិការពាណិជ្ជកម្ម និងឧស្សាហកម្ម : កុច សាន

.រដ្ឋលេខាធិការអប់រំកីឡា-យុវជន និងវិចិត្រសិល្បៈ : ឃីម ឌិត

.រដ្ឋលេខាធិការសាធារណសុខាភិបាល និងសង្គមកិច្ច : ញ៉ៀម សុផល

.រដ្ឋលេខាធិការអមទីស្ដីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកការសម្រប សម្រួលការសិក្សា និងការកែទម្រង់ : ទូច គីម

.រដ្ឋលេខាធិការអមទីស្ដីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធម៌ និងសាព័ត៌មាន : សឹង ភឿនថ

.រដ្ឋលេខាធិការការពារជាតិ : សាក់ ស៊ុតសាខន

.រដ្ឋលេខាធិការកសិកម្ម ទទួលបន្ទុករាជមន្ទីរសហការណ៍ : ឡៅ ប៊ុន ប៉ា

.រដ្ឋលេខាធិការការងារសង្គមកិច្ចទទួកបន្ទុកតាំងទីលំនៅ និងកិច្ចការកសិករ : រឿម សុផល

.រដ្ឋលេខាធិការមហាផ្ទៃ : អ៊ុន ឈុំ

.រដ្ឋលេខាធិការសាធារណសិក្សាធិការ : ធុយ ប៊ុនសូ

**២២-២៧ វិច្ឆិកា** ទស្សនៈកិច្ចរបស់រដ្ឋមន្ត្រីការបរទេសចិន ជូអេនឡាយ មកកម្ពុជា ។

**២៦ វិច្ឆិកា** នៅប្រទេសបារាំង និស្សិតខ្មែរបង្កើតសមាគមនិស្សិតមួយឈ្មោះ "សហព័ន្ធនិស្សិតខ្មែរ" UEK ដែលមាន អ៊ិនសូគាន ជាប្រធាន នៅក្នុងគណកម្មាធិការនោះមាន អៀងសារី, ខៀវ ធីរិទ្ធ, ខៀវ សំផន, ជួបមុំ ដែលសុទ្ធជាអនាគតក្រុមខ្មែរក្រហម ។

**(តនៅលេខក្រោយ)**

នាទី ព្រះពុទ្ធសាសនា

# សមាធិវិបស្សនា

## ការរីកចំរើននៃព្រះធម៌



**ឯហិបស្សិកោ :**

ឆ្នាំ១៩៩៧ បានបង្ហាញឱ្យឃើញថា មានរីកចំរើនយ៉ាងឆាប់រហ័ស និងយ៉ាងសំខាន់នៃព្រះធម៌ ជាទូទៅមិនមែនត្រឹមតែនៅប្រទេសឥណ្ឌាប៉ុណ្ណោះទេ តែនៅលើសកលលោកទាំងមូលផងដែរ ។ ទោះបីនៅពេលសព្វថ្ងៃនេះ មានមជ្ឈមណ្ឌលត្រឹមត្រូវចំនួន៤៣ និងគ្រូអាចារ្យព្រមទាំងគ្រូជំនួយចំនួន៤០០ហើយក៏ដោយក៏សេចក្ដីត្រូវការធម្មសិក្សាវិបស្សនា មានភាពលើសលប់លើលទ្ធភាព ផ្ដល់នូវធម្មសិក្សានេះ ។ មានកត្តាជាច្រើន ដែលជាហេតុនាំឱ្យមានការរីកចំរើននៃព្រះធម៌រួមបញ្ចូលទាំងការបំរើ តាមរបៀបផ្សេងៗនៃសិស្សរាប់ពាន់នាក់ទូទៅក្នុងសកលលោក ។ ប៉ុន្តែកត្តាសំខាន់ជាងគេបំផុត គឺគុណសម្បត្តិរបស់ព្រះធម៌ផ្ទាល់តែម្ដង គឺគុណសម្បត្តិ " ឯហិបស្សិកោ សូមអញ្ជើញមកមើល "។

**មហាចេតិយវិបស្សនា :**

កាលពីថ្ងៃទី២៦ តុលា ១៩៩៧ គេបានប្រារព្ធធ្វើពិធីបុណ្យមួយ ដើម្បីចាក់គ្រឹះសំរាប់សង់ចេតិយ វិបស្សនា នៅក្រុងមុំបៃ ។ នៅក្នុងឱកាសប្រវត្តិសាស្ត្រនេះ សមាគមមហាពោធិ៍ប្រទេសឥណ្ឌាបានដង្ហែព្រះបរមសារីរិកធាតុ



យកទៅតំកល់ទុកនៅក្នុងមហាចេតិយ ។ នៅក្នុងនោះមានបន្ទប់ព័ត៌មានមួយសំរាប់ធ្វើពិព័រណ៍អំពីពុទ្ធប្រវត្តិ និងអត្ថប្រយោជន៍នៃការប្រព្រឹត្តវិបស្សនា ។ មានការពង្រីកឱ្យមានធម្មមន្ទីរមួយដែលអាចទទួលអ្នកចំរើនកម្មដ្ឋានបានចំនួនប្រហែលមួយម៉ឺន (១0000) នាក់ នៅក្នុងមហាចេតិយនោះ ។ គេសង្ឃឹមថា ការសង់មហាចេតិយនេះ នឹងបានចប់សព្វគ្រប់នាចុងឆ្នាំ១៩៩៩ បានជាទីសក្ការៈបូជាមួយយ៉ាងសមរម្យចំពោះវិបស្សនានាឱកាសចាប់ផ្ដើមចូលក្នុងសតវត្សទី២១នេះ ។ សំណង់នេះ សំរាប់រំលឹកបុណ្យខួប ១០០ឆ្នាំនៃកំណើតលោកសាយាគ្យីអ៊ូបាឃិនផងដែរ ។ បព្វជិត និងដូនជីរួមបញ្ចូលទាំងអ្នកតំណាងជាច្រើនអ្នកមកពីប្រទេសភូមា និងតៃវ៉ាន់ផង បានចូលរួមក្នុងពិធីសម្ពោធនេះ រួចហើយក៏បានទៅចូលរួមក្នុងធម្មសិក្សា១០ថ្ងៃមួយនៅចំពោះមុខលោក ហ្គោឥនកា ដែលគេបានរៀបចំឡើងនៅពេលជាមួយគ្នានៅធម្មគីរី ។ នៅក្នុងឱកាសជាមួយគ្នានោះ មានការធ្វើអំណោយទានជាផ្លូវការនូវ ថាសកុមប៉ាក់ CD-ROM ព្រះត្រៃបិដកភាសាបាលី ដែលជាលទ្ធផលរបស់វិទ្យាស្ថានស្រាវជ្រាវវិបស្សនា ។ នេះគឺជាថាស CD-ROM លើកទីមួយក្នុងពិភពលោកដែលមានព្រះត្រៃបិដកទាំងមូល ព្រមទាំងអក្សរសាស្ត្រសម្ព័ន្ធ (textes asscies )ផងជាតួអក្សរទេវនាគរី រ៉ូម៉ាំង និងភូមា ។ ព្រះត្រៃបិដក និងអក្សរសាស្ត្រសម្ព័ន្ធនេះផ្អែកទៅលើអត្ថបទជាទីទុកចិត្តរបស់សង្គាយនាទី៦ នៅប្រទេសភូមា នាដើមសតវត្សទី២០នេះ ។ ថាសកុមប៉ាក់ នេះរក្សាទុកនូវពុទ្ធវចនៈពិតប្រាកដតាមរបៀបអេឡិចត្រូនិចសម័យថ្មី ហើយជួយសិក្សាស្រាវជ្រាវផ្នែកអក្សរសាស្ត្រយ៉ាងច្រើនមហិមា យើងមានដំណើរយ៉ាងឆាប់រហ័សទាន់ចិត្ត ។ ដោយហេតុនេះ ថាសកុមប៉ាក់ជាឧបករណ៍មួយសំខាន់ណាស់ក្នុងការស្រាវជ្រាវវិទ្យាស្ថានកំពុងតែធ្វើការចែកផ្សាយជាទូទៅជាធម្មទានចំពោះគ្រឹះស្ថានអប់រំ, អ្នកប្រាជ្ញស្រាវជ្រាវ និងអ្នកចូលចិត្តចង់បានទាំងឡាយក្នុងសកលលោក ។

**ប្រទេសឥណ្ឌា :**

ក្នុងឆ្នាំ១៩៩៧ គេបានរៀបចំធ្វើធម្មសិក្សា ១០ ថ្ងៃចំនួនសរុប២៥៦ដង ។ ចំនួននេះរាប់បញ្ចូលទាំងធម្មសិក្សា៥០នៅក្នុងពន្ធនាគារ១០ផងដែរ។ នៅទីក្រុងមុំបៃគេបានរៀបចំធម្មសិក្សា១០ថ្ងៃ មួយដាច់ដោយឡែកពីសំរាប់តែមនុស្សឃ្លង់ និងធម្មសិក្សាពីរទៀតដាច់ដោយឡែកសំរាប់តែមនុស្សពិការភ្នែក ។ ក្នុងឆ្នាំនេះ នៅទីក្រុង បង្គ លោរ៍ (Bongalore) និងរដ្ឋកេរល (Etat de Kerala) ភាគខាងត្បូងនៃប្រទេសឥណ្ឌា គេសង្កេតឃើញថា ធម្មសិក្សា និងសិស្សបានកើនចំនួនយ៉ាងជាក់ស្ដែង ។ នៅធម្មគីរី គេបានរៀបចំធម្មសិក្សា១០ថ្ងៃចំនួន ២១ដង ធម្មសិក្សាសំរាប់សិស្សចាស់៩ដង ហើយមានសិស្សថ្មី៧៣៥០នាក់ និងសិស្សចាស់២៨៩២នាក់ បានមកចូលរួមក្នុងធម្មសិក្សាទាំងឡាយនោះ ។ ក្នុងឆ្នាំនេះ ពាក្យសុំចូលរួមក្នុងធម្មសិក្សាមានចំនួនច្រើនលើសលប់ : គេកំពុងទទួលពាក្យ

**(តនៅលេខក្រោយ)**

(តមកពីទំព័រទី១១)

# អ្នកស្រុកនាំគ្នាស្រែកយំ...

អ្នកស្រី តុង ស៊ាត ត្រូវជាប្រពន្ធរបស់ សាន វី បានយំរៀបរាប់ថា មេឃុំដុតផ្ទះខ្ញុំចោល ប្ដីខ្ញុំត្រូវគេចាប់ដាក់គុកទៀត អយុត្តិធម៌ណាស់ ។ បើប្ដីខ្ញុំធ្វើខុសហេតុអ្វីត្រូវអនុវត្តតាមច្បាប់ ហើយ


លំនៅរបស់ប្រជាពលរដ្ឋ នៅជុំវិញតំបន់បឹងកក់

បើប្ដីខ្ញុំធ្វើខុសគួរតែរកភស្តុតាងឱ្យឃើញ នេះជាសំរែកទួញយំរបស់ស្ត្រីរងគ្រោះប្រាប់ក្រុមអង្គការសិទ្ធិមនុស្ស អ្នកកាសែតកាលពីថ្ងៃទី១៩ ខែសីហា ។ លោក ហ៊ាង ហ៊ត អធិការប៉ូលិសស្រុកត្បូង ឃ្មុំស្ដីទី បានឱ្យដឹងថា ឈ្មោះ សាន វី ត្រូវចាប់ខ្លួនតាមតុលាការលេខ៣៤០របស់ចៅក្រមលោក កែម សាន ប៉ុណ្ណោះ ។

ប្រជាពលរដ្ឋ ៧១៩គ្រួសាររស់នៅឃុំព្រែក-កក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម បានសំដែងនូវការព្រួយបារម្ភចំពោះក្រុមហ៊ុន ឡុង ស្រេង បានគំរាមកំហែងឈូសឆាយដីរបស់ពួកគាត់ ដែលធ្លាប់កាន់កាប់តាំងពីឆ្នាំ១៩៧៩មកម្ល៉េះ ។

លោក មិន សុផេង បានរៀបរាប់កាលពីថ្ងៃទី១២ ខែសីហា ថា ពួកគាត់ធ្លាប់ធ្វើការប្ដឹងប្ដល់ច្រើនលើកច្រើនសារហើយ សូម្បីតែនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន ក៏ទៅដែរ ប៉ុន្តែមិនឃើញមានចំណាត់ការសោះ ។ នៅលើដីនោះពួកគាត់ធ្លាប់ដាំដុះដំណាំកៅស៊ូ ប៉ុន្តែត្រូវក្រុមហ៊ុន ឡុង ស្រេង ឱ្យប៉ូលិសដកចេញអស់ ។

**-ខេត្តកំពត :** កាលពីថ្ងៃទី២៣ ខែសីហា ប្រជាពលរដ្ឋប្រមាណជាង២០០នាក់ រស់នៅភូមិកែបថ្មី, រលួស និងទទឹងថ្ងៃ ឃុំបឹងឈូក ស្រុកកំពត បានលើកគ្នាតវ៉ាចំពោះក្រុមហ៊ុន កំពតផត និងក្រុមហ៊ុន កែវ ជា Property and Development ដែលធ្វើការបូមខ្សាច់បំពេញ ផ្ទៃសមុទ្រ ធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន បាត់បង់ជីវកមច្ចាជាតិ ។

បើតាមលិខិត ស.ជ.ណ ដែលខ្មែរប៉ុស្តិ៍ ទទួលបាន មានចុះហត្ថលេខារបស់លោក ប៊ុន អ៊ុយ រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី អនុញ្ញាតឱ្យក្រុមហ៊ុនទាំងពីរបូមខ្សាច់ចាក់បំពេញផ្ទៃដីចំនួន១០០ហិកតា បង្កើតតំបន់សេដ្ឋកិច្ច ។

**-ខេត្តក្រចេះ :** ប្រជាពលរដ្ឋនៅភូមិមានជ័យ ឃុំស្រែចារ ស្រុកស្នួល បានលើកគ្នាមកតវ៉ា ជាមួយក្រុមហ៊ុន ស៊ី អាយ វី ដែលបានយកគ្រឿងចក្រទៅឈូសឆាយដំណាំរបស់ពួកគាត់ម្ដង ហើយម្ដងទៀត លើផ្ទៃដីជាង១០០០ហិកតា ។

លោក សារ៉ែន កែត តំណាងឱ្យប្រជាពលរដ្ឋនៅភូមិខាងលើបានឱ្យដឹងថា អ្នកស្រុកទប់កំហឹងលែងចង់បានហើយ ដោយសារកាលពី ថ្ងៃទី១៩ ខែសីហា កន្លងមកនេះ ក្រុមហ៊ុន ស៊ី អាយ វី បានមកឈូសឆាយផលដំណាំរបស់ពួកគាត់ដែលខំដាំចោលអស់ ។ ពួកគាត់បានស្នើទៅអាជ្ញាធរឱ្យជួយអន្តរាគមន៍ ប៉ុន្តែហាក់ដូចជាគ្មានប្រសិទ្ធភាពសោះ ដោយសារក្រុមហ៊ុនគេមាន អ្នកមានអំណាចនៅពីក្រោយខ្នងជាបង្អែក ។ ជាពិសេសពួកគេមិនចង់បានដីនិងមិនចង់បានលុយកាក់បន្តិចបន្តួច បង្កឱ្យយើងដាច់ពោះស្លាប់នៅពេលក្រោយ ។

**-ខេត្តស្ទឹងត្រែង :** មិនថាតែប្រជាពលរដ្ឋធម្មតាទេ ដែលរងនូវការគំរាមកំហែងនោះ សូម្បីតែអតីតយោធា និងអ្នកភូមិ ក៏ត្រូវប្រឈមមុខនឹងកងយោធាភូមិភាគ១ ខេត្តធ្វើការគាបសង្កត់បង្ខំឱ្យប្រគល់ដីទៅថ្នាក់លើ និងផ្លាស់ប្ដូរការងារថែមទៀត ។

អនុសេនីយ៍ត្រី រាម ណារ៉េត បានអះអាងថា រឿងបញ្ហាថ្នាក់លើត្រូវតែគោរព ប៉ុន្តែរឿងដីផ្ទះសំបែងដែលធ្លាប់រស់នៅជាង១០ឆ្នាំហើយ បែរជាមកបណ្ដេញឱ្យចេញនោះ តើឱ្យគាត់ និងកូនប្រពន្ធទៅនៅទីណា ? នេះជារឿងអយុត្តិធម៌ខ្លាំងណាស់សំរាប់ពួកគាត់ និងពលទាហានជាង១០គ្រួសារទៀតនោះ ។

លោក រាម ណារ៉េត បន្តថា ដីនេះពួកគាត់ធ្លាប់រស់នៅតាំងពីឆ្នាំ១៩៨៥ ហើយឥឡូវនេះស្រាប់តែមេថ្មីឡើងមកមានគោលការណ៍ពង្រីកដីដាំដំណាំ យកដីកូនចៅស្រេចតែចិត្ត ដែលធ្វើឱ្យពួកគាត់មិនអាចទទួលយកបានទេ ។

**-ខេត្តកណ្ដាល :** កាលពីថ្ងៃទី២២ ខែសីហា កន្លងមក ប្រជាពលរដ្ឋប្រមាណជាង៣០០នាក់ នៅភូមិបោះអង្កាញ់ ឃុំព្រែកឯង ស្រុកក្បៀនស្វាយ បានលើកគ្នាទៅតវ៉ានឹងអាជ្ញាធរស្រុក ដែល មានគោលនយោបាយដេញ ពួកគាត់ចេញ និង សងជំងឺចិត្តបន្តិចបន្តួច ។

អ្នកស្រុកម្នាក់ឈ្មោះ សុគន្ធ បានឱ្យដឹងថា ដីនេះពួកគាត់ធ្លាប់បង្កបង្កើនផលតាំងពីឆ្នាំ១៩៧៩ លុះដល់ឆ្នាំ១៩៨៥ អាជ្ញាធរស្រុកក៏បានដកហូតទុកកសាងសាលារៀន មន្ទីរពេទ្យ ប៉ុន្តែពួកគាត់រង់ចាំមើលដល់ឆ្នាំ១៩៩២ មិនឃើញមានធ្វើអ្វីក៏នាំគ្នាទៅរស់នៅបង្កបង្កើនផលវិញ និងឮដំណឹងថា ស្រុកលក់ទៅឱ្យក្រុមហ៊ុន ឈឿន ចាន់ថន ។

ចៅហ្វាយស្រុកក្បៀនស្វាយលោក ហេង ទៀន បានធ្វើការចោទប្រកាន់ថា ប្រជាពលរដ្ឋ រស់នៅអនាធិបតេយ្យលើដីរបស់គណបក្សប្រជាជនកម្ពុជា ហើយលោកកំពុងធ្វើការសំរបសំរួលគ្នាឱ្យពួកគាត់រស់នៅក្បែរទីនោះវិញ ។

**-ខេត្តកំពង់ឆ្នាំង :** កាលពីថ្ងៃទី២៥ ខែសីហា ប្រជាពលរដ្ឋនៅភូមិឡពាង និងបឹងកក់ ឃុំតាជេស ស្រុកកំពង់ត្រឡាច ដែលមានចំណារនាយករដ្ឋមន្ត្រី ហ៊ុន សែន ឱ្យជួយដោះស្រាយ ប៉ុន្តែត្រូវក្រុមហ៊ុនខេឌីស៊ី របស់អ្នក ជា ខេង ភរិយាលោក ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល មិនព្រមសំរបសំរួល ។

អ្នកស្រី ទូច លី ប្រធានភូមិឡពាង បាននិយាយទាំងអស់សង្ឃឹមថា តំណាងក្រុមហ៊ុនគេមិនព្រមមកជួបយើងទេ ហើយតំណាងរបស់


លំនៅរបស់ប្រជាពលរដ្ឋ នៅជុំវិញតំបន់បឹងកក់

គេថា ជាដីស្របច្បាប់របស់គេដែលទិញពីម្ចាស់ទី២ត្រឹមត្រូវ មានប្លង់តាំងពីឆ្នាំ១៩៩៧-២០០៧ ។

តំណាងក្រុមហ៊ុន ខេឌីស៊ី បានធ្វើការបដិសេធចំពោះការចោទប្រកាន់របស់អ្នកស្រុក ហើយបានអះអាងថា គេមានច្បាប់ត្រឹមត្រូវទៅវិញ ។

**-ខេត្តមណ្ឌលគិរី :** ពួកជនជាតិព្នងរស់នៅភូមិពូឡេះ ឃុំដាក់ដាំ ស្រុកអូរាំង បានផ្ដិតមេដៃប្រឆាំងនឹងប៉ូលិសឃុំដាក់ដាំ ដែលកាប់ឆ្ការព្រៃរបស់ពួកគាត់ធ្លាប់គោរពបូជា និងដាំដុះតាំងពីសម័យបុរាណអស់ជាង១០ហិកតា ឱ្យអង្គការសិទ្ធិមនុស្សជួយអន្តរាគមន៍ ។

លោក ចាស់ ឃើត តំណាងពួកព្នង បានឱ្យដឹងថា តាំងពីថ្ងៃទី១៩ ខែសីហា មេប៉ូលិសយោន ហាន បានដាក់ម៉ាស៊ីនត្រង់តីន័រ កាត់ផ្ដាច់ព្រៃឈើរបស់ពួកគាត់យ៉ាងរង្គាល គ្មានកោតញញើតអ្នកសោះឡើយ ។

**-ខេត្តរតនគិរី :** អ្នកភូមិតងក្រពូ ឃុំអូរជុំ ស្រុកអូរជុំ បានលើកគ្នាទៅមុខសាលាខេត្តកាលពីថ្ងៃទី២០ តវ៉ារឿងក្រុមហ៊ុនឈូសឆាយដីរបស់ពួកគាត់ធ្លាប់បង្កើនផលអស់ជាង២០ហិកតា ។ ពួកឈ្មួញបានឱ្យលុយជាសំណងផ្លូវចិត្តបន្តិចបន្តួច ប៉ុន្តែពួកគាត់បដិសេធ ពីព្រោះខ្លាចដាច់ពោះស្លាប់ទៅថ្ងៃមុខ ។

ក្នុងលិខិតបញ្ជាក់របស់អ្នកភូមិបានឱ្យដឹងថា អភិបាលស្រុក និងបក្ខពួកបានប្រគល់ដីនេះ ឱ្យទៅឈ្មោះ សេង ពិសិដ្ឋ កាលពីខែកក្កដា ហើយពួកគាត់សូមឱ្យអាជ្ញាធរខេត្តជួយអន្តរាគមន៍ ពីព្រោះដីនេះទុកបង្កបង្កើនផលអភិរក្ស និងជាកន្លែងគោរពបូជា ។

(តមកទំព័រទី២០)




## បណ្ណបញ្ជាកាសែតខ្មែរប៉ុស្តិ៍

ខ្ញុំចង់ឱ្យ " ខ្មែរប៉ុស្តិ៍ " ផ្ញើរកាសែតជាភាសាខ្មែរ ដែលសំបូរដោយព័ត៌មានក្នុងសហគមន៍ខ្មែរនៅបរទេស មកឱ្យខ្ញុំជាប្រចាំ រៀងរាល់ពេល ដែលកាសែតនេះចេញផ្សាយ មួយខែពីរដង ។

ឈ្មោះ និងអាស័យដ្ឋានរបស់ខ្ញុំ :

ឈ្មោះ :......................................................

អាស័យដ្ឋាន :................................................

...........................................................U.S.A.

ទូរស័ព្ទ :......................................................

អ៊ីមែល :......................................................

ខ្ញុំផ្ញើរភ្ជាប់ជាមួយនូវ សែក ឬ មានីអដ័រ មក U.A.M.G ចំនួនមួយខែតម្លៃ ៥ ដុល្លារ ×........( ចំនួនមួយខែ ) =...................

U.A.M.G 5730Rising Sun Avenue Philadelphia,PA 19120

**Phone : (215) 722-2226**

## (តមកពីទំព័រទី១១) កូនខ្មែររៀនសូកប៉ាន់តាំងពីថ្នាក់...

សុខ សីហា រៀនថ្នាក់ទី១ បាននិយាយថា ពួកគេពេលចូលដល់ក្នុងថ្នាក់ ត្រូវប្រធានថ្នាក់ដើរប្រមូលលុយឱ្យគ្រូម្នាក់៣០០រៀលជាប្រចាំ ហើយអ្នកណាមិនឱ្យលុយគ្រូទេ គាត់នឹងស្តីឱ្យ ។

សុខ សីហា បានរៀបរាប់ថា នៅក្នុងរៀនក្រៅពីប្រមូលលុយឱ្យគ្រូម្នាក់៣០០ហើយ គាត់តំរូវឱ្យទិញនំ និងផ្លែឈើដែលគាត់ដាក់លក់មួយជាន់ទៀត ហើយថ្នាក់ណាក៏គេធ្វើដូចគ្នាដែរ ។

លោកគ្រូ កែវ សុឡេង បង្រៀននៅសាលាបឋមសិក្សាស្ទឹងមានជ័យ បានឆ្លើយទាំងអៀនខ្មាស់ថា គាត់ពិតជាបានទទួលលុយពីសិក្សាមែន ការយកនោះទាំងបង្ខំចិត្តសំរាប់ដោះស្រាយក្រពះប៉ុណ្ណោះ គឺមិនអាចធ្វើមានបានទេ គ្រាន់តែទ្រឆ្នាំងបាយកុំឱ្យអស់អង្ករទេ ។

អ្នកគ្រូបន្តថា បើប្រាក់ខែចាយគ្រប់គ្រាន់ គាត់មិនទៅប្រមូលលុយកាក់ ២០០-៣០០រៀល នាំតែសិស្ស និងឪពុកម្តាយ.... ទេ ប៉ុន្តែវាទាល់ទៅហើយ មិនដឹងធ្វើយ៉ាងម៉េច ។

លោកគ្រូ-អ្នកគ្រូនៅរាជធានីភ្នំពេញ ក៏ដូចជានៅទីប្រជុំជននានាដែរ គឺពួកគាត់ធ្វើបែបនេះទាំងក្បត់ឧត្តមគិត ខុសពីមនសិការវិជ្ជាជីវៈ ដើម្បីតែក្រពះប៉ុណ្ណោះ ពីព្រោះប្រាក់ខែតិចតួចពេកមិនអាចរស់បាន ។

លោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា បានឱ្យដឹងថា ការប្រមូលលុយបន្តិចបន្តួច និងលក់ឯកសាររបស់គ្រូៗ មិនមែនជារឿងពុករលួយទេ គឺជារឿងក្រពះសុទ្ធសាធ សព្វថ្ងៃនេះប្រាក់ខែពួកគាត់ម្នាក់ៗពី២០ទៅ៣០ម៉ឺនរៀល គ្រាន់តែចាក់សាំងស្ទើរមិនគ្រប់ផង ។

លោក រ៉ុង ឈុន បានបន្តថា កន្លងមកសមាគមលោកបានធ្វើលិខិតស្នើសុំទៅរដ្ឋាភិបាលឱ្យដំឡើងប្រាក់ខែគ្រូបង្រៀនយ៉ាងតិចពី១០០ទៅ១៥០ដុល្លារ ប៉ុន្តែគ្មានការឆ្លើយបតសោះ ហើយឡើងឱ្យមួយឆ្នាំ២០% ស្មើនឹង១២០០០រៀលនោះ វាមិនទាន់ទំនិញទីផ្សារទេ ។ ដូច្នេះដើម្បីបំបាត់បាតុភាពទាំងនេះ រដ្ឋាភិបាលត្រូវតែដំឡើងប្រាក់ខែឱ្យពួកគាត់ឱ្យបានគ្រប់ ទើបវាមិនជះឥទ្ធិពលអាក្រក់ដល់ទំពាំងស្នងឫស្សី ។

ទាក់ទិននឹងបញ្ហាប្រាក់ខែគ្រូបង្រៀននេះ អ្នកស្រី ម៉ារីតា នីកូឡាស គ្រូបង្រៀនឆ្លងដែនមកពីសហរដ្ឋអាមេរិកដែលមកបណ្តុះបណ្តាលគ្រូៗនៅក្រុងភ្នំពេញ បានធ្វើការកត់សំគាល់ថា រដ្ឋាភិបាលគួរតែដំឡើងប្រាក់ខែឱ្យលោកគ្រូ-អ្នកគ្រូឱ្យបានច្រើន ដើម្បីលើកស្ទួយជីវភាពរស់នៅ គុណភាពអប់រំទៅពេលអនាគត ។

នាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់ថា រាជរដ្ឋាភិបាលគ្មានប្រាក់ឡើងឱ្យអ្នករាជការម្តងពី១០០ទៅ១៥០ដុល្លារទេ ប៉ុន្តែយើងមានគោលការណ៍ដំឡើងឱ្យក្នុងមួយឆ្នាំ២០%ជា រៀងរាល់ឆ្នាំ រហូតដល់១០០ដុល្លារ ។

ក្នុងយុទ្ធនាការឃោសនាបោះឆ្នោតថ្ងៃទី២៧ ខែកក្កដា កន្លងមក គណបក្សនយោបាយចំនួន ១០ បានប្តេជ្ញាចិត្តប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

គឺមានតែគណបក្សប្រជាជនកម្ពុជាមួយទេ ដែលមិនព្រមចូលរួម ហើយបែរជាឈ្នះឆ្នោតទៅវិញ ។

លោក គល់ បញ្ញា នាយកប្រតិបត្តិអង្គការ



លោក គល់ បញ្ញា នាយកប្រតិបត្តិអង្គការ ខុមហ្វ្រែល

ខុមហ្វ្រែលបានបញ្ជាក់ក្នុងវេទិកានោះថា អំពើពុករលួយបានរីករាលដាលលើគ្រប់វិស័យ គឺទាំងវប្បធម៌ សង្គមកិច្ច សេដ្ឋកិច្ច តាំងពីថ្នាក់លើដល់ថ្នាក់ក្រោមបំផុត ។ ចំណែកឯប្រព័ន្ធ តុលាការ សុខាភិបាល អប់រំ ការគ្រប់គ្រងធនធានធម្មជាតិ បានគ្របដណ្តប់ដោយអំពើពុករលួយ ធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍន៍សង្គមកិច្ច ។

លោក យឹម សុវណ្ណ តំណាងរាស្ត្រគណបក្សសម រង្ស៊ី បានឱ្យដឹងថា គណបក្សលោកបានធ្វើការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយពអាណិត្ត ហើយ ព្រមទាំងបានធ្វើសេចក្តីព្រៀងច្បាប់ឱ្យសភាអនុម័តច្បាប់ប្រឆាំងនឹងអំពើពុករលួយដែរ ប៉ុន្តែមិនត្រូវប្រធានសភា និងគណៈកម្មាធិការជំនាញនៃរដ្ឋសភាចាប់អារម្មណ៍ឡើយ ។

កញ្ញា សេង ធារី នាយិកាមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម បានបញ្ជាក់ថា រដ្ឋាភិបាលត្រូវតែអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយឱ្យបានឆាប់ ដើម្បីការពារផលប្រយោជន៍ប្រជាពលរដ្ឋ ។

ដោយសារតែគ្មានច្បាប់ប្រឆាំងនឹងអំពើពុករលួយ ធ្វើឱ្យមន្ត្រីរាជការមួយភាគធំប្រព្រឹត្តិអំពើពុករលួយ ដើម្បីដោះស្រាយជីវភាពរស់នៅប្រចាំថ្ងៃ ។ បញ្ហានេះត្រូវបានលោក សុខ សំអឿន នាយកប្រតិបត្តិអង្គការអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា បានបញ្ជាក់ក្នុងឱកាសនាំមេដៃយកទៅប្រគល់ជូនរដ្ឋសភាថា មន្ត្រីរាជការកម្រសុំប្រាក់ក្រោយតុណាស់ ប៉ុន្តែគេមានវិធីតាមរយៈការបំពេញសំណុំបែបបទ ដោយរកលេសខុសនេះ ខុសនោះ ឬធ្វើឱ្យយឺតយ៉ាវ បើកាលណាអ្នកទៅធ្វើកិច្ចការមិនព្រមបង់លុយឱ្យគេនោះ ។

គួរបញ្ជាក់ថា កាលពីថ្ងៃទី១៦ ខែឧសភា កន្លងមក អង្គការសមាគមជាង៤០ ក្នុងប្រទេសកម្ពុជា ដែលធ្វើយុទ្ធនាការស្នាមមេដៃប្រជាពលរដ្ឋបានជាង១លាននាក់ នាំយកទៅរដ្ឋសភាដើម្បីឱ្យរដ្ឋសភាអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ ។ ប៉ុន្តែត្រូវបានតំណាងរដ្ឋសភាមិនទទួលយក ហើយថា រដ្ឋសភាគ្មានកន្លែងទុកស្នាមមេដៃទាំងនេះទេ ។

ការរីករាលដាលនៃអំពើពុករលួយនេះ អង្គការតម្លាភាពអន្តរជាតិ ជាអង្គការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ មានទីតាំងនៅក្រុងប៊ែកឡាំង ប្រទេសអាល្លឺម៉ង់ បានរកឃើញថា មន្ត្រីកម្ពុជាភាគច្រើនរស់ដោយសារទទួលប្រាក់សំណូក ហើយលុយរដ្ឋក្នុងមួយឆ្នាំបាត់អស់ ប្រមាណពី ៣៥០ទៅ៥០០លានដុល្លារ គឺជិតស្មើនឹងប្រាក់ជំនួយរបស់សហគមន៍អន្តរជាតិដែលជួយប្រចាំឆ្នាំសំរាប់កម្ពុជាទៅហើយ ៕

## (តមកពីទំព័រទី១០) លិង្គព្រះឥសូរ_យោនីព្រះនាងឧមាវតី...

ត្រូវបានបុព្វបុរសខ្មែរយកមកពាក់ធ្វើ ជាបន្តោងខ្សែ.ក ដើម្បីធ្វើជាគ្រឿងសិរីមង្គលការពារខ្លួន ។

សូមរំលឹកបញ្ជាក់ឡើងវិញថា លិង្គធ្វើអំពីថ្មនៅស្ថានីយ៍សំរោងសែន ក៏មានអត្ថន័យដូចលិង្គដទៃទៀតដែរ ដែលស្ថិតក្នុងសម័យកាលដូចគ្នា ពោលគឺរវាង៥០០ ទៅ១០០ឆ្នាំមុនគ្រិស្តសករាជ ។ ក្នុងសម័យអង្គរការបូជាក្នុងឱកាសធ្វើពិធីឆ្លងប្រាសាទ ដើម្បីបង្រួបបង្រួមជាតិព្រះរាជាខ្មែរ រមែងឧទ្ទិសដល់ព្រះសិវលិង្គ ដោយប្រើពាក្យ "កម្តែង/ជគតតរាជ្យ" ពាក្យនេះ មានន័យថា "ទេវតាប្រចាំរាជវង្សានុវង្សខ្មែរ" ហើយសំដៅព្រះសិវលិង្គនេះឯង ដែលស្ថិតនៅចំកណ្តាលព្រះរាជនគរ " ។

ចំពោះខ្មែរ លិង្គ គឺមិនគ្រាន់តែជាប្រដាប់ភេទរបស់បុរសផ្តល់នូវភាពស្រណុកស្រួលក្នុងការរួមរក្សជាមួយភេទស្ត្រីតែប៉ុណ្ណោះទេ ប៉ុន្តែជាប្រដាប់បន្តពូជពង្សវង្សត្រកូល ពោលគឺ ខ្មែរគោរពថ្វាយបង្គំព្រះសិវលិង្គ ក៏ដោយសារមូលហេតុចម្បងនេះដែរ ។ ហេតុដូច្នេះហើយ បានជាគេស្ថាបនាលិង្គ និងយោនីថ្មសំរាប់ជានិមិត្តសញ្ញាទុកជាទីសក្ការបូជារហូតមក ។

បើតាមឯកសារប្រវត្តិសាស្ត្រ និងសំណង់ប្រាសាទយ៉ាងច្រើនលើសលប់ បានបញ្ជាក់ថា ព្រះមហាក្សត្រ នាហ្មឺនសព្វមុខមន្ត្រី ប្រជាពលរដ្ឋគោរពចំពោះលិង្គព្រះឥសូរ និងយោនីព្រះនាងឧមាវតី ក្នុងលទ្ធិព្រហ្មញ្ញសាសនា តាំងពីសតវត្សទី១ដល់សតវត្សទី១៣ ។ ក្នុងនោះ គេសង្កេតឃើញនៅបាតស្ទឹងសៀមរាប លើកំពូលភ្នំគូលែនមានលិង្គ១០០០ និងចម្លាក់យោនី ពាសពេញបាតដីដែលមានទឹកហូរខ្វបប្រាំង ខ្វបវស្សា ជាពិសេសនៅតាមប្រាង្គប្រាសាទជាច្រើន ដែលបុព្វបុរសយើងកសាងឡើងដើម្បីឧទ្ទិសថ្វាយចំពោះព្រហ្មញ្ញសាសនា ដោយក្នុងនោះ មានតម្កល់រូបសំណាកលិង្គព្រះឥសូរ និងយោនី សំរាប់គោរពបូជាផងដែរ ។

ចំពោះជំនឿការគោរពលិង្គព្រះឥសូរ និងយោនីព្រះនាងឧមាវតី គឺកើតមានតាំងពីសម័យយូរលង់ដ៏ណាស់មកហើយ ហើយមនុស្សសម័យមុនជឿថា វត្ថុទាំងពីរនេះបានបង្កើតមនុស្សលោកដំបូងបំផុតលើផែនដីភាគច្រើនគេតំណាងឱ្យព្រលឹងរបស់បុព្វការីជន ដែលចាំថែរក្សាកូនចៅ បន្តពូជពង្សគ្រប់សម័យកាល ជាពិសេសតំណាងឱ្យអ្នកតាចាស់ស្រុក ។

លើសពីនេះទៅទៀត រូបសំណាកទាំងនេះគេតំណាងឱ្យឯកភាពគ្នា ភាពសម្បូរសប្បាយរុងរឿង ហើយរឹងមាំអមតៈ ក្នុងចិត្តមនុស្សគ្រប់វ័យប្រៀបបីដូចជាថ្ម ដែលរឹងមាំ ហើយត្រជាក់ត្រជុំទៀតផង ។ នៅក្នុងសារមន្ទីរជាតិគេសង្កេតឃើញមានការដាក់តាំងវត្ថុបុរាណយ៉ាងច្រើន ដែលទាក់ទងនឹងវប្បធម៌ ទំនៀមទំលាប់ប្រពៃណីសាសនាខ្មែរតាំងពីសម័យបុរាណ ដែលបញ្ជាក់ពីភាពចាស់ទុំផ្នែកវប្បធម៌ អរិយធម៌របស់ខ្មែរយើងនៅតំបន់អាស៊ីអាគ្នេយ៍ ៕



Get Connect...Stay inform.

....Subscribe to the Khmer Post!

Please send me 1 year subscription of the Khmer Post newspaper 24 issues for $60.00

Name: ____________________

Address: ____________________

____________________

Payment method:

Money order Check Bill me

Please send your payment to US-Asia Media Group.

5730 Rising Sun Ave. Philadelphia, Pa 19120

# កំណើតជាមនុស្ស

**ដោយអ្នកស្រី សុខុម អ៊ឹង**

ក កើតជាមនុស្សពិតជាសំណាង
ខ ខើចអាយុទាំងក្មេងចាស់
គ គួរគប្បីគិតកុំឃ្លាត
ឃ ឃ្មីឃ្មាត ! ណាស់នេះបណ្ដាំ
ង ងប់នឹងល្បែងតែចាក់ឃ្លាត
ត្រូវតាំងចិត្តជាប់រាប់ជាញាតិ
ច ចេញឱ្យឆ្ងាយកុំប្រហារ
ឆ ឆ្លាតឱ្យណាស់ខំខ្មីឃ្មាត
ជ ជាប់ជឿខុសចាញ់កិលល្បិច
ឈ ឈ្លោកកុំងុលក្បែរពាងស្រា
ញ ញ៉ីមញញែមញៀនថ្នាំខ្លាំង
ដ ដាមដិតជាប់ចិត្តឥតញ្ញេច
ឋ ឋានពិតគ្មានពិនប្រាកដ
ឌ ឌិតប្រឌិតរឿងនានា
ណ ណាត់អ្នកណាបានស្ដាប់ហើយ
ត តឹងសញ្ជឹងឱ្យប្រាកដ
ថ ថារឿងនេះពិតបវរ
ទ ទ្រឹងសញ្ជឹងប្រឹង១ដើរ
ធ ធន់អត់ធ្មត់ត្រូវតែប្រឹង
ន នេះរឿងរ៉ាវមនុស្សត្រូវស្ដាប់
ប បោសចាំបុក ចេញចំប្រាវ
ផ ផុងចិត្តផុយដូចដោះអាវ

ដូចមានភស្ដុតាំងឃើញជាក់ច្បាស់
អាយុខ្លីណាស់ស្លាប់ព្រោះកម្ម ។
មិនគួរប្រមាទផ្លូវធម៌ផ្ដាំ
ប្រព្រឹត្តមាំទាំខំសង្វាត ។
មនុស្សត្រូវឆ្លាស់ឈ្លៀតកុំទ្រមាថ
ត្រូវតាមក្បួនខ្នាតនៃមនុស្សជាតិ ។
ត្រូវមានមេត្តាកុំពិឃាត
រស់កុំឱ្យឃ្លាតពីសាសនា ។
រស់សុំកុំភ្លេច ពាក្យមេត្តា
ចាញ់កិលមាយាចិត្តកំហូច ។
សុរាប្រឆាំងឥតប្រយោជន៍
ញ៉ាំងឱ្យកាយខូចខាតការបារ ។
និញ្ញនពិតខ្សត់ត្បិតតណ្ហា
កាព្យខ្មែរពិស្ដាមានដោយខ្សត់
សូមកុំដៀលឡើយត្រូវអំណត់
ពាក្យពិតបំផុតមិនងាយឮ ។
ជាតិមនុស្សនិករសំណាងលើ
សង្វាតប្រឹងធ្វើឱ្យចំណាប់ ។
ទើបដល់បានដឹងរឿងត្រូវស្លាប់
មួយរឿងត្រូវកាប់ដោយមុខដាវ ។
ខំប្រឹងស្រាវជ្រាវដឹងរឿងរ៉ាវ
ឱ្យចិត្តស្រួចស្រាវទាំងប្រុសស្រី ៕


**NEW GOLDEN PALACE RESTAURANT**

801-21 Washington Ave.
Phone: 215-627-2822

Open Daily from 10am-10pm
Dim Sum Every Day from 10am - 3pm

**Authentic Chinese & Vietnamese Cuisine**
**Very Delicious and Nutritious**

-ហាងយើងមានម្ហូបចិន នឹងម្ហូបវៀតណាមពិតប្រាកដ មានរសជាតិឈ្ងុយឆ្ងាញ់ ហើយជីវជាតិប្រសើរ

**ពិសេសនៅពេលរាត្រី :** ចាប់ពីម៉ោង ៦ ល្ងាច ដល់បិតហាង ជូនភេសជ្ជៈពិសារដោយឥតគិតថ្លៃ (ពិសារយ៉ាងតិច **$20**)

**ពិសេសដោយម្ចាស់ហាង:** មានចុះតម្លៃ **10%** លើម្ហូបអាហារថ្ងៃត្រង់ ឬល្ងាច បើលោកអ្នកបង្ហាញប័ណ្ណពាណិជ្ជកម្មយើងដល់អ្នកគិតលុយ

**Nightly Special:** 6pm 'til Closing: FREE drinks with every meal ($20 minimum order)
**Manager Special:**
Take 10% off meal (Lunch & Dinner) when your present this advertisement



**Manager Special :**
-10% OFF
LUNCH & DINNER
**Present This Coupon**



*FreeLife*
*The Himalayan Goji Company®*



# the World's Most Powerful Anti-Aging Food

**ចំណីដែលទប់ទល់ជរាភាពដ៏ខ្លាំងជាងគេក្នុងលោក**
**គឺទឹកផ្លែឈើ "គោជី " នៃព្រៃហេមពាន្ត**

**HIMALYAN GOJI**
**Juice**



ការសម្គាត់នៃសុខភាពល្អរបស់ពួកអាស៊ីបានត្រូវរកឃើញ នារជ្ជកាលស្ដេចតាំងឆ្នាំ ៨០០ គ.ស ពលរដ្ឋនៃតំបន់មួយនៅព្រៃហេមពាន្តមិនព្រមចាស់-សក់ក៏មិនស-ធ្មេញក៏មិនបាក់-គេថា អ្នកស្រុកបានផឹកទឹកអណ្ដូងមួយដែលមានដើម "គោជី "ដុះជុំវិញ គេស្មានថា មានវត្ថុសក្ដិសិទ្ធអ្វីមួយជួយថែរក្សាពួកគេ ។ ទើបឥឡូវនេះ គេដឹកថា "គោជី " មានជីវជាតិពិសេសមួយឈ្មោះ POLYSACHARIDES ដែលពុំមាននៅផ្លែឈើឯណាទៀតសោះ ដែលជួយដល់ប្រព័ន្ធការពារខ្លួនរបស់មនុស្សបាន ។

បើចង់បាន Goji មកពិសារសូមជាវតាម www.forever.freelife.com
ឬក៏ទូរស័ព្ទលេខ : **(267) 253-3947**

SHARE THE SECRET

**TIME Magazine wrote :**

*" this year's breakout (Superfruit ) was the Himalyan Goji Berry, said to be a source of energy and longevity ".* To order, please visit the website at : **www.forever.freelife.com**

**Or please call (267) 253-3947 to order**



KHMER
KICK BOXING CENTER
មជ្ឈមណ្ឌលប្រដាល់ខ្មែរសេរី
កីឡានាំមកនូវកម្លាំងមាំមួន សុខភាពល្អ
ការពារជីវិតខ្លួនឯង
បង្កើតនូវមិត្តភាពគ្នា
OUMRY BAN
MASTER TRAINER
SELF-DEFENSE & FITNESS
តម្លៃនៃការហ្វឹកហាត់
-កុមារ 60 ដុល្លារ/ 1 ខែ (បូកទាំងតម្លៃចូលជា Membership)
-មនុស្សពេញវ័យ $110/1ខែ
(បូកទាំងតម្លៃចូលជា Membership)
KHMER KICKBOXING
Long Beach Kickboxing Center
Designed by khmer post
223 W. Anaheim St.
Long Beach, CA 90813 Cell:(562) 591-0533

(តមកពីទំព័រទី០១) # តុលាការសហព័ន្ធច្រាន...

របស់លោក ពៅ ស៊ីវន និង ទិត្យ ស៊ីផាន់ បានបន្តប្តឹងនោះ ត្រូវបានបញ្ជូនត្រឡប់មកកាន់តុលាការកំពូលរដ្ឋ California វិញ ដើម្បីឱ្យ តុលាការថ្នាក់រដ្ឋមួយនេះ អនុវត្តទៅតាមសាលដីកាដែលបានសម្រេចរួចមកហើយ ។

ការច្រានចោលដោយបញ្ជូនត្រឡប់មកកាន់តុលាការកំពូលនោះវិញ គឺធ្វើឡើងតាមរយៈលិខិតមួយនេះ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៨ ដែលខ្មែរប៉ុស្តិ៍ទទួលបានក្នុងន័យបញ្ជាក់ថា សុពលភាពនៃចំណាត់ការរបស់តុលាការកំពូលដែលបានដាក់លក្ខខ័ណ្ឌឱ្យគណៈកម្មការទាំងពីរត្រូវតែប្រើតួនាទីស្នងការទាំង៣នាក់ ក្នុងការគ្រប់គ្រងកិច្ចការវត្ត និងទ្រព្យសម្បត្តិ (KBA) រហូតដល់មានដំណោះស្រាយឱ្យមានអ្នកដឹកនាំតាមការបោះឆ្នោតមួយ ។

គណៈកម្មការវត្តចាស់របស់ ទិត្យ ស៊ីផាន់ ធ្លាប់បានបដិសេធមិនទទួលស្គាល់នូវសាលក្រមកាត់ក្តីរបស់តុលាការកំពូលក្រុង Long Beach ដោយបន្តពាក្យបណ្តឹងរបស់ខ្លួនទៅតុលាការឧទ្ធរណ៍ចំនួន២លើក ប៉ុន្តែត្រូវតុលាការមួយនេះបដិសេធចោលផងដែរ កាលពីប៉ុន្មានខែមុន ។

លោកនាយកគណៈកម្មការវត្តចាស់ ទិត្យ ស៊ីផាន់ បានប្រាប់ខ្មែរប៉ុស្តិ៍តាមទូរស័ព្ទកាលពីថ្ងៃទី១១ ខែកញ្ញា ថារូបគាត់ពុំទាន់បានឃើញលិខិតច្រានចោលពីតុលាការសហព័ន្ធនោះនៅឡើយទេ ។ ប៉ុន្តែតែលោកឆ្ងល់ថា ហេតុអ្វីបានជាតុលាការមិនធ្វើសវនាការមុនចេញលិខិតនោះ ។

ជម្លោះរឿងរ៉ាវវត្តកើតមានមកជិតមួយឆ្នាំក្នុងការ ប្តឹងប្តល់គ្នារវាងគណៈកម្មការ ព្រះសង្ឃ និងពុទ្ធបរិស័ទជា មួយគណៈកម្មការវត្តចាស់របស់លោក ពៅ ស៊ីវន និង ទិត្យ ស៊ីផាន់ ព្រោះតែការចោទប្រកាន់គ្នាទៅវិញ ទៅមកដែលគណៈកម្មការព្រះសង្ឃ និងពុទ្ធបរិស័ទបានចោទថា គណៈកម្មការចាស់ដឹកនាំកិច្ចការវត្តខុសច្បាប់ចំនួន១១ឆ្នាំ រំលោភបំពានលើព្រះសង្ឃ និងដូនជីប្រើប្រាស់ថវិកាមិនប្រក្រតីជាដើម ។ ចំណែកខាងគណៈកម្មការចាស់របស់ ទិត្យ ស៊ីផាន់ ធ្លាប់អះអាង នៅក្នុងសេចក្តីប្រកាសរបស់ខ្លួនថា ពួកគេកំពុងរងគ្រោះពីការរំលោភបំពានដណ្តើមទ្រព្យសម្បត្តិ និងប្រាក់សន្សំទុកសង់ព្រះវិហាររបស់វត្តពីសំណាក់ជនមួយក្រុម ។

ក្រុមពុទ្ធបរិស័ទ និងព្រះសង្ឃបានក្តៅក្រហាយក្រុមលោក ទិត្យ ស៊ីផាន់ ដែលបានយកទ្រព្យសម្បត្តិ និងលុយកាក់វត្តប្រគល់ទៅឱ្យ Church of Revelation កាលពីថ្ងៃទី៨ ខែមិថុនា ឆ្នាំ ២០០៨ ។

ប៉ុន្តែក្រុមលោក ទិត្យ ស៊ីផាន់ បដិសេធក្នុងសេចក្តីប្រកាសរបស់ខ្លួនថា មិនមែនជាការពិត ។

ស្នងការប្រាយ៉ិនបិនប្រាប់ខ្មែរប៉ុស្តិ៍ថា ស ឬខ្មៅ. ល្អ ឬអាក្រក់ វាមិនស្ថិតនៅលើការបរិហារគ្នានោះទេ គឺវាស្ថិតនៅលើបន្ទាត់នៃច្បាប់ វាមិនស្ថិតនៅលើការបំផ្លើងការពិតនោះទេ ពោលគឺតុលាការគេមានសុភវិនិច្ឆ័យច្បាស់លាស់ ។

ក្រុមអ្នកនិយមកណ្តាលដែលចង់ឃើញសន្តិភាពក្នុងផ្លូវពុទ្ធចក្រ និយាយថា ការនៅតែមានៈចិត្តឈ្នះ-ចាញ់ វារិតតែធ្វើឱ្យសង្គមខ្មែរមួយនៅតែបន្តការបែកបាក់ផ្លូវព្រះពុទ្ធសាសនាស្រុតចុះ ធ្វើឱ្យមនុស្សអស់ជំនឿចំពោះអ្នកដឹកនាំ ។

អ្នកនិយមកណ្តាលបន្តថា តាមពិតទៅបើគណៈកម្មការចាស់របស់ ទិត្យ ស៊ីផាន់ ទទួលយកការបោះឆ្នោត និងតាមការចាត់ចែងរបស់តុលាការ ឬក៏សម្របសម្រួលគ្នាតាំងពីដើមទីមុនការប្តឹងប្តល់វាចប់បាត់ទៅហើយ ។


ស្នងការ Bryant Ben (រូបថត ឯល ម៉ាន់ថា)







ទិដ្ឋភាពព្រះសង្ឃ និងពុទ្ធបរិស័ទធ្វើបាតុកម្មតវ៉ាចំពោះការយកវត្តទៅឱ្យ Church (រូបថតអង្គរបុរី)






បញ្ហាជម្លោះវត្តនេះ ត្រូវបានគេមើលឃើញថាមានក្រុមអ្នកទី៣នៅពីក្រោយខ្នងនៃគណៈ-កម្មការវត្តចាស់ គឺក្រុមលោក Peter Long, Richer San និង Dany Vong ដើម្បីប្រឆាំងគ្នាឈ្នះចាញ់ទៅនឹងក្រុមលោក សុទ្ធ ប៉ាលីន, ប្រាយ យ៉ិនបិន ដែលធ្លាប់ជាគូបដិបក្សគ្នាជារៀងរហូតមក Sic !។ ប៉ុន្តែប្រភពនេះ ខ្មែរប៉ុស្តិ៍មិនទាន់សន្និដ្ឋានថាប្រាកដនៅឡើយទេ យើងទុកឱ្យមិត្តអ្នកអានធ្វើការពិចារណាចុះចៀសវាងការប្រើប្រាស់កាសែតបរិហារកេរ្តិ៍ និងផ្ទុយពីវិជ្ជាជីវៈខ្លួន និងគ្មាន (ក.ក.ន) នៅពេលដែល ខ្មែរប៉ុស្តិ៍និយាយពីហេតុផលនៃរឿងរ៉ាវ ជម្លោះវត្ត IRAP គឺមានអ្នកសើចសប្បាយ និងមាន អ្នកមិនពេញចិត្តរហូតដល់ប្តឹងប្តល់ខ្មែរប៉ុស្តិ៍ទៀតផង Sic ! ។

នៅពេលខ្មែរប៉ុស្តិ៍ឈប់និយាយរឿងរ៉ាវវត្ត IRAP នៅលើទំព័រកាសែតបំណងប្រាថ្នាមិនចង់ឱ្យប៉ះពាល់ ឬអាប់ឱនដល់ផ្នែកព្រះពុទ្ធសាសនានោះ... បែរជាមានគេចោទថា ខ្មែរប៉ុស្តិ៍ ទទួលសំណូកលុយកាក់ពីបុគ្គលមួយចំនួន ! ។

ចម្លើយយុត្តិធម៌ គឺនៅលើមិត្តអ្នកអានពិចា-រណាតាមគតិយុត្តិ និងមានសុភាវគតិជាមនុស្ស ! ខ្មែរប៉ុស្តិ៍ឈរលើវិជ្ជាជីវៈ ដោយមិននាំខ្លួនឱ្យធ្លាក់ទៅរកអគតិ៤យ៉ាងដោយការសរសេរ ព្រោះតែភាពល្ងិតល្ងង់ ដោយការភ័យខ្លាច ដោយការស្អប់ ដោយការស្រឡាញ់នោះទេ ៕

**Reasons Why You Want to Put**
The Advertisement with the Khmer Post
In Philadelphia

**បុព្វហេតុដែលនាំឱ្យលោកអ្នកផ្សាយពាណិជ្ជកម្មនៅ "ខ្មែរប៉ុស្តិ៍"**

The Khmer Post is the only Cambodian media that available to reach out over 30,000 Cambodian readers who live in Philadelphia.



"ខ្មែរប៉ុស្តិ៍" គឺជាប្រព័ន្ធផ្សព្វផ្សាយខ្មែរតែមួយ ដែលចែកផ្សាយដល់អ្នកអានខ្មែរប្រមាណ ៣ ម៉ឺននាក់ កំពុងរស់នៅហ្វីឡាដែលហ្វីយ៉ា

One phone call away to grow your business, 20% discount when you sign up for a contract of year by calling this number (267) 253-3947.

លេខទូរស័ព្ទដែលធ្វើឱ្យពាណិជ្ជកម្មលោកអ្នករីកដុះដាល គឺ :
**(267) 253-3947**
យើងខ្ញុំចុះថ្លៃជូន ២០ % បើលោកអ្នកផ្សាយ ១ ឆ្នាំ

**Growing your business. Advertise yourself.**

## (តមកពីទំព័រទី០១) ដៃពីរទ្រទ្រង់ជីវិតសារព័ត៌មានមួយ

បណ្ដាញព័តិមានវិជ្ជាជីវៈជាបណ្ដាញទាក់ទងសេរី-សាធារណៈរបស់សហគមន៍ខ្មែរកើតចេញបានហើយប្រកបដោយគុណសម្បត្តិច្រើន តាមតម្រូវការខាងលិច ។ យើងបំរើលោកអ្នកអានជាខ្មែរជាកូនខ្មែររស់នៅបរទេស និងជាពលរដ្ឋក្នុងសហគមន៍ដោយរំពឹងថា លោកអ្នកនឹងក្លាយជា " **ដៃម្ខាងទៀត** " ដែលនឹងទទួលគាំទ្រជីវិតកូនខ្ចីរបស់សហគមន៍មួយនេះឱ្យរស់រានធាត់ធំទៀតបាន សូមលោកអ្នកគិតថា :

១. ស្នាដៃផលិតកម្ម " ខ្មែរប៉ុស្តិ៍ " នេះ គឺជាសាច់ឈាមដ៏ថ្លៃថ្លាផ្ទាល់របស់លោកអ្នក

២. សាច់ឈាមមួយដំណក់នេះ បានធ្វើឱ្យលោកអ្នកមានមោទនភាពស្មើមុន នឹងសហគមន៍ដទៃឯទៀតបាន

៣. សេចក្ដីស្រឡាញ់លើកូនខ្ចីអាយុមួយឆ្នាំនេះ នឹងបង្រៀនលោកអ្នកបានច្រើន នូវអ្វីដែលយើងមិនធ្លាប់ជួបប្រទះ

៤. មិនតែប៉ុណ្ណោះ លោកអ្នកបញ្ចេញថ្វីដៃនៃការណែនាំ ថែទាំ និងការពារត្រលប់ទៅវិញបានបង្ហាញដល់អ្នកដទៃ

៥. វានឹងធ្វើឱ្យលោកអ្នកមើលឃើញពីស្ថានភាពខ្លួនឯង ព្រមទាំងឃើញសហគមន៍ខ្លួន ដូចកញ្ចក់ឆ្លុះមើលលំអរខ្លួនប្រាណ

៦. ចរន្ត " ទៅ-មក " នៃព័តិមានយើងនឹងបន្ថយការព្រួយបារម្ភ ទំនាស់ កំហឹង... ដោយការប្រើសីលធម៌-ចំណេះ និងពិចារណា

៧. ចរន្តសីលធម៌នឹងបង្រួបបង្រួមចំនួនមនុស្សដែលគិតត្រូវ ឱ្យអាចរកគ្នាឃើញ ហើយនាំគ្នាទប់ស្កាត់ចរន្តអវិជ្ជាមាននៃសង្គម

៨. " ត្រូវការ " ក្នុងពាណិជ្ជកម្ម ឬមានគំនិតថ្មីអ្វីមួយ ឬឥតការងារធ្វើ វានឹងនាំឱ្យលោកអ្នកជួបនឹងអ្នក " ចង់បាន " យ៉ាងងាយស្រួល

៩. " ខ្មែរប៉ុស្តិ៍ " អាចនឹងផ្ដល់អំណាចជ្រើសតាំងតំណាងខ្មែរសម្រាប់សហគមន៍នៅ ស.រ.អា បាន

១០. ហើយវាក៏ជាសមុទ្រមិនចេះរីងស្ងួន នៃការកំសាន្តចិត្ត ដែលយើងត្រូវការប្រចាំថ្ងៃទៀតផង

" ខ្មែរប៉ុស្តិ៍ " នៅពេលដែលបានគោរពវិជ្ជាជីវៈគ្រប់គ្រាន់ វានឹងបំពេញតួនាទីយ៉ាងតិចក៏១០យ៉ាងខាងលើនេះ ជូនលោកអ្នកបានជាប្រាកដ ។ បើប្រៀប " ខ្មែរប៉ុស្តិ៍ " ទៅនឹងប្រព័ន្ធផ្សព្វផ្សាយជាភាសាខ្មែរនៅកម្ពុជា និងនៅបរទេសផ្សេងៗទៀតបានយ៉ាងងាយស្រួល ។ ថ្វីដ្បិតតែនៅក្មេងខ្ចី " ខ្មែរប៉ុស្តិ៍ " បានយកជ័យជំនះបានក្រៃលហើយលើទឹកចិត្តសហគមន៍ខ្មែរ ឬអាស៊ី ឬអាមេរិកាំងនៅជុំវិញយើង និងក្នុងចំណោមអង្គការឯកជន ឬ សាធារណៈមិនយកកំរៃនានា យើងជឿថា ដោយ សារតែការគោរពវិជ្ជាជីវៈនេះជោគជ័យនឹងកើន ឡើងខ្ពស់ថែមទៀតជាមិនខាន ។ តើវិជ្ជាជិវៈនៃអ្នកសារព័តិមាននោះជាអ្វីទៅ ? គឺជា :

-ភាពឯករាជ្យរបស់អង្គការសារព័តិមាន " ខ្មែរប៉ុស្តិ៍ " ឱ្យឆ្ងាយពីលុយ ឬរង្វាន់ទុច្ចរិតសម្រាប់បង្កើតអត្ថបទ ឱ្យឆ្ងាយពីការគម្រាមកំហែងនៅលើការសរសេរ ឱ្យឆ្ងាយពីការស្រឡាញ់ ឬស្អប់របស់អ្នកសរសេរ ជាពិសេសត្រូវបំភ្លេចខ្លួនឯងពីអត្ថបទឱ្យបាន ។

-ប្រកាន់សីលធម៌នៃអ្នកសារព័តិមាន ឱ្យទាល់តែក្លាយជាមាគ៌ានៃជីវិតធម្មតាបាន ដូចជា មិនលួច មិនបំភ្លៃ មិនបំបាត់ព័តិមាន ដូចជា មិនទាន់ជឿ ដោយគ្រាន់តែបានឃើញ ឬឮម្ដង ជីកកកាយឱ្យជ្រៅ ស្រាវជ្រាវឱ្យទូលាយ ដូចជាការពារកុមារ ឬពិការភាពនៃអ្នករងគ្រោះ ដូចជាឱ្យឱកាសតួបដិបក្ខអាចការពារខ្លួនបាន ដូចជាមិនផ្សាយពាក្យចចាមអារាម...។ល។

-សោភ័ណភាពនៃការសរសេរអត្ថបទ នៃការប្រើអត្ថបទពិសេសគ្មានពីរ នៃការជ្រើសរើសអត្ថបទមកផ្គុំគ្នា នៃការរៀបទំព័រ នៃការថតរូប នៃការផ្គុំព័តិមានជាមួយពាណិជ្ជកម្ម ក៏ជាផ្នែកមួយនៃសីលធម៌របស់ " ខ្មែរប៉ុស្តិ៍ " ដែរ ។

គុណភាពល្អប្រសើរនៃ " ខ្មែរប៉ុស្តិ៍ " បានមកពីបទពិសោធន៍ច្រើនឆ្នាំនៃអ្នកសរសេរបន្ថែមដោយ កាសិក្សាទៅលើថ្នាលរៀងរាល់ពីរសប្ដាហ៍នៃអង្គប្រជុំអ្នកនិពន្ធ និងបន្ថែមដោយការស្ដាប់ពាក្យទិទាន ។ អ្នកវាយអក្សរពុម្ព អ្នកកែរអក្ខរាវិរុទ្ធ អ្នករៀបគំនូរពាណិជ្ជកម្ម រាប់ទាំងអ្នកចែកផ្សាយ សុទ្ធសឹងជាអ្នកមានទេពកោសល្យខ្ពស់ចូលមករួមធ្វើការយ៉ាងប្រឹងប្រែង ។ នៅមានបុគ្គលិកសំខាន់មួយផ្នែកទៀត គឺផ្នែកពាណិជ្ជកម្ម និងផ្នែកការគ្រប់គ្រងការជាវកាសែត ដែលដើរខ្វាត់ខ្វែងតាមទីក្រុង និងជនបទ ដើម្បីបំរើប្រយោជន៍រួមរបស់ " ខ្មែរប៉ុស្តិ៍ " ផង របស់ពាណិជ្ជកម្មផង និងរបស់អ្នកអាននៅឆ្ងាយៗផង ។ កាសែតបានចេញផ្សាយក្នុងមួយឆ្នាំនេះ ប្រកបដោយការប្រឹងប្រែងយ៉ាងខ្លាំង តែការគាំទ្រមកវិញ ទាំងពាណិជ្ជកម្ម ទាំងអ្នកអានមានទំហំតូចទាបនៅឡើយពុំទាន់អាចឱ្យ " ខ្មែរប៉ុស្តិ៍ " រស់បានជាម្ចាស់ការ មានលំនឹងរឹងមាំនៅឡើយទេ ។

" ខ្មែរប៉ុស្តិ៍ " ត្រូវការឱ្យលោកអ្នកចូលមកជួយគាំទ្រ ជាវប្រចាំខែឱ្យបានច្រើនគ្នា ( មួយខែ ៥ដុល្លារ) ពាណិជ្ជកម្មស្ដីពីកិច្ចការរកស៊ី ផ្សព្វផ្សាយទិញលក់ដូររបស់តូចធំ រកបងប្អូន ឬបញ្ជូនសារផ្សេងតាមកាសែត ។ លោកអ្នកធ្វើយ៉ាងនេះបាន គឺច្បាស់ជាមិនអានកាសែតដោយសារអ្នកដទៃទៀតទេ ហើយនឹងមានមោទនភាព និងទទួលឈ្មោះថា បានចូលរួមកសាងសហគមន៍ខ្លួនឯងយ៉ាងសកម្មទៀត ។ យើងក៏សូមថ្លែងអំណរគុណ ដល់លោកអ្នកដែលបានយល់ពីទស្សនៈនៃរបៀបគាំទ្រដល់ ប្រព័ន្ធផ្សព្វផ្សាយខ្មែរនៅបរទេស ហើយបានប្រើយើងខ្ញុំឱ្យជួយផ្សាយអ្វីផ្សេងៗ ឬក៏ជួយជាវកាសែត ឬជួយផ្សាយពីវត្តមាននៃកាសែតខ្មែរ កន្លងមកនេះ គឺប្រាកដជាស្មារតីស្នេហាជាតិ និងវប្បធម៌ជាតិដ៏ខ្ពង់ខ្ពស់កាត់ជាតម្លៃមិនបានទេ ៕

## (តមកពីទំព័រទី០៧) ថ្ងៃបុណ្យនៃពួកប្រេត_អសុរកាយ...

និងជាឱកាសឱ្យពួកពុទ្ធបរិស័ទបានជួបជុំគ្នាទៀតផង ។ ចំណែកឯម្ចាស់ទានក៏ទទួលបានផលបុណ្យកុសលកាន់តែច្រើនមួយកំរិតថែមទៀតនៅពេលបច្ចុប្បន្ន និងទៅអនាគតជាតិ ។

នៅថ្ងៃដាក់បិណ្ឌនេះ អ្នកស្រុកបានធ្វើបាយសម្លរួមគ្នានៅតាមវត្ត និងនៅតាមផ្ទះរៀងៗខ្លួន


ប្រជាពលរដ្ឋកំពុងរាប់បាត្រឧទ្ទិសកុសលជូនដល់បុព្វការីជន

មានវេចនំចេក នំគម នំអន្សម និងនំចិន ព្រមទាំងគ្រឿងភេសជ្ជៈ និងទេយ្យទានមួយចំនួនទៀតសំរាប់សំរាប់ប្រគេនចំពោះព្រះសង្ឃតាមវេនរៀងៗខ្លួន ។

អ្នកស្រី លី មុយអេង រស់នៅទីក្រុងភ្នំពេញបានឱ្យដឹងថា នៅក្នុងរដូវបុណ្យភ្ជុំបិណ្ឌម្ដងៗ គាត់តែងតែទៅវត្តធ្វើបុណ្យទាន ឧទ្ទិសកុសលឱ្យជីដូនជីតាមិនដែលខកខាននោះទេ លើសពីនេះ អ្នកស្រី ក៏បានផ្ញើលុយកាក់ ឱ្យឪពុកម្ដាយនៅស្រុកកំណើត សំរាប់ធ្វើបុណ្យ ថែមទៀត លុះដល់ថ្ងៃភ្ជុំធំ ទើបទៅធ្វើបុណ្យនៅឯស្រុកកំណើតជួបជុំបងប្អូន និងសែនព្រេនតាមទំនៀមទំលាប់ប្រពៃណីព្រះពុទ្ធសាសនា ។

អ្នកស្រី លី មុយអេង បានបន្តថា បុណ្យភ្ជុំបិណ្ឌនេះមានការសារសំខាន់ខ្លាំងណាស់ ដែលពុទ្ធបរិស័ទនាំគ្នាទៅវត្តធ្វើបុណ្យមិនដែលខកខានទេ សូម្បីតែបងប្អូនរបស់គាត់ដែលរស់នៅអាមេរិកក៏ពួកគាត់មកធ្វើបុណ្យដែរ ។ ប៉ុន្តែបើពួកគាត់មិនបានមកក៏ផ្ញើលុយកាកសំរាប់ធ្វើបុណ្យឧទ្ទិសកុសលឱ្យជីដូនជីតាមិនដែលខកខានឡើយ ។

ទាក់ទិនទៅនឹងប្រវត្តិនៃការដាក់បិណ្ឌនេះ បើតាមគម្ពីរសាសនាបានបញ្ជាក់ថា អស់រយៈកាលដ៏យូរលង់ គ្រួសាររបស់ព្រះ បាទពិម្ពិសារបានធ្វើបុណ្យ ប៉ុន្តែ ទទួលទានមុនព្រះ សង្ឃ លុះពេលស្លាប់ ទៅ កើតជាប្រេតរងទុក្ខលំបាកវេទនា គ្មានអាហារទទួលទាន ។ ពួកប្រេតទាំងអស់ នោះបានរង់ចាំព្រះត្រាស២ព្រះអង្គកន្លងផុតទៅរហូតដល់ព្រះសមគោត្តមបានត្រាស់ ក៏នាំគ្នាមកសួរទៀត ដើម្បីរកអាហារទទួលទាន ។ ព្រះសម្មាសម្ពុទ្ធបានត្រាសថា "ចាំព្រះបាទពិម្ពិសារជាញាតិរបស់អ្នកឱ្យទានដល់តថាគតនឹងញ៉ាំងឱ្យអាហារនេះបានសំរេចដល់អ្នកទាំងអស់គ្នា " ។ ពេលព្រះបាទពិម្ពិសារធ្វើបុណ្យយ៉ាងអធិកអធមហើយ ប៉ុន្តែមិនបានឧទ្ទិសកុសលឱ្យពួកប្រេតយប់ឡើងពួកប្រេតក៏មកយំទ្រហឹង ក្បែរបន្ទប់ព្រះអង្គទៀត ។

ព្រះបាទពិម្ពិសារឃើញហេតុភេទនេះ ក៏យាងទៅសួរព្រះមហាក្សត្រ ហើយព្រះអង្គមានបន្ទូលថា "ពួកប្រេតជាសាច់ញាតិរបស់ព្រះអង្គ ត្រូវបានអាហារបរិភោគក្នុងសាសនាតថាគត" ។ ប៉ុន្តែពេលព្រះអង្គធ្វើបុណ្យមិនបាន ឧទ្ទិសកុសលឱ្យទើបមាន ឮសំលេងស្រែកយំលាន់ឡើង បែបនេះ ។

ក្រោយពីព្រះបាទពិម្ពិសារ រៀបចំពិធីនេះរួចឥទ្ធិពលព្រះពុទ្ធ សាសនាក៏ជិតដាមក្នុងអារម្មណ៍ពុទ្ធសាសនិកជារៀងរហូត។ ចំណែកនៅប្រទេសកម្ពុជារៀបចំពិធី ដាក់បិណ្ឌក្នុងរជ្ជកាលព្រះបាទអង្គ ឌួង នាសម័យអង្គរ ហើយបានចាក់ឫសសាយភាយដល់សព្វថ្ងៃនេះ ៕



# ការិយាល័យមេធាវី លិនហ្សេ ដ័រង

# LAW OFFICE OF LINDSAY DOERING

**ទទួលការពារផលប្រយោជន៍លោកអ្នកករណីនានាតាមផ្លូវច្បាប់ដូចជា :**

- ករណីបើករបរពាណិជ្ជកម្ម នឹងផ្ទេរប្រាក់ក្នុងមុខជំនួញ
- ករណីទិញលក់អចលនវត្ថុ ដូចជា: ផ្ទះសម្បែង ដីធ្លីជាដើម ។
- ករណីគ្រោះថ្នាក់រថយន្ត ឬគ្រោះថ្នាក់នៅកន្លែងធ្វើការ
- ករណីអន្តោប្រវេសន៍
- ឬករណីឧក្រិដ្ឋកម្ម ។ល។



**ធ្លាប់មានបទពិសោធន៍ខ្ពស់ ផ្ដល់សេវាជូនតាមវិជ្ជាជីវៈ ហើយតម្លៃក៏សមរម្យទៀតផង យើងអាចមានអ្នកបកប្រែភាសាជូនលោកអ្នកបាន ។**

General practice law office handling matters in :

Corporations and business transations
Read estate
Car Accidents
Work place injury
Immigration
Criminal fefense
Experienced, professional service and reasonable rate. translator available.

Office: (215) 667-8118 2301 Delancey place, Philadelphia PA 19103
Cell : (215) 840-1364 Email : lindsaydoering@yahoo.com

## (តមកទំព័រទី១១) អ្នកស្រុកនាំគ្នាស្រែកយំ...

**-ក្រុងភ្នំពេញ** ៈប្រជាពលរដ្ឋដែលរស់នៅបុក បឹងកក់ និងព័ទ្ធជុំវិញប្រមាណ៤២០០គ្រួសារលើ ទំហំដី១៣៣ហិកតា កំពុងតែប្រឈមមុខនឹង ការបង្ខំចាកចេញពីលំនៅឋានរស់ខ្លួន ក្នុងសំណង ជំងឺចិត្ត៨០០០ដុល្លារ និងប្រាក់ខែ២លានរៀល ។

តំបន់ជំលោះនេះត្រូវបានអាជ្ញាធរក្រុង ភ្នំពេញ ជួលឱ្យក្រុមហ៊ុនកូរ៉េឈ្មោះថា "ស៊ូកា គូអ៊ីង" រយៈពេល៩៩ឆ្នាំ ដែលមានទឹកប្រាក់៧៩ លានដុល្លារ ដើម្បីអភិវឌ្ឍន៍តំបន់រមណីយដ្ឋាន ទេសចរណ៍វប្បធមិ និងសំណង់អគ្គារពាណិជ្ជកម្ម ខ្ពស់ៗ ។

អភិបាលរងក្រុង ម៉ាន់ ឈឿន បានឱ្យដឹង ថា យើងមិនទុកបឹងនេះឱ្យធំពេកទេ ដែលជា ហេតុបង្កឱ្យមានភាពអនាធិបតេយ្យដូចសព្វថ្ងៃ នេះទេ ហើយយើងត្រូវអភិវឌ្ឍន៍ដីនេះឱ្យក្លាយ ជាទីក្រុងគង់ ក្នុងតំបន់អាស៊ីអាគ្នេយ៍ ។

អភិបាលរងក្រុងបានឱ្យដឹងថា គំរោងអភិវឌ្ឍន៍ បឹងកក់ជាគោលការណ៍របស់រាជរដ្ឋាភិបាល គឺ អភិវឌ្ឍន៍នៅនឹងកន្លែង ។ ប៉ុន្តែដោយសារមាន ការទាមទារខ្លាំងពេក ពេលនេះយើងសំរេចឱ្យ ក្នុងមួយគ្រួសារ៨០០០ដុល្លារ និងប្រាក់២លាន រៀល ជាថ្នូរនឹងការចាកចេញ ហើយបើពួកគាត់ មិនយកផ្ទះមួយខ្នងនៅជាយក្រុងចំងាយប្រមាណ ២០គីឡូម៉ែត្រ រង់ចាំផ្ទះសង់ហើយអាចយកបាន ។

ទោះបីជាមានការដោះដូរគោលនយោបាយ បែបនេះក្តី ប្រជាពលរដ្ឋដែលរស់នៅទីនេះធ្វើ ការទាមទារឱ្យមានការសងជំងឺចិត្តឱ្យបានសមរម្យ បើតំលៃដូចខាងលើ គឺពួកគាត់មិនព្រមចាក ចេញនោះទេ ។ អ្នកស្រី ទូច ស៊ីផុល អ្នកប្រកប របរផ្ទះសំណាក់លើផ្ទៃបឹង បានឱ្យដឹងថា គាត់ រស់នៅទីនេះប្រកបរបរតាំងពីឆ្នាំ១៩៨៩ម្លេះ បើឱ្យរុះរើផ្ទះចេញមិនដឹងជាទៅទីណាទេ គឺចង់ ឱ្យក្រុមហ៊ុន ឬអាជ្ញាធរជូនសំណងគាត់២៣ម៉ឺន ដុល្លារទើបគាត់ព្រមចាកចេញ ។

អ្នកស្រី បេ ផារី តំណាងសមកគមន៍ ដែល យកពាក្យបណ្តឹងទៅដាក់នៅសាលាក្រុង បាន សំដែងនូវការមិនទុកចិត្តចំពោះអាជ្ញាធរ ដោយ បញ្ជាក់ថា អាជ្ញាធរគ្រាន់តែធ្វើជាសាក្សីបាន ហើយ គឺពួកគាត់ចង់ជួបម្ចាស់ក្រុមហ៊ុនផ្ទាល់ ។

ការចាក់ដីលប់បឹងកក់នេះ លោក ម៉ុក ម៉ារ៉េត រដ្ឋមន្ត្រីក្រសួងបរិស្ថានធ្លាប់មានប្រតិកម្ម យ៉ាងខ្លាំងថា អាចបង្កឱ្យប៉ះពាល់ដល់បរិស្ថាន ប្រសិនបើយើងមិនធ្វើកិច្ចសហការឱ្យបានល្អិត ល្អន់ជាមួយជំនាញនោះ ។ ប៉ុន្តែខាងអាជ្ញាធរ ក្រុងភ្នំពេញបានឆ្លើយតបថា មិនមានបញ្ហានោះ ទេ ពីព្រោះគេបានសិក្សារួចរាល់ហើយ ។

ចំណែកប្រជាពលរដ្ឋនៅដីក្រហម សង្កាត់ ទន្លេបាសាក់ ខណ្ឌចំការមន ចំនួន១៤៦៥គ្រួសារ ត្រូវសមត្ថកិច្ចប៉េអឹម និងប៉ូលិសចុះរុះរើផ្ទះ សម្បែងរបស់ពួកគាត់កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧ ហើយរហូតដល់សព្វថ្ងៃពួកគាត់នៅ តែប្រឈមមុខដាក់គ្នា ប្តឹងប្តល់ឡើងតុលាការ ដោះស្រាយមិនទាន់ចេញ កំពុងតែមានការព្រួយ បារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន ។

ក្នុងឧប្បហេតុនេះ ស្ត្រីឈ្មោះ ឡុង ខុម អាយុ ៤០ឆ្នាំ និងឈ្មោះ និរតី ត្រូវប៉ូលិសចាប់ខ្លួន ដាក់ ខ្នោះបញ្ជូនទៅថ្នាក់លើពីបទរារាំងសមត្ថកិច្ច មិនឱ្យរុះរើផ្ទះសម្បែង ហើយអ្នកស្រុកលើកគ្នា ទៅតវ៉ានៅមុខរដ្ឋសភាឱ្យជួយដោះស្រាយ ប៉ុន្តែ គ្មានលទ្ធផលអ្វីសោះ ។

អ្នកស្រុកភាគច្រើនដែលត្រូវអាជ្ញាធរ បណ្តេញចេញពីលំនៅឋានដែលធ្លាប់រស់នៅ ត្រូវ គេចែកដីឱ្យក្នុងមួយគ្រួសារទំហំ៥ម៉ែត្រ × ១៥ ម៉ែត្រ រស់នៅជាយក្រុង តាំងពីឆ្នាំ២០០២ គឺ ចំណុចភូមិសែនសុខ ក្នុងសង្កាត់ឃ្មួញ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។

អង្គការសិទ្ធិមនុស្សលីកាដូ បានចេញសេចក្តី ថ្លែងការណ៍កាលពីថ្ងៃទី២៩ ខែឧសភា ថា វិបត្តិ ទំនាស់ដីធ្លីកាន់តែធ្ងន់ធ្ងរ ដោយសារអ្នកភូមិមក ពីខេត្ត៥ បានមកពីស្រុកកំណើតរបស់ខ្លួន ដើម្បី មកតវ៉ានៅក្រុងភ្នំពេញ ។ ក្នុងនោះខេត្តកំពត ៧០នាក់ ខេត្តបាត់ដំបង២៥នាក់ ខេត្តបន្ទាយ-មានជ័យ២០នាក់ ខេត្តព្រះវិហារ៣នាក់ ដែល ពួកគេតំណាងឱ្យប្រជាពលរដ្ឋជាង១០០០នាក់ ។

ក្នុងចំណោមពួកគេ គឺអ្នកបាត់ដំបងធ្វើដំណើរ ដោយជើងរយៈពេលជាង៤៨ម៉ោងទើបដល់ ភ្នំពេញ ឱ្យ ហ៊ុន សែន ជួយអន្តរាគមន៍ ពីព្រោះ ពួកគាត់គ្មានជំរើស ។

លោកស្រី ខែក ហ្គាឡាប្រ៊ូ ប្រធានអង្គការ លីកាដូបានបញ្ជាក់ថា អ្នកស្រុកពុំគួរមកភ្នំពេញ ដើម្បីសុំយុត្តិធម៌ និងដំណោះស្រាយទេ ដោយ សារគ្មានជំរើស ។ម្យ៉ាងទៀតពួកអាជ្ញាធរមិន បានយកចិត្តទុកដាក់ពីរឿងរបស់ពួកគាត់បានប្តឹ ង ឱ្យដោះស្រាយ ។

ទំនាស់ដីធ្លីកើតមានមិនចេះចប់នេះត្រូវបាន មន្ត្រីកម្មវិធីសិទ្ធិមនុស្សបញ្ជាក់ថា បណ្តាលមក ពីរដ្ឋផ្តល់ដីសម្បទានឱ្យក្រុមហ៊ុនឯកជនពុំបាន សិក្សាច្បាស់លាស់ ធ្វើឱ្យប៉ះពាល់ដល់ដីអ្នកស្រុក ហើយពួកឈ្មួញបានទិញដីទុកច្រើន ធ្វើឱ្យកសិករ បាត់បង់ដីធ្វើស្រែជាបន្តបន្ទាប់ ។

ករណីទំនាស់ដីធ្លីនេះ អ្នកស្រុកបានដាក់ពាក្យ ពាក្យបណ្តឹងជាបន្តបន្ទាប់ទៅអាជ្ញាធរ និង សមត្ថកិច្ចគ្រប់មូលដ្ឋាន ប៉ុន្តែការដោះស្រាយ មានភាពយឺតយ៉ាវ ធ្វើឱ្យពួកគាត់អស់ជំនឿ ហើយនាំគ្នារត់មកភ្នំពេញឱ្យអ្នកមានអំណាច ជួយអន្តរាគមន៍ ។

យោងតាមឯកសារស្តីពីដីសម្បទានបាន បង្ហាញថា ដីសម្បទានជាង១លានហិកតា ត្រូវ រដ្ឋាភិបាលប្រគល់ឱ្យក្រុមហ៊ុនក្នុងស្រុក និង ក្រៅស្រុកធ្វើវិនិយោគទុនរយៈពេលជាង៩០ឆ្នាំ ចំណែកឯប្រជាពលរដ្ឋត្រូវគេបណ្តេញចេញ ឱ្យរស់នៅយ៉ាងវេទនា ក្នុងនោះមានដីប្រហែល ១០ម៉ឺនហិកតា បានត្រូវបានដោះស្រាយឱ្យអ្នក ស្រុកដែរ ។

ប្រភពដដែលបញ្ជាក់ថា ប្រជាពលរដ្ឋជាង ៥០០០គ្រួសារត្រូវបណ្តេញចេញពីលំនៅឋាន ចាប់ខ្លួនជិត២០០នាក់ ដែលករណីនេះកើនខ្ពស់ ជាងឆ្នាំកន្លងទៅ ។ដោយសារតែទំនាស់ដីធ្លីមាន កំណើនខ្ពស់ ហើយអាជ្ញាធរគ្មានសមត្ថភាពដោះ ស្រាយនោះ នាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន បាន ប្រកាសរំលាយអាជ្ញាធរដោះស្រាយដីធ្លីចោល ដែល លោក សុខ អាន ជាប្រធាន ។

លោក សុខ អាន ត្រូវបានគេមើលឃើញថា ជាដៃស្តាំរបស់ ហ៊ុន សែន និងមានអំណាច តួនាទី ធ្វើជាប្រធានស្ទើរគ្រប់ស្ថាប័នក្នុងប្រទេសកម្ពុជា ៕

## (តមកទំព័រទី២១) ជីវិតរបស់តារិយាអធិរាជសម្លេងមាស...

គំនិតបើកសមាគមនេះឡើង។

**• តើបទចម្រៀងឧត្តមដួងចិត្តគាត់ផ្តើម ច្រៀងនៅពេលណា ? មូលហេតុអ្វីបានជាគាត់ តែងបទនេះឡើង ?**

បទនេះខ្ញុំចាំច្បាស់ណាស់ កាលពី៥០ ឆ្នាំមុន ក្រោយពីខ្ញុំ និងស្វាមីរបស់ខ្ញុំ ក្រោយពីរៀបការ ជាប្តីប្រពន្ធហើយក៏បណ្តើរគ្នាមករស់នៅភ្នំពេញ ។ ក្រោយពីរួមរស់ជាមួយគ្នា ហើយខ្ញុំក៏មានផ្ទៃ ពោះកំណើតកូនច្បងគឺឈ្មោះ ស៊ីន យុទ្ធនា នៅ ស្ទឹងត្រែង សព្វថ្ងៃនៅពេលនោះកំណើត កូន ជិតគ្រប់ខែ ក៏មានការព្រួយបារម្ភយ៉ាងខ្លាំង ណា មួយជាកូនដំបូង ដោយម្យ៉ាងត្រូវនៅសំរាលកូននៅ ស្រុកឆ្ងាយពីប្តីណាមួយខ្លាចអាំងភ្លើងក្តៅខ្លួង ។ គ្រាន់តែឮពាក្យប្រពន្ធបារម្ភដូច្នេះ ពេលនោះស្វាមី របស់ខ្ញុំបានសន្យាថា "កូនកុំព្រួយអីចាំបងតែង ចម្រៀងមួយបទនៅពេលអូនអាំងភ្លើងក្តៅខ្លួង " ដូចអ្វីដែលតាមសន្យានោះ ពិតមែនក្រោយពេល កំណើតកូនស្រីច្បងនោះ រួចបទចម្រៀងឧត្តមដួង ចិត្តក៏បានឮតាមវិទ្យុជាតិមែនដូចការសន្យារបស់ គាត់មុនពេលខ្ញុំធ្វើដំណើរត្រឡប់មកស្រុកកំណើត ដើម្បីសំរាលកូន ។

**• ប៉ុន្តែក្រោយមកខ្ញុំឮគេថា អ៊ុំស្រីបែកគ្នាមួយ រយៈរួចទើបបានជួបគ្នាវិញ ស្វាមីរបស់អ៊ុំស្រី ក៏ ច្រៀងបទចំប៉ីសៀមរាប តើពិតឬទេ ហើយ មូលហេតុអ្វីបានគាត់ច្រៀងបទនេះ ?**

ចាស! ចំពោះរឿងនេះខ្ញុំមិនលាក់លៀម អីទេ ក្នុងរឿងនេះគឺជារឿងពិតណាស់ ហើយ បន្ទាប់ពីខ្ញុំសំរាលបានកូនស្រីបានកូនស្រីច្បង គឺពួកខ្ញុំពីរនាក់ប្តីប្រពន្ធបានបែកគ្នារយៈពេល ៧ឆ្នាំ ។ ការដែលបណ្តាលឱ្យពួកខ្ញុំបែកមួយ រយៈនេះក៏មកពីស្វាមីរបស់ខ្ញុំមាន ស្រីផ្សេងទៀត ពេលនោះខ្ញុំខឹងក៏បណ្តាលឱ្យបែកគ្នាទៅ ។ ប៉ុន្តែ ក្រោយមកចាស់ទុំខាងគាត់(ប្តី)ក៏មកសុំឱ្យជា នាគ្នាវិញ ក៏ជួបគ្នាវិញទៅក្រោយជួបជុំគ្នាវិញ ហើយ ស្វាមីខ្ញុំក៏នាំខ្ញុំ និងកូនទៅលេងខេត្ត សៀមរាបអង្គររួចក៏ច្រៀងបទចំប៉ីសៀមរាប ទុកជាចំណងចិត្តនៃការជួបគ្នាម្តងទៀតរវាង ខ្ញុំ និងគាត់ ។

**• មូលហេតុអ្វីបានជាអ៊ុំស្រីមិនមកនៅភ្នំពេញ ?**

មូលហេតុបានជាខ្ញុំមិនមកនៅភ្នំពេញជា មួយកូន ឆាយ៉ា គឺខ្ញុំសព្វថ្ងៃចាស់ណាស់ហើយ មិនចង់មកចោលស្រុកកំណើតណាមួយ ឆាយ៉ា មានជីវភាពលំបាកខ្លះៗដែរ ម្លោះហើយមិន ចង់ឱ្យបន្ទុកមួយទៀតធ្លាក់លើ ឆាយ៉ាកាន់តែ ធ្ងន់ ទើបខ្ញុំសំរេចចិត្តនៅទីនេះ(ស្ទឹងត្រែង) តែខ្ញុំឧស្សាហ៍ចុះឡើងមកលេងញឹកញាប់ដែរ ។

**• មកទល់ពេលនេះស្វាមីអ៊ុំស្រីបានស្លាប់ ចោលអ៊ុំស្រីជិត៣០ឆ្នាំហើយ តើអ៊ុំស្រីបានដឹង កន្លែងគាត់ស្លាប់នៅទីណាហើយឬនៅ ហើយ អ៊ុំស្រីមានបានមកធ្វើបុណ្យដល់កន្លែងនោះ ដែរឬទេ ?**

នៅក្នុងរឿងនេះ គឺខ្ញុំបានដឹងអាស្រ័យទៅ លើ ឆាយ៉ា គេជាអ្នកស្រាវជ្រាវ ហើយខ្ញុំក៏ពុំដែល បានសួរនាំ ឆាយ៉ា ដែរ នៅក្នុងរឿងរកកន្លែង ឪពុករបស់គេដែលខ្មែរ ក្រហមយកទៅសម្លាប់ ចោល នៅទីណានោះ ។ ចំណែក រឿងធ្វើបុណ្យ គឺខ្ញុំបានធ្វើបុណ្យ ឧទ្ទិសទៅឱ្យគាត់ញឹកញាប ណាស់ស្ទើរតែមួយឆ្នាំម្តង តាមលទ្ធភាពខ្ញុំ និង កូនចៅ ធ្វើទៅបាន ៕


WORC

Women's Opportunities Resource Center

លើកដំកើងសង្គម និងសេដ្ឋកិច្ចឱ្យរស់គ្រប់គ្រាន់ខ្លួនឯងបាន

*ជនភៀសខ្លួន
*ជនសុំសិទ្ធិជ្រកកោន

សូមសួររកឈ្មោះ : សុបិន




មជ្ឈមណ្ឌលផ្តល់ឱកាស ឱ្យមានធនធានរបស់ស្ត្រី
(267) 253-3947 និយាយខ្មែរ

ជួយដល់ជនភៀសខ្លួន / ជនសុំសិទ្ធិជ្រកកោន

គណនីសន្សំប្រាក់ក្នុងគ្រួសារ

✔ អ្នកសន្សំបាន $ 2,000
✔ WORC នឹងជួយអ្នក $ 2,000
$ 4,000

អ្នកត្រូវធ្វើ :

ទី១- ហៅរក (267) 253 3947 ដើម្បីផ្តើម
ទី២- សន្សំប្រាក់ $10ដុល្លារមួយសប្តាហ៍ពី ៦-១២ ខែ
ទី៣- ទៅសិក្សាពីគណនីថ្នាក់បង្រៀនឥតយកកំរៃ
ទី៤- WORC បង្គ្រប់ជួយស្មើប្រាក់សន្សំបាន

អាចប្រើប្រាក់សំរាប់ :

-ការសិក្សា
-ទិញផ្ទះ
-ផ្តើម ឬពង្រីកមុខរបរ

* តម្លៃចុះឈ្មោះ = $40 / តម្លៃប្រឡងជាប់ = $50
-គ្មានកំរៃអ្វីទៀតទេ

ហានី (215) 564 5500 និយាយភាសាអង់គ្លេស

2010 Chestnut Street
Philadelphia, PA 19103
Telephone: (215) 564-5500 • Facsimile: 215-564-0933
Website: www.worc-pa.com



អ្នកស្រី ខាវ ថងញ៉ុត ភរិយាលោក ស៊ិន ស៊ីសាមុត

# ជីវិតរបស់ភរិយាអធិរាជសម្លេងមាស

# ស៊ិន ស៊ីសាមុត



លោក ស៊ិន ស៊ីសាមុត

...អ្នកណាម្នាក់ក៏ស្គាល់ឈ្មោះលោក ស៊ិន ស៊ីសាមុត ដែរ ពីព្រោះ បទចម្រៀងរបស់លោកបានអង្រួនដួងចិត្តប្រជាពលរដ្ឋខ្មែររាប់សិបឆ្នាំ ទាំងក្នុងប្រទេស និងក្រៅប្រទេសធ្វើឱ្យគេម្នាក់ៗមិនអាចបំភ្លេចបាន បើទោះបីរូបគាត់បានលាចាកយើងគ្រប់គ្នាក៏ដោយ ។ អ្វីដែលគាត់បានបន្សល់នោះ គឺកេរ្តិ៍ឈ្មោះដ៏ល្បីល្បាញ តាមរយៈមរតកសំនៀងឱ្យខ្មែរគ្រប់ៗរូប និងគ្រប់ជំនាន់ ។

ប៉ុន្តែមរតកនេះក្រៅពីកិត្តិយស និងកេរ្តិ៍ឈ្មោះមរតកនេះមិនបានផ្តល់ឱ្យនូវជីវិត និងជីវភាពរបស់ភរិយា និងក្រុមគ្រួសារគាត់រុងរឿង និងល្បីល្បាញដូចនឹងកេរ្តិ៍ឈ្មោះ និងបទចម្រៀងរបស់គាត់ទេ ។ មនុស្សជាច្រើនកំពុងតែចង់ដឹងថា តើក្រុមគ្រួសាររបស់គាត់ ពិសេសភរិយារបស់លោកដែលនៅមានជីវិតនៅឡើយ រស់នៅក្នុងសភាពបែបណា ហើយមានកម្រងអនុស្សាវរីយ៍យ៉ាងណាជាមួយស្វាមីគាត់ កាលលោកនៅរស់ជុំគ្នាក្នុងសម័យកាលដ៏ត្រចេះត្រចង់ក្នុងជីវិតរបស់ពួកគាត់នោះ ។

•••ដើម្បីឆ្លើយតបទៅនឹងចម្ងល់ទាំងនេះ កាសែតខ្មែរប៉ុស្តិ៍បានធ្វើបទសម្ភាសន៍ជាមួយអ្នកស្រី ខាវ ថងញ៉ុត ភរិយារបស់អធិរាជសំឡេងមាស ស៊ិន ស៊ីសាមុត ដែលមានខ្លឹមសារដូចខាងក្រោមនេះ :

**•តើសព្វថ្ងៃនេះអ៊ុំស្រីមានអាយុប៉ុន្មានហើយ ?**

សូមអរគុណដល់កាសែតខ្មែរប៉ុស្តិ៍ សព្វថ្ងៃនេះខ្ញុំសុខសប្បាយធម្មតាទេ តែចំពោះសុខភាពរបស់ខ្ញុំវិញ សព្វថ្ងៃវា ដូចជាថមថយចុះច្រើនឆ្នាំនេះ ប្រៀបទៅនឹងឆ្នាំកន្លងទៅ ។ ឆ្នាំនេះ ខ្ញុំមានអាយុ៦៨ឆ្នាំហើយ បើប្រៀបធៀបទៅនឹងព្រះអាទិត្យ គឺរៀបនឹងអស្តង្គតទៅហើយ ហើយភាពចាស់ជរារបស់ខ្ញុំក៏ដូចគ្នាទៅនឹងព្រះអាទិត្យនេះដែរ ។

**•សព្វថ្ងៃអ៊ុំស្រីរស់នៅជាមួយអ្នកណាដែរ ?**

-ចាស! សព្វថ្ងៃខ្ញុំមិនទៅណាចោលភូមិកំណើតរបស់ខ្ញុំទេ គឺនៅភូមិស្ពានថ្ម ឃុំស្ទឹងត្រែង ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង ។ ចំណែកឯការរស់នៅសព្វថ្ងៃនេះ ខ្ញុំមិនបានរស់នៅជាមួយកូនណាទេ គឺខ្ញុំរស់នៅជាមួយចៅស្រីដែលជាកូនស្រីច្បង (យុទ្ធនា) កូនស្រីទី១របស់ខ្ញុំ ។ សព្វថ្ងៃចៅស្រីរបស់ខ្ញុំនាងធ្វើជាគ្រូបង្រៀននៅសាលាវិទ្យាល័យ ហ៊ុន សែន ស្ទឹងត្រែង ។

មូលហេតុដែលរស់នៅផ្ទះមួយផ្សេងតែពីរនាក់ចៅ គឺពីដើមឡើយពួកខ្ញុំទាំងកូនចៅរស់នៅផ្ទះតែមួយ ។ ប៉ុន្តែក្រោយមកយុទ្ធនាកូនស្រីខ្ញុំគេបានសង់ផ្ទះថ្មីមួយទៀតទៅពេលនោះក៏ត្រូវបំបែកគ្នានៅ ហើយផ្ទះទាំងពីរនៅជាប់គ្នាស្ថិតនៅលើដីភូមិតែមួយ ។ ចំពោះការហូបចុក គឺហូបរួមគ្នាដដែល គឺបែកគ្នាតែការដេកនៅតែប៉ុណ្ណឹងទេ ។

**•តើអ៊ុំស្រីមានកូនប៉ុន្មាននាក់ដែរ ?**

-ចាស! ខ្ញុំមានកូនចំនួន៤នាក់ តែសព្វថ្ងៃនៅរស់តែពីរនាក់ គឺទី១ ឈ្មោះ ស៊ិន យុទ្ធនា ទី២ ស៊ិន ច័ន្ទឆាយ៉ា ហើយនិងមានចៅចំនួន៦នាក់ហើយ ។ យុទ្ធនាសព្វថ្ងៃគេធ្វើការនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈសរសៃសូត្រខ្មែរស្ទឹងត្រែង ។

**ទាក់ទិននឹងវ័យក៏កាន់តែជរា តើអ៊ុំស្រីកាន់សីលដែរឬទេ ? ស្របគ្នាទៅនឹងកូនប្រុសបើកសមាគម ស៊ិន ស៊ីសាមុត អ៊ុំស្រីមានអារម្មណ៍យ៉ាងម៉េចដែរ ?**

-អ៊ុំស្រី ថងញ៉ុត



គុជ ចន្ថា ចាងហ្វាងផលិតកម្មមាតុភូមិ និងភរិយាលោក ស៊ិន ស៊ីសាមុត

បានបន្ទីសំណើច

កខឹក រួចទើបបន្តឆ្លើយតប)

ក្មួយអើយបើនិយាយរឿង កាន់សីល គឺខ្ញុំបានព្យាយាមប្រតិបត្តិ តាំងពីក្រោយថ្ងៃរំដោះ ៧មករាម្ល៉េះរហូត ពេលនេះគឺជិត៣០ឆ្នាំ ហើយកាន់សីល៨ មួយខែធ្វើចង្ហាន់ទៅប្រគេនព្រះសង្ឃចំនួន៤ដង គឺពុំដែលខកខានម្តងណាឡើយ ហើយខ្ញុំត្រូវយកចង្ហាន់ទៅ គឺថ្ងៃ៥ ថ្ងៃ៨ ថ្ងៃ៤ ថ្ងៃ១៥ គឺទៅ៤ថ្ងៃក្នុង១ខែ ។

**•តើចង្ហាន់យកទៅប្រគេនព្រះសង្ឃ អ៊ុំស្រី រៀបចំដោយខ្លួនឯងឬ ?**

ចំពោះចង្ហាន់នោះ គឺពួកគេពុំដែលធ្វើឱ្យខកខានខែណាមួយឡើយ ទោះបីមាន ឬមិន មានក្តី ក៏កូននិងចៅៗ ខំប្រឹងបំពេញ តាមការគួររបស់ពួកគេ ។ ចំពោះរឿងក្រុមគ្រួសារ ឆាយ៉ា នៅភ្នំពេញ ក៏គេបានទទួលជួយមួយចំណែកដែរ ពោលគឺគេតែងតែផ្ញើជាលុយកាក់បន្តិចបន្តួចតាមលទ្ធភាពដែលគេអាចជួយទៅបាន ។

ចំណែកឯរឿង បើកសមាគមស៊ិន ស៊ីសាមុត ចំពោះអារម្មណ៍របស់ខ្ញុំ ខ្ញុំគិតថា វាល្អណាស់ ហើយ



ចៅស្រីបង្កើត ស៊ិន ស៊ីសាមុត នៅស្ទឹងត្រែង

ដែលកូនប្រុសរបស់ខ្ញុំ ក៏ដូចជាអ្នករួមគំនិតផ្តើមបើកសមាគមនេះឡើង ។ រូបខ្ញុំផ្ទាល់ក្នុងនាមជាភរិយាដែលគេហៅគាត់ថា អធិរាជសំលេងមាស ស៊ិន ស៊ីសាមុត ទោះគាត់បានស្លាប់បាត់បង់ជីវិតបាត់ហើយក៏ដោយ តែលោកបានបន្សល់ទុកនូវចំណីអារម្មណ៍ ដើម្បីនៅកំដរប្រិយមិត្តតាមរយៈបទចម្រៀងជាហេតុមិនអាចឱ្យគេបំភ្លេចបានត្រង់នេះ ហើយដែលជំរុញចិត្តគាំទ្រកូនប្រុសរបស់ខ្ញុំ គឺ ស៊ិន ច័ន្ទឆាយ៉ា ចំពោះជំហរ ដែលគេផ្តើម

( តទៅទំព័រទី២០ )



# ហោរាសាស្ត្រប្រចាំខែ កញ្ញា ថ្ងៃទី ២៣-០៩



### ឆ្នាំជូត : (ពពួកទេវតាប្រុស ធាតុទឹក)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែមានផលចំណូលហូរចូលបានច្រើនក្រាស់ក្រែលគួរសមក្តី តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះចាយវាយខ្ជះខ្ជាយខ្លាំងពេក ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ បើស្រលាញ់កុំទៅញីក បើរពូកកុំទៅញយ ទើបចំណងស្នេហាអាចគង់វង្សបានយូរអង្វែង ៕



### ឆ្នាំឆ្លូវ : ( ពពួកមនុស្សប្រុស ធាតុដី )

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿង រកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ លោកអ្នកអាចផ្អាករាល់កិច្ចការងារសំខាន់ៗមួយរយៈពេលសិន ព្រោះបើហ៊ានតែមានចិត្តមានះរឹងរូស គឺពិតជាស៊ិយធំអាចបង់ខាតទ្រព្យជាក់ជាមិនខាន ។ ចំពោះស្ត្រីភេទក្នុងរយៈពេលនេះ មិនត្រូវដើរផ្លូវឆ្ងាយដាច់សង្វែងតែម្នាក់ឯងឡើយ ប្រយ័ត្នបានជួបគ្រោះភ័យ ៕



### ឆ្នាំខាល : ( ពពួកយក្សស្រី ធាតុឈើ )

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ក៏អាចទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ ។ បើជាអាជីវករ អ្នករកស៊ីជួញដូរ នឹងមានទំនិញលក់ចេញទិញចូលឥតទំនេរដៃ ព្រមទាំងមានទ្រព្យហូរចូលជាហូរហែទៀតផង ៕



### ឆ្នាំថោះ : ( ពពួកមនុស្សស្រី ធាតុឈើ )

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ បើជាបុគ្គលិក កម្មករដែលបំរើការងារនៅតាមក្រុមហ៊ុន ឬរោងចក្រនានា ចូរចេះដាក់ខ្លួនដាក់កាយ និងចេះធ្វើទំនាក់ទំនងល្អជាមួយនឹងចៅហ្វាយនាយ ឬថៅកែ ព្រមទាំងអ្នករួមការងារជាមួយ ទើបកិច្ចការងារអាចដំណើរការបានស្រួល ៕



### ឆ្នាំរោង : (ពពួកទេវតាប្រុស ធាតុមាស)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿង រកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ លោកអ្នកអាចផ្អាករាល់កិច្ចការងារសំខាន់ៗមួយរយៈពេលសិន ព្រោះបើហ៊ានតែមានចិត្តមានះរឹងរូស គឺពិតជាស៊ិយធំអាចបង់ខាតទ្រព្យជាក់ជាមិនខាន ។ ចំពោះស្ត្រីភេទក្នុងរយៈពេលនេះ មិនត្រូវដើរផ្លូវឆ្ងាយដាច់សង្វែងតែម្នាក់ឯងឡើយ ប្រយ័ត្នបានជួបគ្រោះភ័យ ៕



### ឆ្នាំម្សាញ់ : (ពពួកមនុស្សប្រុស ធាតុភ្លើង)

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ក៏មានអ្នកជួយជ្រោមជ្រែងយ៉ាងពេញទំហឹងដែរ ។ ចំពោះស្ត្រីភេទនៅលីវ និងត្រូវបានកម្លោះៗចោមរោមស្រលាញ់ រហូតអាចឈានដល់ការស្តីដណ្តឹងយកធ្វើជាគូអនាគតទៀតផង ៕



### ឆ្នាំមមី : (ពពួកទេវតាស្រី ធាតុភ្លើង)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ត្រូវមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ជាពិសេសមុននឹងចុះហត្ថលេខា ឬផ្តិតស្នាមមេដៃផ្សេងៗ ចូរចេះពិនិត្យពិច័យឱ្យបានល្អិតល្អន់ ព្រោះកាលបើមានការភ្លាំងភ្លាត់តែបន្តិច អាចបង់ខាតផលប្រយោជន៍ច្រើន ៕



### ឆ្នាំមមែ : (ពពួកទេវតាស្រី ធាតុមាស)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ បើមានរឿងឈ្លោះប្រកែកកើតឡើង ចូរចេះអត់ធ្មត់ និងរម្ងាប់ចិត្តឱ្យបានត្រជាក់ ដាច់ខាតមិនត្រូវតបតទាំងកំហឹងទល់នឹងកំហល់ឡើយ ទើបរឿងតូចមិនអាចក្លាយជារឿងធំបាន ។ ក្នុងរយៈពេលនេះ បើមានដំណើរទៅណាមកណា ចូរប្រយ័ត្នប្រយែងក្រែងជួបគ្រោះថ្នាក់ចរាចរ ៕



### ឆ្នាំវក : (ពពួកយក្សប្រុស ធាតុដែក)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ លោកអ្នកមានអារម្មណ៍ភ្លឺថ្លា គំនិត ប្រាជ្ញាឈ្លាសវៃ ទោះប្រកបកិច្ចការងារអ្វីៗក៏ដោយ ក៏អាចទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ ។ ចំពោះស្វាមីភរិយាវិញ មានភាពល្អកល្អឹនគ្នាណាស់ ហើយពិសេស នោះស្រលាញ់គ្នាលើសមុនទៅទៀត ៕



### ឆ្នាំរកា : (ពពួកយក្សប្រុស ធាតុដែក)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងបញ្ហាលំបាកៗច្រើន។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ចូរកុំមានការធ្វេសប្រហែសឱ្យសោះ ជាពិសេសចំពោះអាជីវករអ្នករកស៊ីប្តូរប្រាក់ ឬលក់គ្រឿងអលង្ការមានតម្លៃផ្សេងៗ ត្រូវប្រយ័ត្នប្រយែងមានជនខិលខូចលួចបន្លំ ឬឆក់ប្លន់ ៕



### ឆ្នាំច : ( ពពួកយក្សស្រី ធាតុដី )

រាសីលោកអ្នកល្អធម្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះរាល់ឧបទ្រពចង្រៃ និងរាល់ឧបសគ្គត្រូវបានសាបរលាបជាបណ្តើរៗ ដូច្នេះលោកអ្នកអាចប្រកបកិច្ចការងាររកស៊ីបានពេញដៃពេញជើង ។ ចំពោះអ្នកជំនួញជួញដូរ បើមានប្រគល់ ឬទទួលនូវមុខទំនិញសព្វសារពើ ចូរចេះពិនិត្យគុណភាព និងរាប់ចំនួនឱ្យបានច្បាស់លាស់ ទើបពុំមានរឿងឆបោកកើតឡើង ៕



### ឆ្នាំកុរ : (ពពួកមនុស្សស្រី ធាតុទឹក)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ក្នុងរយៈពេលនេះ អ្វីដែលលោកអ្នកត្រូវយកចិត្តទុកដាក់នោះ គឺនៅតែមានមនុស្សខិលខូចខ្លះប៉ងបំផ្លិចបំផ្លាញរាល់កិច្ចការងារ ដូច្នេះមុននឹងធ្វើអ្វីមួយ ឬមុននឹងធ្វើដំណើរទៅណាមកណា ចូរមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ។ ចំពោះគូស្នេហ៍ក្នុង រយៈពេលនេះមានការយល់ចិត្តគ្នាល្អ គ្មានបញ្ហាអ្វីកើតឡើងធំដុំទេ ៕


## Buy something... Sell something...Announce something...advertise on the Khmer Post Classifieds!

**រកផ្ទះជួល**

យើងត្រូវការផ្ទះមានពីរ ឬបីបន្ទប់គេង នៅតំបន់ខាងជើងហ្វីឡាដែលហ្វៀ សូមទំនាក់ទំនងមកសុបិន : **(267) 253-3947**

South Philadelphia Library, 1700 S. Broad St.
**ESL classes,** Tuesdays & Thursdays 12:30-3:00 p.m.

**Books and DVDs in Khmer language**
South Philadelphia Branch, 1700 S .Broad St.
Whitman Branch, 200 Snyder Ave.
Greater Olney Branch, 5501 N. 5th St.
Wyoming Branch, 231 E. Wyoming Ave.

**រដ្ឋសង $500-650 គាត់ លើសម្បត្តិ**

ចំពោះម្ចាស់ផ្ទះ ឬអ្នកជួលផ្ទះ ដែលមានអាយុ +៦៥ -មេម៉ាយ ឬពោះម៉ាយ +៥០ -មនុស្សពិការ +១៨ ឆ្នាំ ហើយមានប្រាក់ចំណូលចន្លោះ ១៥,០០០-៣៥,០០០-អាចទាមទារប្រាក់នោះបាន រហូតដល់ថ្ងៃ ៣១ធ្នូ ០៨.

សូមហៅទៅ **(215) 467-0690** SEAMAAC

**Your Advertisement**
**Is Here For**
**Less than $10 for two weeks!**

Service
C.C. Building Services
Metropolitan Area




**រកមនុស្សធ្វើការច្រើនគ្នា**

ធ្វើជាអ្នកជំនួយដល់មនុស្សពិការនៅជុំវិញ Philadelphia
THIG ទូរស័ព្ទ : **215 320 2040** WEBSITE : www.taigine.org
ការងារល្អត្រឹមត្រូវ មាន BENEFIC មានសវិស្សមកាល...

**Clip & Fax This**
**Classified Coupon**

Classified Advertising
Name your category: Sales, Services, Fund Raisers…etc.
Our rates: $5.00 for up to 22 words
15 cents each additional words
Send us your ad in one of the following ways:
1. by Fax to (215) 722-2226
2-by mail to the Khmer Post 5730 Rising Sun Avenue. Philadelphia, Pa 19120 3-By phone (267) 253-3947
Payments methods: cash or checks.
Name:__________ Address: ________
City____________________
State ________ Zip__________
Phone: ________ Fax__________
Your Advertisement Message:

# ក្រសួងការពារជាតិអាមេរិកាំងផ្តល់សិទ្ធិថ្មីដល់អតីតយុទ្ធជនខ្មែរនៅសហរដ្ឋអាមេរិក



អតីតយុទ្ធជនខ្មែរដែលធ្លាប់ប្រយុទ្ធនៅកម្ពុជា ស្មាទល់នឹងស្មាជាមួយសហរដ្ឋអាមេរិក បានត្រូវលោក **សរិត ប៉ែន** អតីតកាលទាហានខ្មែរកំពុងផ្សព្វផ្សាយអញ្ជើញអតីតយុទ្ធជនខ្មែរទាំងអស់ឱ្យដាក់ពាក្យបង្ហាញខ្លួន ដើម្បីយកសិទ្ធិជាអតីតកងទ័ពជាតិទៅក្រសួងការពារជាតិអាមេរិកាំង ។

*Department of Defense*

**Report to Congress**

**on**

**Military Funeral Honors for Veterans**

***As Required by***
***Section 567 of the Strom Thurmond National Defense Authorization Act for Fiscal Year 1999***

នៅសហរដ្ឋអាមេរិកនេះ សិទ្ធិជាអតីតយុទ្ធជន បានត្រូវផ្តល់ឱ្យដល់អតីតយុទ្ធជនវៀតណាម និង "ហ្មុង" រួចហើយ រីឯអតីតយុទ្ធជនខ្មែរទើបតែនឹងដឹងដំណឹងជាដំបូងនៅពេលនេះ ។ គេនៅពុំទាន់ដឹងនៅឡើយថា "សិទ្ធិជាអតីតយុទ្ធជនខ្មែរ" នោះ នឹងទទួលបានភាគផលអ្វីនៅឡើយទេ ។

**ទូរស័ព្ទលោក : សរិត ប៉ែន (267) 574-6695**









# ប៉ែន សុវណ្ណ និយាយអ្វីពី ហ៊ុន សែន ប្រាប់ខ្មែរប៉ុស្តិ៍

●●●ជាមួយលោកអតីតនាយករដ្ឋមន្ត្រី សាធារណរដ្ឋកម្ពុជាប្រជាមានិត ប៉ែន សុវណ្ណ បានឆ្លើយនឹងអំពីស្ថានភាពជីវិតរបស់លោក ក្រោយពីបានយួនដោះលែងលោកឱ្យចេញពីគុក ងងឹតក្រុងហាណូយប្រទេសយួនកុម្មុយនីស្ត ។ ដោយសារមានអន្តរាគមន៍ពីរណសិរ្ស ជាតិរំដោះប្រជាពលរដ្ឋខ្មែរ រ.ជ.រ.ប.ខ ដឹក នាំដោយលោកតា សឺន សាន កិច្ចព្រមព្រៀង ទីក្រុងប៉ារីស ២៣ តុលា ឆ្នាំ ១៩៩១ និងអង្គការសហប្រជាជាតិ (អ៊ុនតាក់) នាឆ្នាំ ១៩៩២-១៩៩៣ ។

ក្នុងសំនួរទី១ លោក ប៉ែន សុវណ្ណ បាន ឆ្លើយថា : មានអ្នកយកព័ត៌មានបានសួរទៅ លោក ហ៊ុន សែន អំពីករណីលោក ប៉ែន សុវណ្ណ ត្រូវធ្វើមាតុភូមិនិវត្តន៍ថា : តើឱ្យគាត់ធ្វើអ្វីនៅក្នុងឆាកនយោបាយ ? លោក ហ៊ុន សែន បានឆ្លើយថា : ខ្ញុំ និងគណបក្ស

ប្រជាជនកម្ពុជានឹងបញ្ជូនលោក ប៉ែន សុវណ្ណ ឱ្យទៅនៅស្រុកកំណើតរបស់គាត់ ។ គាត់អាចធ្វើជាកសិករ ដូចជាប្រជាពលរដ្ឋខ្មែរ ដទៃទៀតដែរ ។ ពេលនោះគាត់យកខ្ញុំ មកនៅភូមិស្នោ ឃុំរកា ក្នុងស្រុកដូនកែវ ខេត្តតាកែវ ជាស្រុកកំណើត ក្បែរវាលបឹង គឺគ្មានរបបគ្មានគោលឥនយោបាយ សំរាប់ឧបត្ថម្ភជាអតីតអ្នកតស៊ូរជនដែលហ៊ានពលិកម្ម ដើម្បីជាតិមាតុភូមិក៏គ្មាន ។

ចំណែកផ្ទះសម្បែងឱ្យមិនបានត្រឹមត្រូវដូចជាពួកគេទេ ហើយដីនៅត្រង់ហ្នឹងត្រូវដាំដំណាំចិញ្ចឹមមាន់ ចិញ្ចឹមជ្រូក សំរាប់លក់ចិញ្ចឹមជីវិត ។ លោក ហ៊ុន សែន ប្រាប់តាមមន្ត្រីរាជការក្នុងគណបក្សប្រជាជនកម្ពុជាថា : បើចង់ចូលបំរើក្នុងគណបក្សប្រជាជនកម្ពុជាសុំហាមពីរចំណុច : គឺទី១ កុំចង្អៀតចង្អល់នឹងយួនកុំរិះគន់នឹងនិគមជនយួន ដែលមកតាំងទីលំនៅក្នុងស្រុកខ្មែរនេះ ។ បញ្ហាទី២ គឺថាកុំនិយាយពីរឿងមាស១២តោន ពេជ្រ២គីឡូ ដែលជាជ័យភ័ណ្ឌ ខ្ញុំយកពីរបប ប៉ុល ពត កាលពីឆ្នាំ១៩៧៩ ហើយយកមកដាក់រាត់រាយមិនទាន់មានធនាគារគ្រប់គ្រងទេ យកមកទុកនៅក្នុងបរិវេណលំនៅស្ថានរបស់ខ្ញុំ ។ កាលណោះមានអង្គរក្សការពារខ្លះ បើកែទម្រង់រចនា-សម្ព័ន្ធរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ពេលហ្នឹងធ្វើបានខ្ញុំមានគ្រប់លក្ខណៈសម្បត្តិបក្សទាំងរដ្ឋាភិបាលផង ។

ខ្ញុំបានអញ្ជើញគណៈប្រតិភូគណបក្ស និងរដ្ឋាភិបាលមកចូលឃ្លាំងមាសហ្នឹងមាន៧២កេស ក្នុងមួយកេសមានទម្ងន់២៥០គីឡូ សុទ្ធតែមាសដុំ ។

**សំនួរ:** តើរឿងមាសទាំងនេះ សព្វថ្ងៃនៅឯណា ?

លោក ប៉ែន សុវណ្ណ : ចាំ ខ្ញុំជំរាបឱ្យអស់សិន ពេលខ្ញុំចេញពីគុកហើយ មុននេះ ខ្ញុំបានប្រគល់ឱ្យគេហើយ កាលខ្ញុំនៅកាន់អំណាចបានប្រគល់ឱ្យអ្នកដឹកនាំទាំងរដ្ឋាភិបាលទាំងបក្សនៅម៉ោង ៨ព្រឹក ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៨១ ។ អស់លោកបានទទួលស្គាល់ ឆ្លើយថាមាសមែនពិត ហើយខ្ញុំឱ្យចុះហត្ថលេខាក្នុងសៀវភៅហ្នឹង ហើយដល់ពេលខ្ញុំចេញពីគុក ខ្ញុំបានសួរកូនចៅចាស់ គេប្រាប់ថា មាស១២តោនជាង និងពេជ្រ២គីឡូ គេថាចែកគ្នាអស់ហើយ តាំងពីឆ្នាំ១៩៨៧ គេប្រាប់ខ្ញុំជាសម្ងាត់ ។


អតីតនាយករដ្ឋមន្ត្រីខ្មែរ ប៉ែន សុវណ្ណ ផ្តល់បទសម្ភាសន៍ដល់វិទ្យុខ្មែរប៉ុស្តិ៍

ហេតុនេះបានជាគេថា: កុំឱ្យរំលឹកកុំសួរពីរឿងមាសឬ គាស់កកាយពីរឿងមាស និងទី២ កុំឱ្យប្រឆាំងយួននិគមជនយួនមកតាំងលំនៅដ្ឋានក្នុងស្រុកខ្មែរទៀត ។ បើធ្វើបានបក្សប្រជា-ជនកម្ពុជា គេឱ្យចូលរួមចំណែកក្នុងសកម្មភាពនយោបាយវិញ ។

**សំនួរ** : ជុំវិញបញ្ហាដែលលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មិនចង់ឱ្យលោកទៅកាន់តំណែងណាមួយក្នុងគណបក្សប្រជាជនកម្ពុជាហ្នឹង ដោយសារលោកមានប្រជាប្រិយភាព ហើយជាមេចាស់ពិបាកលោក ហ៊ុន សែន គ្រប់គ្រង ឬក៏ចាត់ចែងនេះវាទាក់ទងទៅនឹងឯកសារមួយដែលវិទ្យុខ្មែរប៉ុស្តិ៍ទទួលបាន គឺឯកសារដែលនិយាយពីកំណត់ហេតុស្ដីពីសន្និបាតលើកទី១ នៃសហជីពនៅក្រសួងការបរទេស នៅថ្ងៃទី ៦ ដល់៨ ខែតុលា ឆ្នាំ១៩៨១ ដែលសម័យនោះ លោក ហ៊ុន សែន នៅជាអនុប្រធានក្រុមប្រឹក្សាគណរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបទេស ហើយលោកបានសំណូមពរ នៅក្នុងសន្និបាតប្រជុំថា : សូមឱ្យសមមិត្តទាំងអស់គ្នាពិចារណាឱ្យបានហ្មត់ចត់ជុំវិញថា : "បើអ្នកណាប្រឆាំងនឹងវត្តមានរបស់យួន គឺប្រឆាំងនឹងអាយុខ្លួនផ្ទាល់" ។

(តនៅលេខក្រោយ)


អត់ពីលោកអ្នកនៅ តើបាននរណាជួយថែរក្សាកូនចៅលោកអ្នក ?

NEW YORK LIFE

១-ធានារ៉ាប់រងសម្រាប់ជីវិត (Life Insurance)
២-សន្សំលុយសំរាប់ចូលនិវត្តន៍ (Retirement Planning)
៣-សន្សំលុយសម្រាប់កូនចូលរៀនមហាវិទ្យាល័យ (College Saving)
៤-រៀបចំទ្រព្យសម្បត្តិទុកឱ្យកូនចៅ (Estate Planning)



ខ្ញុំអាចជួយពន្យល់ដល់បងប្អូនដោយមិនយកកម្រៃ

WUTHA CHIN MBA,
Agent New York Life
P. (610) 660 5897, Cell. P (267) 736 0445
wchin@ft.newyorklife.com

ឱសថស្ថានខ្មែរ
Sav-Mor PHARMACY
Sam EA R.Ph.
2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447



បំរើលោកអ្នកដោយមិត្តភាព និងរហ័សចិត្ត
Fast and Friendly Service

- Sav-Mor គឺជាឱសថស្ថានបំរើ ការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំ តាមវេជ្ជបញ្ជាជាភាសាខ្មែរបាន
- យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ឬទៅអន្តរជាតិ

*Accept most insurance plans including Medicare & Medicaid
*Easy Prescription transfer
*Inside. Prepaid phone card. Call Cambodia.




U.S.A. AUTO GLASS
ហាងជួសជុលកញ្ចក់រថយន្ត

-ដាក់កញ្ចក់ឡានគ្រប់ធុន កញ្ចក់ថ្មី ឬ ចាស់
-ធានាគុណភាពដល់ទៅ ១ ឆ្នាំ
-យ៉ាងឆាប់រហ័ស រយៈពេលក្នុងថ្ងៃតែមួយ

បើលោកអ្នកមិនអាចអញ្ជើញមកហាងយើងខ្ញុំបាន ខ្ញុំបានអាចទៅប្តូរកញ្ចក់ឡានដល់ផ្ទះ






We Specialized in:
Windshield Replace,
Windshield Repair
Door Glass Repair
Sun Roof + Side Mirror
Window Motor + Regulator
Window Tint
State inspection
Wiper Blades

WE'LL COME TO YOUR HOME OR BUSINESS

SAME DAY SERVICE
1 YEAR WARRANTY
NEW/USED GLASS

Monday-Friday 8 a.m. - 5 p.m. Saturday 8 a.m. - 2 p.m.

1822 South 7th Street.
Philadelphia, Pa 19148
Tel: 215.271.7190
Fax: 215.271.9150